សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droits et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ៖

និស្សិត៖ កញ្ញា **គុជ សេងអេនជី**

ណែនាំដោយ៖

លោក **ភង ស៊ីផាន់ណារ៉ា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droits et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយៈ
និស្សិតៈ កញ្ញា **គុជ សេងអេនជី**

ណែនាំដោយៈ
លោក **ភង ស៊ីផាន់ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គុជ សេខអេនជី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ ក្រុម L4B05 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង សូមលំអោនកាយ វាចាចិត្ត ប្រកបដោយកតញ្ញូកតវេទិតាធម៌ និងភក្តីភាព សូមធ្វើគារវកិច្ច និង កត្តញ្ញូតាធម៌ចំពោះ៖

លោកឪពុកអ្នកម្តាយដែលមានគុណយ៉ាងធំធេង និងមិនអាចកាត់ថ្លៃងបានចំពោះរូបកូនដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សារូបកូនប្រកបដោយព្រហ្មវិហារធម៌ និងបានបញ្ជូនកូនឲ្យទៅសាលារៀនដើម្បីសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹង ដើម្បីរស់នៅប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ។

លោកគ្រូសាស្ត្រាចារ្យ **កុច ស៊ីផាន់ណារ៉ា** ដែលលោកបានខិតខំណែនាំ ដឹកនាំនាងខ្ញុំដោយបង្ហាញទិសដៅ ផ្ទេរចំណេះ និងផ្តល់ ជាអនុសាសន៍ល្អៗ ពន្យល់ណែនាំនាងខ្ញុំអស់ពីកម្លាំងកាយចិត្ត អស់ពីសម្ថភាពមិនគិតអំពីការនឿយហត់គ្រប់បែបយ៉ាង ដើម្បីចំណេះដឹងបន្ថែម និងដើម្បីការពារសារណាបញ្ចប់ការសិក្សា ជាពិសេសដើម្បីជាធនធានសម្រាប់ប្រទេសជាតិទាំងមូលផងដែរ។

លោកគ្រូ អ្នកគ្រូ និងលោក-លោកស្រីសាស្ត្រាចារ្យតាំងពីបឋមសិក្សា រហូតដល់ពេលបច្ចុប្បន្ន ពិសេសលោកគ្រូលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ដែលបានខិតខំបង្ហាត់បង្រៀន អប់រំទូន្មានប្រៀនប្រដៅដល់នាងខ្ញុំឲ្យក្លាយទៅជាសិស្សល្អ និងធ្វើឲ្យនាងខ្ញុំបានទទួលចំណេះដឹងជាច្រើនមិនអាចកាត់ថ្លៃបាន និងជាចំណេះ ព្រមទាំងជំនាញសម្រាប់ខ្លួនឯងនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។

ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាថ្នាក់ដឹកនាំកំពូល ដែលបានអនុញ្ញាតឲ្យនាងខ្ញុំបានចូលសិក្សារៀនសូត្រតាំងពីឆ្នាំដំបូងរហូតដល់ពេលសរសេរសារណាបញ្ចប់កម្រិតបរិញ្ញាបត្រនេះ។

រៀមច្បងទាំងឡាយដែលបានបន្សល់ទុកនូវ ស្នាដៃល្អៗជាច្រើន សម្រាប់ធ្វើជាគម្រូ និងព័ត៌មានដល់នាងខ្ញុំផ្ទាល់ ក៏ដូចជានិស្សិតរួមជំនាន់ និងសិស្សប្អូនជំនាន់ក្រោយៗទៀត។

ជាចុងក្រោយនេះ នាងខ្ញុំសូមជូននូវពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ដល់លោកអ្នកមានគុណទាំងអស់កុំបីឃ្លាងឃ្លាតឡើយ។

## អារម្ភកថា

នាងខ្ញុំជានិស្សិតជំនាន់ទី២០ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២៣-២០២៤ បានសិក្សាបរិញ្ញាបត្រនីតិសាស្ត្ររយៈពេល៤ ឆ្នាំកន្លងមកនេះ មុខវិជ្ជាដែលនាងខ្ញុំគិតថាស្រឡាញ់ ចូលចិត្តនិងសាកសមបំផុត ក្នុងការលើកយកមកស្រាវជ្រាវ និងចងក្រងសារឡើងវិញ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ គឺមុខវិជ្ជា នីតិក្រុមហ៊ុន។ មុខវិជ្ជានេះពិតជាមានសារៈសំខាន់ណាស់ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់បង្កើតក្រុមហ៊ុន។ ដោយមើលឃើញពីអត្ថប្រយោជន៍បែបនេះ ទើបខ្ញុំបានជ្រើសរើសប្រធានបទក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

តាមរយៈប្រធានបទខាងលើនេះ នាងខ្ញុំចង់ស្វែងយល់ឲ្យកាន់តែស៊ីជម្រៅទៅលើដំណើរការនៃការបង្កើត និងប្រតិបត្តិការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ដូច្នេះប្រធានបទនេះ អាចជាគន្លឹះខ្លះៗ ដល់អ្នកដែលមានបំណងចង់ស្វែងយល់ និងបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

នាងខ្ញុំសង្ឃឹមថា ការខិតខំរបស់នាងខ្ញុំក្នុងការសិក្សាស្រាវជ្រាវ និងការចងក្រងនេះ អាចចូលរួមចំណែកក្នុងការផ្តល់ជាឯកសារដល់និស្សិតជំនាន់ក្រោយសិក្សាស្រាវជ្រាវបន្តមួយចំណែកផងដែរ។

ការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំ ពិតណាស់នៅមានការខ្វះខាត ពុំអាចគ្រប់ជ្រុងជ្រោយទេទាំងពេចន៍ អត្ថន័យ ខ្លឹមសារ ដោយសារតែការសិក្សា និងចំណេះដឹងរបស់នាងខ្ញុំនៅមានកម្រិត ដូច្នេះហើយអ្នកស្រាវជ្រាវទាំងឡាយ មេត្តា ខន្តី អភ័យទោស នូវកំហុសខុសឆ្គងដោយអចេតនា ហើយនាងខ្ញុំមានសេចក្តីសោមនស្សរីករាយ ចំពោះការរិះគន់ពីមិត្តអ្នកអាន និងមិត្តអ្នកសិក្សាស្រាវជ្រាវទាំងឡាយនៅក្នុងអត្ថន័យស្ថាបនា ដើម្បីកែលម្អឲ្យកាន់តែមានសុក្រឹត្យភាពថែមទៀត។

# មាតិកា

**ទំព័រ**

**បញ្ជីអក្សរកាត់**.......... vii

**បញ្ជីពាក្យបច្ចេកទេស**.......... viii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ.......... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ.......... ១

៣. គោលបំណងនៃការស្រាវជ្រាវ.......... ១

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ.......... ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ.......... ២

៦. សារៈសំខាន់នៃការស្រាវជ្រាវ.......... ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......... ២

## ជំពូកទី១

## ការបង្កើត និងការប្រព្រឹត្តិទៅនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

**១.១. សញ្ញាណក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**.......... ៣

**១.២. ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**.......... ៣

១.២.១. ល័ក្ខខ័ណ្ឌសុពលភាពចំពោះការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត.......... ៣

១.២.១.១.ការព្រមព្រៀងរបស់សមាជិកភាគហ៊ុន.......... ៤

១.២.១.២.សមត្ថភាពរបស់សមាជិកភាគហ៊ុន.......... ៤

១.២.១.៣. កម្មវត្ថុនៃការបង្កើតក្រុមហ៊ុន.......... ៤

១.២.២. ទម្រង់នៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត.......... ៤

១.២.២.១. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង.......... ៥

១.២.២.២. ខ្លឹមសារនៃលក្ខន្តិកៈ.......... ៥

ក. ទ្រង់ទ្រាយក្រុមហ៊ុន.......... ៥

ខ. នាមករណ៍ក្រុមហ៊ុន.......... ៥

គ. សញ្ជាតិក្រុមហ៊ុន.......... ៦

ឃ. ទីស្នាក់ការក្រុមហ៊ុន.......... ៧

ង. កម្មវត្ថុក្រុមហ៊ុន ........ ៧
ច. ថេរវេលា ........ ៧
១.២.២.៣. ដើមទុន និងភាគហ៊ុនរបស់ក្រុមហ៊ុន ........ ៨
ក. ដើមទុន ........ ៨
ខ. ភាគហ៊ុន ........ ៩
១.២.២.៤. ការផ្សព្វផ្សាយសាធារណៈ ........ ៩
ក. ការផ្សាយក្នុងសារព័ត៌មានស្របច្បាប់ ........ ៩
ខ. ការតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ........ ១០
គ. ការចុះបញ្ជីពាណិជ្ជកម្ម ........ ១០
**១.៣. ការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** ........ ១១
១.៣.១. ការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមហ៊ុន ........ ១១
១.៣.១.១. ក្រុមប្រឹក្សាភិបាល ........ ១២
ក. ការរើសតាំងសមាជិកក្រុមប្រឹក្សាភិបាល ........ ១២
ខ. ការបោះឆ្នោតរើសតាំងប្រធានក្រុមប្រឹក្សាភិបាល ........ ១២
គ. មុខងាររបស់ក្រុមប្រឹក្សាភិបាល ........ ១២
ឃ. ការបញ្ចប់តួនាទីរបស់ក្រុមប្រឹក្សាភិបាល ........ ១៣
១.៣.១.២. អភិបាល ........ ១៣
ក. ការតែងតាំងអភិបាល ........ ១៣
ខ. តួនាទីរបស់អភិបាល ........ ១៤
គ. សិទ្ធិរបស់អភិបាល ........ ១៤
ឃ. ការបញ្ចប់តួនាទីរបស់អភិបាល ........ ១៥
១.៣.១.៣. លេខាធិការរបស់ក្រុមហ៊ុន ........ ១៥
១.៣.១.៤. មហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន ........ ១៦
ក. មហាសន្និបាតវិសាមញ្ញ ........ ១៦
ខ. មហាសន្និបាតប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន ........ ១៦
គ. ការដឹកនាំសន្និបាតរបស់ម្ចាស់ភាគហ៊ុន ........ ១៦
ឃ. ការបោះឆ្នោតសម្រេចដោយម្ចាស់ភាគហ៊ុនក្នុងអង្គប្រជុំពិសេស ........ ១៦

ង. វិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ..................... ១៧
១.៣.២. ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ..................... ១៨

## ជំពូកទី២

## នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

**២.១. ការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យា** ..................... ២០
២.១.១. ការចុះបញ្ជីបង្កើត ..................... ២១
២.១.២. ការចុះបញ្ជីកែប្រែ ..................... ២៥
**២.២. អានុភាពនៃការចុះបញ្ជី** ..................... ៣០
២.២.១. ការចុះបញ្ជីបង្កើត ..................... ៣០
២.២.២. ការចុះបញ្ជីកែប្រែ ..................... ៣១
២.២.៣. ការចុះបញ្ជីរំលាយ ..................... ៣១

## ជំពូកទី៣

## ប្រតិបត្តិការរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

៣.១. សំណើរលក់មូលបត្រ និងការបោះផ្សាយមូលបត្រ..................... ៣២
៣.១.១. ការពិនិត្យលើពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ..................... ៣២
៣.១.២. លក្ខខណ្ឌនៃពាក្យស្នើរសុំបោះផ្សាយ និងលក់មូលបត្រ..................... ៣៣
៣.១.៣. ការយល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ..................... ៣៤
៣.១.៤. ការដាក់លក់មូលបត្រជាសាធារណៈ..................... ៣៤
៣.២. កាពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ..................... ៣៦
៣.២.១. ពាក្យស្នើសុំពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ..................... ៣៦
៣.២.២. ការអនុញ្ញាតលើលទ្ធភាពអាចចុះបញ្ជី..................... ៣៧
៣.៣. យន្តការបោះផ្សាយមូលបត្រកម្មសិទ្ធិសាធារណៈ..................... ៣៧
៣.៣.១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយមូលបត្រជាសាធរណៈ..................... ៣៨
៣.៣.២. ការតែងតាំងក្រុមហ៊ុនធានាទិញ..................... ៣៨
៣.៣.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ..................... ៣៨
៣.២.៤. ការត្រួតពិនិត្យការបំពេញការតព្វកិច្ចតាមច្បាប់..................... ៣៩
៣.៣.៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ..................... ៣៩

៣.៣.៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនិងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ....................................៣៩
៣.៣.៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង( Book Building )..........................៤០
៣.៣.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សាមូលបត្រកម្ពុជា..........................៤០
៣.៣.៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើរលក់ និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.................................................................៤០
៣.៣.១០. ការធ្វើបរិវិសកម្មមូលបត្រ.........................................................................................៤០
៣.៣.១១. ការរាយការណ៍ពីលទ្ធផលនៃបរិវិសកម្មមូលបត្រ...................................................៤១
៣.៣.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សាមូលបត្រកម្ពុជា............................៤១
ក. ការដាក់ពាក្យចុះបញ្ជីជាផ្លូវការ.........................................................................៤១
ខ. ការផ្តល់ការអនុញ្ញាតនៃការចុះបញ្ជី....................................................................៤២
៣.៤. ការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិ.............................................................៤២
៣.៤.១. ការជម្រះបញ្ជីក្រុមហ៊ុនដោយស្ម័គ្រចិត្ត..................................................................៤២
៣.៤.២. ការជម្រះបញ្ជីក្រុមហ៊ុនតាមផ្លូវតុលាការ.................................................................៤៣
៣.៤.៣. លទ្ធផលនៃការជម្រះបញ្ជីក្រុមហ៊ុន........................................................................៤៣
**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ម.ក : គណៈកម្មការមូលបត្រកម្ពុជា

ផ.ម.ក : ក្រុមហ៊ុនផ្សារមូលបត្រ

PLC : Public Limited Company

CSA : ( Cash Settlement Agent ) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ពន្ធ័ នឹងមូលបត្រ

SF : ( Securities Firm ) ក្រុមហ៊ុនមូលបត្រ

CSO : ( Cash Settlement operator ) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ

CSX : ( Cambodia Securities Exchange ) ក្រុមហ៊ុនផ្សារមូលបត្រ

SECC : ( Security Exchange Committee in Cambodia ) គណៈកម្មការមូលបត្រ

NBC : ( National Bank of Cambodia ) ធនាគារជាតិនៃកម្ពុជា

CSD : ( Cash Settlement Depository ) ប្រតិបត្តិកររក្សាទុកមូលបត្រ

CMA : ( Client Money Account ) គណនីទូទាត់សាច់ប្រាក់អតិថិជន

# បញ្ជីពាក្យបច្ចេកទេស

- **ក្រុមហ៊ុនមមហាជនទទួលខុសត្រូវមានកម្រិត**: សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយមូលបត្រជាសាធារណៈ ។
- **ក្រុមហ៊ុនមូលបត្រ**: សំដៅដល់ក្រុមហ៊ុន ឬក្រុមហ៊ុនសហកម្មសិទ្ធិដែលទទួលបានអាជ្ញាប័ណ្ណ ដើម្បីធ្វើអាជីវកម្មមូលបត្រដោយស្របតាមច្បាប់នេះ។
- **ទីផ្សារមូលបត្រ**: សំដៅលើទីលើទីផ្សារ ឬកន្លែងជួញដូរមូលបត្រ ឬប្រពន្ធ័ដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬ ស្នើការទិញ លក់មូលបត្រ។
- **នីតិបុគ្គលប្រតិស្រុត**: សំដៅលើនីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេង។ នីតិបុគ្គលនេះមិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបង្កើតឡើងព្រះជារាណាចក្រកម្ពុជា។
- **មូលបត្រ** (ផ្អែកទៅតាមសន្ទានុក្រមរដ្ឋប្បវេណី) គឺជាប័ណ្ណដែលតំណាងឲ្យសិទ្ធិលើកម្មសិទ្ធិរបស់ម្ចាស់ប័ណ្ណទៅលើក្រុមហ៊ុន (ប័ណ្ណហ៊ុន) តំណាងឲ្យសិទ្ធិទំនាក់ទំនងផ្នែកគណទេយ្យរវាងម្ចាស់ប័ណ្ណនោះ និងក្រុមហ៊ុន ឬរដ្ឋាភិបាល (ឧ. ប័ណ្ណរតនាគារ) ឬតំណាងឲ្យសិទ្ធិផ្សេងៗទៀតទៅម្ចាស់ប័ណ្ណនោះ។ ចំណែកឯ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនពាក្យថា មូលបត្រសំដៅ ដល់មូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គល ផ្សេងៗ ដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រ កម្ពុជាដោយអនុលោមតាមច្បាប់។
- **អ្នកធ្វើបរិវិសកម្ម**

  គឺជាអ្នកចុះឈ្មោះសុំទិញមូលបត្រនៅពេញក្រុមហ៊ុនធ្វើសំណើលក់មូលបត្រជាសាធារណៈ។

# សេចក្តីផ្តើម

# សេចក្តីផ្តើម

**១. លំនាំបញ្ហានៃការស្រាវជ្រាវ**

នាពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាកំពុងព្យាយាមយ៉ាងខ្លាំងដើម្បីឲ្យចរន្តសេដ្ឋកិច្ចនៅក្នុងប្រទេសមានការរីកលូតលាស់ឡើង។ ការទាក់ទាញវិនិយោគគិនមកបណ្តាក់ទុន និងបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម គឺជាចំណុចសំខាន់បំផុតសម្រាប់ការបង្កើនសេដ្ឋកិច្ចកម្ពុជាឲ្យរីកចម្រើន។ ដូច្នេះហើយវិធីសាស្ត្រដែលរាជរដ្ឋាភិបាលបានខិតខំទាក់ទាញអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសនោះគឺការកែប្រែហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន រួមមានការរៀបចំ និងកសាងនូវប្រភពថាមពលផ្លូវ ថ្នល់ និងមូលដ្ឋានច្បាប់ដូចជា ច្បាប់បន្ធូរបន្ថយពន្ធដា ដើម្បីលើកទឹកចិត្តវិនិយោគគិន ព្រមទាំតាមដាននូវការលំបាករបស់វិនិយោគគិន និងជួយស្វែងរកដំណោះស្រាយ។

ប្រទេសកម្ពុជាបានបង្កើតច្បាប់គោលសម្រាប់គ្រប់គ្រងក្នុងវិស័យពាណិជ្ជកម្ម គឺច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងច្បាប់ផ្សេងទៀតដែលអនុម័តថ្មី។ ច្បាប់ទាំងនេះបានចែងពីប្រភេទនៃក្រុមហ៊ុនផ្សេងៗជាច្រើនដែលអ្នកវិនិយោគទុនអាចជ្រើសរើសក្នុងការបង្កើតតាមកម្រិតនៃដើមទុនរបស់ខ្លួន។ ដោយការសំឡឹងមើលឃើញនូវអត្ថប្រយោជន៍នៃការចូលរួមវិនិយោគពីវិស័យឯកជនក្នុងការបង្កើតក្រុមហ៊ុនក្នុងសារណានេះ នឹងធ្វើការបកស្រាយអំពីប្រភេទក្រុមហ៊ុនមួយដែលកំពុងទទួលបានការចាប់អារម្មណ៍ក៏ដូចជាមានការបណ្តាក់ទុនពីវិនិយោគគិនជាច្រើននោះគឺ **ក្រុមហ៊ុនហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**។

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ**

ចំណុចដែលនាងខ្ញុំបានលើកមកស្រាវជ្រាវ និងធ្វើការបកស្រាយដោយផ្អែកលើចំណោទបញ្ហាមួយចំនួនដែលទាក់ទងទៅក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ នាងខ្ញុំសូមលើកយកនូវចំណោទបញ្ហាមួយចំនួនដូចជា៖

- តើការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវការលក្ខខណ្ឌអ្វីខ្លះ ?
- តើក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតប្រព្រឹត្តទៅយ៉ាងដូចម្តេច ?
- តើការចុះបញ្ជីក្រុមហ៊ុននាពេលបច្ចុប្បន្នត្រូវធ្វើឡើងយ៉ាងដូចម្តេច ?
- តើក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតប្រតិបត្តិការទៅយ៉ាងដូចម្តេចខ្លះ ?

**៣. គោលបំណងនៃការស្រាវជ្រាវ**

គោលបំណងនៃការស្រាវជ្រាវប្រធានបទនេះគឺដើម្បីស្វែងយល់យ៉ាងច្បាស់ពីដំណើរការផ្សេងៗទាក់ទង

ទៅនឹងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ថាតើក្រុមហ៊ុនត្រូវបានបង្កើតឡើងក្រោមលក្ខខណ្ឌអ្វីខ្លះ? និងដំណើរការយ៉ាងដូចម្តេច?

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ការស្រាវជ្រាវទៅលើប្រធានបទនេះ នាងខ្ញុំបានធ្វើការសិក្សាទៅលើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម២០០៥ និងបទប្បញ្ញត្តិដទៃទៀត ដែលទាក់ទងទៅនឹងការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដែលទាក់ទងទៅនឹងការចុះបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រឯកជន។

**៥. សារៈសំខាន់នៃការស្រាវជ្រាវ**

ក្រោយពីបានធ្វើការស្រាវជ្រាវទៅលើប្រធានបទស្តីពី **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** ធ្វើឲ្យនាងខ្ញុំយល់ដឹងយ៉ាងច្រើនទាក់ទងទៅនឹងប្រភេទក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសគឺភាពលម្អិតដែលទាក់ទងទៅនឹងប្រធានបទ។ ប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់ចំពោះនិស្សិត និងប្រជាជនផ្សេងទៀតដែលមានបំណងចង់បង្កើតក្រុមហ៊ុន ឬចង់ចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធបច្ចេកវិទ្យា និងស្វែងយល់បន្ថែមទាក់ទងទៅនឹងទីផ្សារមូលបត្រ។

**៦. វិធីសាស្ត្រនៃការស្រាវជ្រាវ**

ចំពោះដំណើរការនៃការស្រាវជ្រាវ នាងខ្ញុំបានធ្វើការស្វែងរកឯកសារដែលពាក់ព័ន្ធនៅបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងនៅតាមបណ្ណាល័យផ្សេងៗទៀត។ លើសពីនេះទៅទៀតខ្ញុំទទួលបានការណែនាំពីលោកអ្នកគ្រូសាស្ត្រាចារ្យ ក្រសួងពាក់ព័ន្ធ និងតាមរយៈការស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណេត។ ការស្រាវជ្រាវប្រធានបទនេះពាក់ព័ន្ធទៅនឹងបទដ្ឋានគតិយុត្តមួយចំនួនដូចជា ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី ២០០៧ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ប្រកាស និងអនុក្រឹត្យផ្សេងៗទៀត។

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

មុននឹងឈានទៅដល់ការបកស្រាយប្រធានបទនេះ នាងខ្ញុំសូមធ្វើការប្រកាសប្លង់សារណាបញ្ចប់ការសិក្សានេះជាមុនសិន។ ប្លង់នៃសៀវភៅសារណាមួយក្បាលនេះចែកចេញជាបី ជំពូកធំៗះ

**ជំពូកទី១ ការបង្កើត ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**

**ជំពូកទី២ នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**

**ជំពូកទី៣ ប្រតិបត្តិការរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**

# ជំពូកទី១

# ការបង្កើត
# និងការប្រព្រឹត្តទៅនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

# ជំពូកទី១
# ការបង្កើត និងការប្រព្រឹត្តទៅនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

## ១.១ សញ្ញាណក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាទម្រង់មួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈ[1]។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតជាសហគ្រាសដែលបង្កើតដោយម្ចាស់ភាគហ៊ុនចាប់ពីពីរនាក់ឡើងទៅដោយមិនកំណត់ចំនួនអតិបរមានៃម្ចាស់ភាគហ៊ុនទេ។ ហើយម្ចាស់ភាគហ៊ុនមានការទទួលខុសត្រូវត្រឹមតែថ្លៃភាគហ៊ុន ដែលបានទិញក្នុងក្រុមហ៊ុនតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតអាចបោះលក់មូលបត្រជាសាធារណៈបានស្របតាមច្បាស់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ១.២. ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ដើម្បីបង្កើតក្រុមហ៊ុនមួយបាន នីតិបុគ្គលឬរូបវន្តបុគ្គលត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្ម និងស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួងនានា។ នីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬច្រើន ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទៅឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម[2]។ ចំណែកឯនាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវដាក់នាមពាក្យថា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ សរសេរអក្សរកាត់ដាក់ខាងចុងឬខាងក្រោម ម.ក ឬ ភីអិលស៊ី (PLC= PUBLIC LIMITED COMPANY)។

[1] មាត្រា៨៧ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[2] មាត្រា៩១ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតតម្រូវអោយបំពេញតាមលក្ខខណ្ឌពីរគឺ លក្ខខណ្ឌសុពលភាពនិងលក្ខខណ្ឌទម្រង់។

## ១.២.១.លក្ខខណ្ឌសុពលភាពនៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្នុងការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត លក្ខខណ្ឌសុពលភាពគឺជាលក្ខខណ្ឌចាំបាច់ដែលសមាជិកភាគហ៊ុនទាំងអស់ត្រូវតែបំពេញនិងគោរពតាម។ ដើម្បីអោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតអាចបង្កើតទៅបាន សមាជិកទាំងអស់ត្រូវតែមានការព្រមព្រៀងគ្នា និងត្រូវមានសមត្ថមានពេញលេញតាមផ្លូវច្បាប់ ហើយក៏ត្រូវមានកម្មវត្ថុច្បាស់លាស់នៃការបង្កើតក្រុមហ៊ុនផងដែរ។

### ១.២.១.១. ការព្រមព្រៀងរបស់សមាជិកភាគហ៊ុន

ការព្រមព្រៀងរបស់សមាជិកភាគហ៊ុនត្រូវស្តែងឡើងតាមឆន្ទៈពិតប្រាកដ ដោយសេរីពីសមាជិកទាំងអស់នៅក្នុងក្រុមហ៊ុន ត្រូវតែធ្វើឡើងប្រកបដោយភាពយុត្តិធម៌ សមធម៌រវាងគ្នានិងគ្នា និងត្រូវជៀសផុតពីអធម៌នៃការព្រមព្រៀង ឬការភាន់ច្រឡំលើបុគ្គលមិនអាចទាមទារធ្វើជាមូលហេតុនៃមោឃភាពនោះទេពីព្រោះក្រុមហ៊ុននេះ បង្កើតឡើងមិនមែនចាប់កំណើតលើការរាប់អានបុគ្គលនោះទេ។

### ១.២.១.២. សមត្ថភាពរបស់សមាជិកភាគហ៊ុន

ក្រុមហ៊ុនបង្កើតឡើងក្នុងគោលបំណងដើម្បីស្វែងរកប្រាក់ចំណេញ ដូច្នេះហើយសមាជិករបស់ក្រុមហ៊ុនត្រូវតែមានសមត្ថភាពពេញលេញតាមច្បាប់កំណត់ គ្មានករណីវិសមិត្តភាព និងការហាមឃាត់ដោយច្បាប់ឡើយ។ សមាជិកទាំងអស់មិនចាំបាច់មានលក្ខណៈសម្បត្តិជាពាណិជ្ជករនោះទេ គឺទាមទារមានសមត្ថភាពអាចបំពេញការងារស៊ីវិល។ ក្នុង ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អនីតិជនក៏មានសមត្ថភាពអាចចូលរួមជាសមាជិកភាគហ៊ុនដែរ តែត្រូវតែជាអនីតិជនដែលមានអត្តាធីនភាព[3]។

### ១.២.១.៣ កម្មវត្ថុនៃការបង្កើតក្រុមហ៊ុន

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានកម្មវត្ថុចម្បង គឺឆ្ពោះទៅរកការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

[3] មាត្រា២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដែលជាក្រុមហ៊ុនពាណិជ្ជកម្មមួយស្របតាមឆន្ទៈសមាជិកក្រុមហ៊ុនម្នាក់ៗត្រូវស្របតាមនយោបាយសាធារណៈស្របច្បាប់ ផលប្រយោជន៍របស់សមាជិកហ៊ុន។ ហើយម្យ៉ាងវិញទៀតកម្មវត្ថុរបស់ក្រុមហ៊ុនត្រូវតែស្របទៅនឹងច្បាប់ និងមិនផ្ទុយទៅនិងទំនៀមទម្លាប់ល្អរបស់ជាតិសណ្តាប់ធ្នាប់សាធារណៈ មានន័យថាក្រុមហ៊ុននោះមិនមែនបង្កើតឡើងក្នុងគោលបំណងខុសច្បាប់ដូចជាជួញដូរអាវុធខុសច្បាប់ ឬគ្រឿងញៀននោះទេ។ល។

## ១.២.២. ទម្រង់នៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ដើម្បីឲ្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដំណើរការទៅបានត្រូវតែបំពេញនូវទម្រង់មួយចំនួនផងដែរផងដែរ។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវតែបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងត្រូវតែប្រកាសជាសាធារណៈតាមលក្ខខណ្ឌច្បាប់ និងរៀបចំខ្លឹមសារលក្ខន្តិកៈអោយបានច្បាស់លាស់។

### ១.២.២.១. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវតែបង្កើតលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងជាលាយល័ក្ខណ៍អក្សរ តាមទម្រង់ជាលិខិតយថាភូត ដែលកំណត់អំពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមហ៊ុននីមួយៗ និងត្រូវបានតាក់តែងឲ្យបានសមស្របទៅនឹងទម្រង់របស់ក្រុមហ៊ុន និងច្បាស់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ លក្ខន្តិកៈដែលបានបង្កើតហើយត្រូវយកទៅតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។ ក្រុមហ៊ុនគឺអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន[4]។ បទបញ្ជាផ្ទៃក្នុងត្រូវបានអនុម័តដោយអភិបាលក្រុមហ៊ុនក្នុងប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។ បទបញ្ជាផ្ទៃក្នុងត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មក្រោយពេលចុះបញ្ជីហើយ។

សមាជិកទាំងអស់ត្រូវចុះហត្ថលេខាដោយសង្ខេបលើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងព្រមទាំងមានការបញ្ជាក់ពីភាពត្រឹមត្រូវរបស់អ្នកដឹកនាំក្រុមហ៊ុន និងប្រថាប់ត្រាទទួលស្គាល់ពីស្ថាប័នជាអាណាព្យាបាល ដែលគ្រប់គ្រងពីការចុះបញ្ជី (នាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម)។ ខ្លឹមសារនៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងត្រូវបញ្ចូលនូវចំណុចសំខាន់ៗនិងខសន្យាផ្សេងៗទៀតទៅតាមកលក្ខណៈជាក់ស្តែងរបស់ក្រុមហ៊ុន។

---

[4] មាត្រា១០២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥

**២.២.២.២. ខ្លឹមសារលក្ខន្តិកៈ**

ចំពោះខ្លឹមសារនៃលក្ខន្តិកៈរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានដូចតទៅ៖

**ក. ទ្រង់ទ្រាយក្រុមហ៊ុន**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈ។

**ខ. នាមករណ៍ក្រុមហ៊ុន**

នាមករណ៍ក្រុមហ៊ុនគឺជាឈ្មោះដើម្បីដាក់សម្គាល់ក្រុមហ៊ុន ឬហៅថា យីហោក្រុមហ៊ុន។ ក្រុមហ៊ុនទាំងអស់គឺត្រូវតែមាននាមករណ៍មួយជាដាច់ខាត។ ស្ថាបនិកក្រុមហ៊ុនអាចដាក់នាមករណ៍ក្រុមហ៊ុនរបស់ខ្លួនដោយសេរី ប៉ុន្តែនាមករណ៍នោះត្រូវតែឈរលើគោលការច្បាប់បានកំណត់ និងមិនត្រូវផ្ទុយនិងសណ្តាប់ធ្នាប់សាធារណៈ ហើយមានឈ្មោះអាស្រូវ និងមិនសមរម្យ។

ក្រុមហ៊ុនត្រូវប្រើនាមករណ៍ជាភាសាខ្មែរ ហើយត្រូវដាក់នៅជួរខាងលើបង្អស់ហើយត្រូវមានទំហំធំជាងអក្សរដទៃទៀត២(ពីរ)ដងប្រសិនបើមាន។ ការបកប្រែន័យរបស់នាមករណ៍ក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់។ នាមករណ៍ជាភាសាខ្មែរ និងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា[5]។ ក្រុមហ៊ុនត្រូវចារឹកជាភាសាខ្មែរនៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បែបបទឯកសារឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនអាចប្រើប្រាស់និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

ចំពោះនាមករណ៍ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវដាក់នាមពាក្យថា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ សរសេរអក្សរកាត់ដាក់ខាងចុងឬខាងក្រោម ម.ក ឬ ភីអិលសុី (PLC= PUBLIC LIMITED COMPANY)។ ឧទាហរណ៍៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាក់ ម.ក។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យនូវនាមករណ៍

[5] មាត្រា៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥

ដែលបានស្នើសុំដោយក្រុមហ៊ុននោះ ហើយអាចបដិសេធនូវនាមករណ៍ណាដែលប្រហាក់ប្រហែលគ្នាធ្វើឲ្យភាន់ច្រឡំទៅនឹងនាមករណ៍របស់ក្រុមហ៊ុនផ្សេងទៀត ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនរួចហើយ ឬ ដែលសមរម្យ។ សេចក្តីសម្រេចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មដែលពាន់ព័ន្ធទៅនឹងនាមករណ៍របស់ក្រុមហ៊ុនគឺជាសេចក្តីសម្រេចចុងក្រោយ[6]។

**គ. សញ្ជាតិក្រុមហ៊ុន**

ក្រុមហ៊ុនត្រូវមានតែមានសញ្ជាតិមួយច្បាស់លាស់ដែលជាការភ្ជាប់ទំនាក់ទំនងរវាងរដ្ឋ និងក្រុមហ៊ុន ។សញ្ជាតិរបស់ក្រុមហ៊ុនបង្ហាញថា ក្រុមហ៊ុននោះមានកាតព្វកិច្ច និងសិទ្ធិដែលរដ្ឋបានកំណត់ ហើយអាចទទួលបានការការពាររដ្ឋថែមទៀតផង។ ការកំណត់ផ្តល់សញ្ជាតិដល់ក្រុមហ៊ុន គឺជាសិទ្ធិរបស់រដ្ឋដោយក្រុមហ៊ុននោះត្រូវមានទីស្នាក់ការចុះបញ្ជីក្នុងប្រទេសនោះ។ ក្រុមហ៊ុនត្រូវចាត់ទុកថាមានសញ្ជាតិខ្មែរលុះត្រាតែ៖

ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១(ហាសិប១)% ត្រូវកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលមានសញ្ជាតិខ្មែរ ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម[7]។

**ឃ. ទីស្នាក់ការក្រុមហ៊ុន**

ទីស្នាក់ការក្រុមហ៊ុន គឺជាអាស័យដ្ឋានរបស់ក្រុមហ៊ុនដែលលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គ្រប់ពេលវេលា ក្រុមហ៊ុនត្រូវតែមានទីស្នាក់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបានបញ្ជាក់នៅក្នុងលក្ខន្តិកៈ[8]។ ក្រុមហ៊ុនត្រូវផ្តល់ឲ្យទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវសេចក្តីជូនដំណឹងអំពីទីតាំងទីស្នាក់ការចុះបញ្ជីជាមួយគ្នា និងលក្ខន្តិកៈដែលស្តីពីទីតាំង ឬពីការផ្លាស់ប្តូរទីតាំងស្នាក់ការចុះបញ្ជីនោះ។ លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរទីតាំងរបស់ទីស្នាក់ការចុះបញ្ជីត្រូវធ្វើទៅមន្ត្រីទទួលគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ១៥

[6] មាត្រា៩២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥

[7] មាត្រា១០១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០២២

[8] មាត្រា១០៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥

(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ
នោះ[9]។

**ខ. កម្មវត្ថុក្រុមហ៊ុន**

ក្រុមហ៊ុននីមួយៗមានកម្មវត្ថុនៃការធ្វើពាណិជ្ជកិច្ចផ្សេងៗពីគ្នា គោលដៅតែមួយគឺស្វែងរកប្រាក់ចំណេញ។ កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬច្រើនប្រភេទ ប៉ុន្តែកម្មវត្ថុទាំងអស់នោះត្រូវតែប្រព្រឹត្តិដោយស្របតាមបទប្បញ្ញត្តិច្បាប់ដែលបានកំណត់។

**ច. ថេរវេលា**

ថេរវេលាក្រុមហ៊ុន គឺជាដែនកំណត់នៃអាយុកាលរបស់ក្រុមហ៊ុនទៅតាមលក្ខខណ្ឌគតិយុត្ត។ ក្រុមហ៊ុនអាចជ្រើសរើសថេរវេលារបស់ខ្លួនឯងបាន ដោយក្រុមហ៊ុនខ្លះមានរយៈពេលវែង និងក្រុមហ៊ុនខ្លះមានរយៈពេលខ្លី ទៅតាមភាពជោគជ័យ និងការចង់រំលាយក្រុមហ៊ុនរបស់ខ្លួន។ ជាធម្មតាក្រុមហ៊ុនភាគច្រើនជ្រើសរយៈពេល
៩៩ឆ្នាំ សម្រាប់ប្រកបអាជីវកម្មរបស់ខ្លួន ហើយអាចសុំពន្យាថេរវេលាទៀតបានដោយធ្វើការជូនដំណឹងទៅក្រសួងពាណិជ្ជកម្ម។

### ២.២.២.៣. ដើមទុន និងភាគហ៊ុនរបស់ក្រុមហ៊ុន

ដើមទុន គឺជាកត្តាសំខាន់បំផុតក្នុងការបង្កើត និងដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ដើមទុន គឺជាការដាក់បញ្ចូលគ្នានូវភាគទុនជាសាច់ប្រាក់ ឬជាវត្ថុពីសមាជិកភាគហ៊ុនទាំងអស់ដែលបានចូលរួមក្នុងការបង្កើត។

**ក. ដើមទុនរបស់ក្រុមហ៊ុន**

ដើមទុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
គឺជាការដាក់បញ្ចូលគ្នានូវភាគហ៊ុនរបស់សមាជិកភាគហ៊ុននីមួយៗ។ ដើមទុនត្រូវប្រកាសជារូបិយវត្ថុ[10]។ ច្បាប់មិនបានកំណត់ច្បាស់លាស់ពីកម្រិតនៃដើមទុនរបស់ក្រុមហ៊ុនទេ

[9] មាត្រា១០៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥

[10] មាត្រា៩៣ ចំណុចឃ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥

ប៉ុន្តែគ្រាន់តែបានកំណត់ថាក្រុមហ៊ុននីតិបុគ្គលទទួលខុសត្រូវមានកម្រិតត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០០០០០០០ (ម្ភៃលាន) រៀល[11]។ បើយើងសង្កេតមើលតាមការជាក់ស្តែងភាគច្រើនក្រុមហ៊ុនប្រភេទនេះ មានដើមទុនអប្បបរមាចំនួន ១០០០០០០០០(មួយរយលាន)រៀល។ ប្រភេទដើមទុន គឺភាគទុនជាសាច់ប្រាក់ ឬទុនជាវត្ថុ និងជាចំណេះដឹង។

ភាគទុនជាសាច់ប្រាក់

ភាគទុនជាសាច់ប្រាក់ គឺជាភាគទុនដែលមានលក្ខណៈទូទៅ ហើយភាគទុននេះអាចបង់ជាដំណាក់ៗ ឬត្រូវបង់ទាំងស្រុងទៅតាមការកំណត់ច្បាស់លាស់មួយ។ ការកំណត់ពីការបង់ប្រាក់ គឺជាតួនាទីរបស់ក្រុមប្រឹក្សាភិបាល ហើយចំពោះការបង់បង្គ្រប់មិនត្រូវឲ្យលើសពី៣ឆ្នាំឡើយ បន្ទាប់ពីការចុះបញ្ជីពាណិជ្ជកម្ម។

ភាគទុនជាវត្ថុ

ភាគទុនជាវត្ថុ គឺជាការយកនូវវត្ថុអ្វីមួយមកដាក់ជាភាគទុន ដែលត្រូវអភិបាលទាំងឡាយជាអ្នកកំណត់ពីកម្មវត្ថុនោះ ហើយបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ ការសម្រេចរបស់អភិបាលទាំងឡាយនោះចាត់ទុកថាជាការបាន។ តែបើមិនដូច្នោះទេ ភាគទុនជាវត្ថុត្រូវមានការវាយតម្លៃចេញ ជាសាច់ប្រាក់ដោយសវនករ ហើយសវនករត្រូវជ្រើសរើសដោយក្រុមប្រឹក្សាភិបាលនៅក្នុងមហាសន្និបាតដំបូង ឬត្រូវបានជ្រើសរើសដោយតុលាការ។

**ខ. ភាគហ៊ុន**

ភាគហ៊ុន

គឺជាប្រភេទនៃមូលបត្រដែលអាចលក់ដូរបានក្នុងទីផ្សារភាគហ៊ុនដែលមានទៅតាមប្រភេទ ឬ ស៊េរី។ ភាគហ៊ុននីមួយៗត្រូវចុះបញ្ជីទៅតាមបែបបទដែលច្បាប់បានកំណត់។ ភាគហ៊ុននីមួយៗត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណនោះទេសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត

[11] មាត្រា៨៣ នៃក្រមរដ្ឋប្បវេណី ២០០៧

និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

**១.២.២.៣. ការផ្សព្វផ្សាយជាសាធារណៈ**

ការផ្សព្វផ្សាយជាសាធារណៈគឺជាលក្ខខណ្ឌទម្រង់មួយដែលត្រូវបំពេញជាដាច់ខាត។ ការផ្សព្វផ្សាយជាសាធារណៈធ្វើឡើងក្រោមរូបភាពដូចជា ការផ្សាយក្នុងសារព័ត៌មានស្របច្បាប់ ការតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្ម។

**ក. ការផ្សាយក្នុងសារព័ត៌មានស្របច្បាប់**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវចុះផ្សាយសម្រង់លិខិតបង្កើតក្រុមហ៊ុន ឬលក្ខន្តិកៈក្រុមហ៊ុនក្នុងសារព័ត៌មានជាសាធារណៈដោយស្របច្បាប់។ អ្នកដែលទទួលខុសត្រូវចំពោះការអនុវត្តនូវការ ផ្សព្វផ្សាយដែលតម្រូវដោយច្បាប់គឺជា ស្ថាបនិក ឬអភិបាលម្នាក់ៗ។

នៅក្នុងការផ្សព្វផ្សាយ ត្រូវមានចុះនិទ្ទេសសំខាន់ៗដូចជា ៖

- នាមករណ៍ក្រុមហ៊ុន
- ទ្រង់ទ្រាយក្រុមហ៊ុន
- កម្មវត្ថុអាជីវកម្មសង្ខេប
- អាសយដ្ឋានទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន
- ថិរវេលានៃក្រុមហ៊ុន
- ចំនួនដើមទុនជាសាច់ប្រាក់
- ចំនួនភាគហ៊ុន
- តម្លៃចារឹកលើប័ណ្ណភាគហ៊ុននីមួយៗ
- បើសិនជាមានភាគទុនជាសាច់ប្រាក់ផង និង ភាគទុនជាវត្ថុផង ត្រូវបញ្ជាក់ ៖
- ភាគទុនជាសាច់ប្រាក់មានចំនួន...
- ភាគទុនជាវត្ថុគិតតម្លៃជាសាច់ប្រាក់..
  (ពិពណ៌នាដោយសង្ខេបអំពីភាគទុនជាវត្ថុនេះ)
- នាមត្រកូល និងនាមខ្លួន មុខរបរ សញ្ជាតិ អាសយដ្ឋានរបស់អភិបាល

– ទីកន្លែងដែលក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្ម

ពាក្យសុំចុះផ្សាយសេចក្តីប្រកាសនេះដែលមានបញ្ជាក់ការយល់ព្រមទទួលចុះផ្សាយរបស់សារព័ត៌មាន ត្រូវបានរក្សាទុកយ៉ាងតិចពីរច្បាប់សម្រាប់ភ្ជាប់បំពេញជាមួយសំណុំលិខិតពេលដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម។

**ខ. ការតម្កល់ទុកនៅក្នុងក្រសួងពាណិជ្ជកម្ម**

រាល់ទម្រង់លិខិត និងឯកសារទាំងអស់ដែលទាក់ទងទៅនឹងការបង្កើតក្រុមហ៊ុនត្រូវយកទៅតម្កល់ទុកនៅនាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ដោយលេខាធិការរបស់ក្រុមហ៊ុននៅពេលដែលដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញលិខិតបញ្ជាក់មួយជាសម្គាល់ក្រោយពីបានយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុននិងក្រោយពីបានទទួលសោហ៊ុយនៃការតម្កល់នោះ។

**គ. ការចុះបញ្ជីពាណិជ្ជកម្ម**

គ្រប់ក្រុមហ៊ុនពាណិជ្ជកម្មទាំងអស់ ដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជាត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះជាបែបបទនៃការបង្កើត និងថេរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។ ជាពិសេសនោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។

ការចុះឈ្មោះនេះត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃក្រុមហ៊ុនក្នុងខែនៃការបង្កើតក្រុមហ៊ុន និង១៥ (ដប់ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម។

អ្នកស្នើសុំចុះឈ្មោះត្រូវផ្តល់ដល់ទីកន្លែងទទួលចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួន ២(ពីរ) ច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង។

ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គម្រូជននោះ ត្រូវចែងអំពី៖

១. នាមត្រកូល និងនាមខ្លួន ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ របស់សមាជិកក្រុមហ៊ុន

២. ផ្លាកសញ្ញាក្រុមហ៊ុន

៣. កម្មវត្ថុនៃក្រុមហ៊ុន

៤. ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើម មានសាខាឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា

៥. នាមសមាជិក ឬតតិយជន ដែលមានការអនុញ្ញាតឲ្យគ្រប់គ្រងចាត់ចែង និងចុះហត្ថលេខាជំនួសមុខក្រុមហ៊ុន ថ្ងៃ ខែ និងទីកន្លែងកំណើតរបស់អ្នកទាំងនោះ

៦. ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ឬវត្ថុមានតម្លៃដែលផ្ដល់ដោយសមាជិកភាគហ៊ុន

៧. ថ្ងៃ ខែ ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្ដើម និងបញ្ចប់ ។

៨. ទ្រង់ទ្រាយក្រុមហ៊ុន ។

៩. ហត្ថលេខាគំរូរបស់សមាជិក ឬតតិយជន ដូចមានចែងនៅចំណុចលេខ៥ នៃមាត្រា១៧ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

១០. លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ ។

១១. សេចក្ដីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពារពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ។

## ១.៣. ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

បន្ទាប់ពីរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មរួចហើយ ក្រុមហ៊ុននឹងដំណើរការអាជីវកម្មរបស់ខ្លួន។

ការដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដោយយកច្បាប់ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុនជាមាគានៃការដឹកនាំ។ ការដឹកនាំក្រុមហ៊ុនត្រូវមានអភិបាលដែលជាសមាជិកនៃក្រុមប្រឹក្សាភិបាលដែលជ្រើសតាំងដោយម្ចាស់ភាគហ៊ុន ដើម្បីធ្វើជាអ្នកគ្រប់គ្រងទូទៅលើរាល់ដំណើរការទាំងអស់នៃការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុន។

### ១.៣.១. ការគ្រប់គ្រង និងការត្រួតពិនិត្យក្រុមហ៊ុន

ដើម្បីធានាឲ្យបាននូវការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុន ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតមានអង្គការសំខាន់ៗសម្រាប់ត្រួតពិនិត្យ និងគ្រប់គ្រងលើរាល់ដំណើរការនៃការប្រព្រឹត្តទៅនេះ។

### ១.៣.១.១. ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលគឺជាបណ្តុំនៃអភិបាលដែលធ្វើសេចក្តីសម្រេចចិត្ត អំពីការគ្រប់គ្រងក្រុមហ៊ុន។ រូបវន្តបុគ្គលដែលមានសមត្ថភាព មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចកាន់កាប់មុខតំណែងជាអភិបាល ឬជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន។

#### ក. ការរើសតាំងសមាជិកក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវតែជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតរបស់ភាគហ៊ុនិក ដែលចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក[12]។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនត្រូវមានសមាជិកយ៉ាងតិចចំនួន ០៥(ប្រាំ) រូប និងមិនត្រូវលើសពី ១៥(ដប់ប្រាំ) រូបឡើយ[13]។

#### ខ. ការបោះឆ្នោតរើសតាំងប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សានៃក្រុមហ៊ុនមួយ ត្រូវដឹកនាំដោយប្រធានមួយរូប ហៅថាប្រធានក្រុមប្រឹក្សាភិបាល។ ប្រធានក្រុមប្រឹក្សាភិបាលត្រូវបោះឆ្នោតរើសតាំងពីក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាល ហើយអាចត្រូវបានដកហូតមុខតំណែងដោយសម្លេងភាគច្រើនដាច់ខាត របស់អភិបាលទាំងអស់ ប៉ុន្តែឋានៈជាអភិបាលត្រូវរក្សាទុកដដែល[14]។ អភិបាលម្នាក់ ត្រូវមានសម្លេងឆ្នោតតែមួយ។ អភិបាល ឬរូបវន្តបុគ្គលណាម្នាក់អាចធ្វើជាអាណត្តិគាហកៈឲ្យអភិបាលណាម្នាក់ផ្សេងទៀតបាន នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដោយមានលិខិតផ្ទេរសិទ្ធិចាលិខិតជាលាយលក្ខណ៍អក្សរពីអាណត្តិទាយក។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឲ្យលើសពីរយៈពេលមួយឆ្នាំនោះឡើយ។

#### គ. មុខងាររបស់ក្រុមប្រឹក្សាភិបាល

មុខងារចម្បងរបស់ក្រុមប្រឹក្សាភិបាល រួមមានដូចជា ៖

[12] ប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, លេខ ០០២ គ.ម.ក, ០៣ មីនា ២០១០, ប្រកា ១៣

[13] ប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, លេខ ០០២ គ.ម.ក, ០៣ មីនា ២០១០, ប្រកា ១៤

[14] មាត្រា ១២៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

- ជ្រើសរើស និងតែងតាំងបុគ្គលដែលនៅក្នុង ឬនៅក្រៅសមាសភាពរបស់ខ្លួនឱ្យមកបំពេញមុខងារជាអគ្គនាយក និងអគ្គនាយករងមួយរូប ឬច្រើនរូបជាជំនួយការប្រសិនបើចាំបាច់ ឬដកហូតងារមកវិញតាមការ ជាក់ស្តែង និងកំហុស។
- កោះអញ្ជើញសវនករ និង បញ្ឈប់គណនីប្រចាំឆ្នាំ។
- ពិនិត្យលើការគ្រប់គ្រងប្រចាំថ្ងៃរបស់អគ្គនាយក និង សរសេររបាយការណ៍ជាក្រុម។
- កោះអញ្ជើញ កំណត់របៀបវារៈប្រជុំ ដឹកនាំការប្រជុំមហាសន្និបាតសាមញ្ញ និងវិសាមញ្ញនៅទីស្នាក់ការក្រុមហ៊ុន ឬនៅទីកន្លែងផ្សេង។
- សិក្សាកំណត់ទិសដៅសកម្មភាពក្រុមហ៊ុន និងទទួលយកនូវសំណួរចាំបាច់សម្រាប់ដំណើរការក្រុមហ៊ុនឱ្យបានល្អ ស្របតាមកម្មវត្ថុរបស់ក្រុមហ៊ុន ។
- ផ្តល់យោបល់លើរបាយការណ៍អគ្គនាយកជុំវិញលើការជម្រះបញ្ជីប្រចាំឆ្នាំដើម្បីដាក់ជូនមហាសន្និបាតសាមញ្ញ ឬលើរបាយការណ៍ផ្សេងទៀត ជូនមហាសន្និបាតវិសាមញ្ញ។
- លើកសំណើរជូនមហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ ដើម្បីតែងតាំងអគ្គនាយកពិនិត្យមួយរូប ឬច្រើនរូបឱ្យទទួលរ៉ាប់រងការត្រួតពិនិត្យទូទៅប្រចាំឆ្នាំនៅផ្ទៃក្នុងក្រុមហ៊ុន ឬ ស្នើសុំក្រុមហ៊ុន ឬ ស្នើឱ្យដកហូតងារទៅវិញតាមការជាក់ស្តែង។

**ឃ. ការបញ្ចប់តួនាទីក្រុមប្រឹក្សាភិបាល**

ក្រុមអភិបាលអាចត្រូវបានបញ្ចប់តួនាទីដោយសារមូលហេតុមួយចំនួនដូចជា ការមកដល់នូវពេលវេលាដែលបានកំណត់ មរណភាព ការសុំលាលែង ការដកហូតងារ ឬការចោទប្រកាន់តាមបណ្តឹងតុលាការជាដើម។
ក្រុមប្រឹក្សាភិបាលអាចត្រូវដកហូតពីមុខតំណែងដោយសំឡេងភាគច្រើនដាច់ខាតរបស់អភិបាលទាំងឡាយប៉ុន្តែមិនត្រូវដកហូតពីឋានៈអភិបាលឡើយ។

**១.៣.១.២. អភិបាល**

**ក. ការតែងតាំងអភិបាល**

បណ្តាអភិបាល ត្រូវបានជ្រើសរើសតែងតាំងដោយមហាសន្និបាតបង្កើតក្រុមហ៊ុន ឬមហាសន្និបាតសាមញ្ញ។ រូបវន្តបុគ្គល ដែលមានសមត្ថភាពមានអាយុលើសពី ១៨ (ដប់ប្រាំបី) ឆ្នាំ

អាចតែងតាំងឲ្យបម្រើការងារជាអភិបាលបានដែរ។ ចំពោះអភិបាលម្នាក់ៗមានអាណត្តិ ២(ពីរ)ឆ្នាំ ប្រសិនបើមិនបានកំណត់នៅក្នុងលក្ខន្តិកៈទេ ហើយអាចត្រូវបានបោះឆ្នោតឲ្យសាជាថ្មី។

**ខ. តួនាទីរបស់អភិបាល**

អភិបាលមានតួនាទីដូចខាងក្រោម៖

- បង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ចំពោះមហាសន្និបាតប្រចាំឆ្នាំ
- បង្ហាញរបាយការណ៍របស់សវនករ
- បង្ហាញការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ចាត់ចែងការងារប្រចាំថ្ងៃ និងឲ្យស្របទៅនឹងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន។

**គ. សិទ្ធិរបស់អភិបាល**

សិទ្ធិរបស់អភិបាលមានដូចតទៅ៖

១. តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ ។

២. កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ ។

៣. កម្រិតប្រាក់បៀវត្ស ឬ ប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ហ៊ុនដើម្បីសុំសេចក្ដីសម្រេច ។

៤. ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាម ដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយនោះ ។

៥.ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬ លុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៦. ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬ រួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ។

៧. ស្នើសុំម្ចាស់ហ៊ុន ដើម្បីលក់ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ឬមួយភាគ ។

៨. ស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ។

៩. ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុនប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ ។

១០. ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

១១. ខ្ចីប្រាក់ ។

១២. បោះចេញ បោះចេញសាជាថ្មី ឬ លក់មូលបត្ររបស់ក្រុមហ៊ុន ។

១៣. ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន ។

១៤. ធ្វើអីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។

១៥.រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុននិងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន ។

**គ. ការបញ្ចប់តួនាទីរបស់អភិបាល**

អភិបាលអាចត្រូវបានបញ្ចប់តួនាទី ដោយសារ មរណភាព ការសុំលាលែង ការដកហូតងារ ឬការចោទប្រកាន់តាមបណ្តឹងតុលាការជាដើម។
ក្រុមប្រឹក្សាភិបាលអាចត្រូវចាត់តាំងបង្គ្រប់បណ្តោះអាសន្ននៅក្នុងខែបន្ទាប់ ឬក្នុងករណីចំនួនអភិបាលនៅសល់មិនតិចជាង ០៥ រូប។

ការចាត់តាំងនេះ នឹងត្រូវតែទទួលសច្ចាប័នពីមហាសន្និបាតសាមញ្ញលើកក្រោយនេះ។ បើចំនួនអភិបាលថយចុះមកតិចជាង ០៥រូប ក្រុមប្រឹក្សាភិបាលត្រូវកោះអញ្ជើញមហាសន្និបាតសាមញ្ញនៃម្ចាស់ភាគហ៊ុន នៅក្នុងខែបន្ទាប់ដូចគ្នាដើម្បីចាត់តាំងបង្គ្រប់ឡើងវិញ។ អភិបាលម្នាក់ៗ ក៏ដូចជាអ្នកដែលបានចូលរួមដទៃទៀតត្រូវរក្សាការសម្ងាត់យ៉ាងខ្ពស់ចំពោះព័ត៌មានទិន្នន័យ ឬ ឯកសារសំខាន់ដែលខ្លួនបានដឹង ឬ បានទទួលពីក្រុមប្រឹក្សាភិបាល។

**១.៣.១.៣. លេខាធិការរបស់ក្រុមហ៊ុន**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវមានលេខាធិការរបស់ក្រុមហ៊ុនដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លេខាធិការរបស់ក្រុមហ៊ុនត្រូវតែជារូបវន្តបុគ្គលដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងាររបស់ក្រុមហ៊ុន។ លេខាធិការរបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតផ្លូវការនិងឯកសារទាំងឡាយព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការ ក្នុងនាមក្រុមហ៊ុន។

ឯកសារនិងព័ត៌មានតម្រូវដោយច្បាប់ដែលត្រូវផ្តល់ទៅឲ្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវត្រូវប្រគល់ទៅឲ្យលេខាធិការរបស់ក្រុមហ៊ុននៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន លើកលែងតែតាមមធ្យោបាយណាផ្សេងដែលបានកំណត់ដោយច្បាប់។ លេខាធិការរបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកបញ្ជីគណនេយ្យ របស់ការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្ន ឲ្យបានទៀងទាត់ និងការពារឲ្យបានត្រឹមត្រូវ។

### ១.៣.១.៤. មហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន

មហាសន្និបាតម្ចាស់ភាគហ៊ុន គឺជាអង្គការដឹកនាំកំពូលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ មហាសន្និបាតម្ចាស់ភាគហ៊ុនត្រូវធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចដែលមានចែងក្នុងលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុង ឬតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ មហាសន្និបាតម្ចាស់ភាគហ៊ុនអាចធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន ប្រសិនបើមានការយល់ព្រមពីម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់។ មហាសន្និបាតនេះចែកចេញជាពីរប្រភេទគឺ មហាសន្និបាតវិសាមញ្ញ និងមហាសន្និបាតសាមញ្ញ។

#### ក. មហាសន្និបាតវិសាមញ្ញ

មហាសន្និបាតវិសាមញ្ញ(ពិសេស) គឺធ្វើឡើងនៅពេលដែលមានករណីពិសេសកើតឡើងនៅក្នុងក្រុមហ៊ុន។ ការធ្វើមហាសន្និបាតវិសាមញ្ញ ច្រើនតែសម្រេចទៅលើការកែប្រែក្រុមហ៊ុន មានដូចជាការកែប្រែលក្ខន្តិកៈ ការបន្ថែមឬបន្ថយដើមទុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជីក្រុមហ៊ុនជាដើម។ ការសម្រេចរបស់មហាសន្និបាតវិសាមញ្ញត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើន ២/៣(ពីរភាគ៣) ដែលបានចូលរួមក្នុងការបោះឆ្នោត។

#### ខ. មហាសន្និបាតសាមញ្ញ(ប្រចាំឆ្នាំ)

មហាសន្និបាតសាមញ្ញឬមហាសន្និបាតប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន ត្រូវធ្វើយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។ ការធ្វើមហាសន្និបាតនេះចាប់ផ្តើមធ្វើឡើងក្រោយពេលដែលក្រុមហ៊ុនបានបង្កើតឡើងជាផ្លូវការ។ មហាសន្និបាតនេះធ្វើឡើងដើម្បី

តែងតាំងឬដកហូតតំណែងរបស់ក្រុមប្រឹក្សាភិបាល អ្នកគ្រប់គ្រងក្រុមហ៊ុន និង សវនករ រួមទាំងការកែប្រែ និងការរំលាយក្រុមហ៊ុន។

### គ. ការដឹកនាំសន្និបាតរបស់ម្ចាស់ភាគហ៊ុន

អគ្គនាយកនៃក្រុមហ៊ុន ត្រូវធ្វើជាអធិបតីគ្រប់គ្រងសន្និបាតរបស់ម្ចាស់ភាគហ៊ុន។ នៅក្នុងមហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន ក្រុមប្រឹក្សា និងគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបង្ហាញរបាយការណ៍ប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន ដើម្បីធ្វើការសម្រេចយល់ព្រមឬមិនយល់ព្រម។

### ឃ. ការបោះឆ្នោតសម្រេចដោយម្ចាស់ភាគហ៊ុនក្នុងអង្គប្រជុំវិសាមញ្ញ

សមាជិកក្រុមប្រឹក្សាភិបាលមួយរូបៗ មានសម្លេងឆ្នោតមួយសម្លេង។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលធ្វើដោយអនុលោមទៅតាមលក្ខន្តិកៈ ត្រូវមានសម្លេងឆ្នោតគាំទ្រយ៉ាងហោចណាស់៥១ភាគរយ នៃក្រុមប្រឹក្សាភិបាលចូលរួមរាល់អង្គប្រជុំដែលមានក្វ៉រុមគ្រប់ចំនួន លើកលែងតែការសម្រេចដែលទាក់ទងទៅនឹងករណីដូចខាងក្រោមនេះ ដែលតម្រូវការសម្លេងឆ្នោតគាំទ្រយ៉ាងហោចណាស់ ២/៣ នៃសមាជិកក្រុមប្រឹក្សាភិបាលដែលកំពុងបម្រើការៈ

- ការកែប្រែប្រការ ឬខទាំងឡាយនៃលក្ខន្តិកៈ
- ការអនុម័តលើថវិកាប្រចាំឆ្នាំ ឬការផ្លាស់ប្តូរថវិកាប្រចាំឆ្នាំ ដែលមានអគ្គនាយកដាក់ជូននៅក្នុងនោះរាប់បញ្ចូលទាំងថវិកា ដែលបានចំណាយលើមូលធន។
- ការចំណាយលើមូលធនលើសពីថវិកា ដែលត្រូវបានអនុម័តពីដំបូងរួចមកហើយសម្រាប់សារពើពន្ធនោះ។
- ការតែងតាំង ឬ ដកហូតអគ្គនាយកក្រុមហ៊ុន។
- ការធ្វើប្រតិវេទន៍ ឬការទូទាត់ភាគលាភ ឬការបែងចែកទ្រព្យសកម្មផ្សេងៗទៅឱ្យម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន។
- ការរំលាយដោយស្ម័គ្រចិត្ត ឬ ជម្រះបញ្ជីក្រុមហ៊ុន
- ការអនុម័តលើការទូទាត់ភាគលាភរបស់ក្រុមហ៊ុន ត្រូវធ្វើទៅតាមគោលការណ៍ទាក់ទិនទៅនឹងការធ្វើប្រតិវេទន៍ និងការទូទាត់ភាគលាភរបស់ក្រុមហ៊ុន
- ការទិញហ៊ុនវិញ។

### ង. វិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន

កាលណាក្រុមហ៊ុនដែលមិនទាន់ចេញលក់ភាគហ៊ុននៅឡើយទេ ស្ថាបនិកក្រុមហ៊ុនអាចធ្វើវិសោនកម្មលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឬ ប្រសិនបើបានជ្រើសតាំងអភិបាលដំបូងហើយ ការធ្វើវិសោធនកម្មយកតាមសម្លេងភាគច្រើននៃអភិបាល។

សេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ស្តីពីសន្និបាតដើម្បីធ្វើវិសោធនកម្មលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រូវជូនដំណឹង២០(ម្ភៃ) ថ្ងៃមុនមហាសន្និបាត។ រាល់ឯកសារស្តីពីការធ្វើវិសោនកម្មលក្ខន្តិកៈក្រុមហ៊ុន ត្រូវបញ្ជាក់ច្បាស់ពីកាលបរិច្ឆេទការយល់ព្រមពីការបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុន។ រាល់ការធ្វើវិសោធកម្មត្រូវតម្កល់ទុកឯកសារនៅការិយាល័យក្រសួងពាណិជ្ជកម្ម ក្នុងអំឡុងពេល ២០(ម្ភៃ) ថ្ងៃ បន្ទាប់ពីក្រុមហ៊ុនបានអនុម័តហើយលើវិសោធនកម្មនោះ។

**១.៣.២. ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា**

ក្រុមហ៊ុនពីរ ឬច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមបញ្ចូលគ្នាជាក្រុមហ៊ុនថ្មីមួយ ទៀតផ្សេងបាន និងក្រុមហ៊ុនដែលរំលាយហៅថា ក្រុមហ៊ុនដើម ដោយក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថា ក្រុមហ៊ុនថ្មី។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា។ លើកលែងតែមានចែងផ្សេង ក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់។ កិច្ចព្រមព្រៀងនៃការ រំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី៖

- ចំណុចសំខាន់ៗ និងលក្ខខណ្ឌនៃការំលាយក្រុមហ៊ុនបញ្ចូលគ្នា
- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម
- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុន ដើមឱ្យទៅជាភាគហ៊ុនមូលបត្រ ផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម
- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬកម្មសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួលក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុន
ដើមមិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ

- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើង និងដើម្បីផ្តល់ដល់ការគ្រប់គ្រងព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម។

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ៖

- នៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃក្រោយកិច្ចព្រមព្រៀងនេះក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- ក្រុមហ៊ុនដើមនីមួយៗ ត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០ (ម្ភៃ)ថ្ងៃមុន។

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគ បី(២/៣) នៃក្រុមហ៊ុនដើមនីមួយៗ។

ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែកក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់និងដោយប្រយោលនូវសិទ្ធិឯកសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌនៃប្រភេទ ឬស៊េរីនៃភាគហ៊ុនផ្សេងៗ។ អំណាចបោះឆ្នោតដែលបង្កើតឡើងមិនអាចបដិសេធ ឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ។

នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ៖

- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេត្រូវចូលជាធរមាន
- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានក្លាយទៅជាកម្មសិទ្ធិក្រុមហ៊ុនថ្មីដែលត្រូវបន្តធ្វើអាជីវកម្ម
- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ

- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះនៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម

លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈសម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម។

# ជំពូកទី ២

# នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនម
# ហាទទួលខុសត្រូវមានកម្រិត

# ជំពូកទី២

# នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនមហាជនមានកម្រិត

ការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតមានពីរប្រភេទគឺ ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតានិងការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយយោងតាមអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មាត្រា២នៃ អនុក្រឹត្យនេះមានគោលដៅកំណត់នីតិវិធី លក្ខខណ្ឌតម្រូវ និងការអនុញ្ញាតដល់ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ នេះមានន័យថា ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតាលែងមានអានុភាពទៀតហើយ ហើយអភិបាលក្រុមហ៊ុនត្រូវចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិញ។

## ២.១. ការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យា

យោងតាមអនុក្រឹត្យស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលេខ៨៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០ បានកំណត់ថារាល់ការចុះបញ្ជីពាណិជ្ជកម្មត្រូវចុះតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ហើយការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះអនុវត្តតែចំពោះក្រុមហ៊ុន-សហគ្រាសថ្មីទាំងអស់ដែលទើប តែបង្កើតក្រោយអនុក្រឹត្យនេះបានអនុម័តត្រូវចូលតាមគេហទំព័រថ្មី https://www.registrationservices.gov.kh ដោយយោងទៅតាមសេចក្តីជូនដំណឹងស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។

ការចុះបញ្ជីអាជីវកម្មមួយអាចពាក់ព័ន្ធជាមួយក្រសួង-ស្ថាប័នច្រើន ប៉ុន្តែជាទូទៅក្រសួង-ស្ថាប័នគោលដែលពាក់ព័ន្ធរួមមានក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ដើម្បីដំណើរការអាជីវកម្មបានដោយស្របច្បាប់អ្នកដែលជាម្ចាស់អាជីវកម្មត្រូវចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម រួចបន្តចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយឡែកអាជីវកម្មមួយចំនួនត្រូវចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថានប័នដទៃបន្ថែមទៀតដែលអាចជាក្រសួងទេសចរណ៍( សម្រាប់ភោជនីយដ្ឋាន ) ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (សម្រាប់ក្រុមហ៊ុនសំណង់) និងក្រសួងសុខាភិបាល (សម្រាប់ឱសថស្ថាន ឬមន្ទី ពេទ្យ) ជាដើម។ តាមគោលការណ៍ចាស់ អភិបាលត្រូវទៅចុះបញ្ជីអាជីវកម្មរបស់ខ្លួននៅក្រសួង-ស្ថានប័នផ្សេងៗ គ្នា និងតាមនីតិវិធីខុសៗគ្នា។ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលវេលារង់ចាំច្រើនដង

ទម្រាំក្រសួង ស្ថាប័ននីមួយៗផ្តល់ការអនុញ្ញាត។ ចំណែកប្រព័ន្ធចុះបញ្ជីរបស់ក្រសួង-ស្ថាប័ននីមួយៗមានលក្ខណៈដាច់ដោយ ឡែកពីគ្នា និងមិនអាចផ្សារភ្ជាប់ ផ្លាស់ប្តូរទិន្នន័យគ្នាបាន ដែលតម្រូវឱ្យអ្នកបំពេញព័ត៌មានដដែលៗលើពាក្យស្នើ សុំផ្សេងគ្នានៅក្រសួង-ស្ថាប័នផ្សេងគ្នា។ សម្រាប់ការចុះបញ្ជីអាជីវកម្មតាមផ្ទាលបច្ចេកវិទ្យាព័ត៌មានថ្មីនេះ អ្នកអាចធ្វើការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសក្នុងពេលតែមួយបាននៅថ្នាលបច្ចេកវិទ្យាព័ត៌មានតែមួយ។ ដោយឡែកក្នុងដំណាក់កាលដំបូងនេះ ការចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថាប័នដទៃ ក្រៅពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ នឹងតម្រូវឱ្យអ្នកធ្វើតាមនីតិវិធីដដែលរបស់ក្រសួង-ស្ថាប័នសាមី។ តាមរយៈដំណើរការចុះបញ្ជីថ្មីនេះ ការចុះបញ្ជីអាជីវកម្មមួយអាច ចំណាយពេលយ៉ាងយូរ ០៨ថ្ងៃនៃថ្ងៃធ្វើការនិងត្រូវបង់សេវាតិចជាងមុន។ អភិបាលក៏អាចទូទាត់សងប្រាក់សេវាទាំងអស់ក្នុងការចុះបញ្ជីពាណិជ្ជកម្មតាមអនឡាញដោយប្រើប្រាស់សេវា ABA Pay សម្រាប់អតិថិជនធនាគារឌ្លនៈអាស៊ីចំកាត់ (ABA) និងតាមកាតឥណទាន ឬកាតឥណពន្ធសម្រាប់អតិថិជនធនាគារផ្សេងទៀត។ ក្រោយការចុះបញ្ជីពាណិជ្ជកម្មជោគជ័យអភិបាលនឹងទទួលបានអាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថល តាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។ ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មានគោលបំណង សម្រួល និងបង្កបរិយាកាសល្អដល់ការបង្កើតអាជីវកម្មតាមរយៈការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បី ចូលរួមចំណែកលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យប្រសើរឡើង និងទាក់ទាញការវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។

+ នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន




### ២.១.១. ការចុះបញ្ជីបង្កើត

ដើម្បីចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតតម្រូវឲ្យមានឯកសារដូចតទៅ៖

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃក្រោយពណ៌សរបស់អភិបាល ម្ចាស់ហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល)
- ឯកសារអត្តសញ្ញាណប័ណ្ណរបស់អភិបាល ម្ចាស់ហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល)
- លក្ខន្តិកៈក្រុមហ៊ុន
- ឯកសារយោង (អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ករណីម្ចាស់ហ៊ុនជានីតិបុគ្គល
    - លិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនមេ
    - វិញ្ញាបនបត្រក្រុមហ៊ុនមេ
    - លក្ខន្តិកៈក្រុមហ៊ុនមេ
- លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

រាល់ឯកសារភ្ជាប់ទាំងអស់ត្រូវស្កិតក្នុងទម្រង់ PDF រីឯរូបថតត្រូវស្កិតក្នុងទម្រង់JPG ឬJPEG ដែលស្កេន

ពីច្បាប់ដើម ហើយមានគុណភាពល្អ។ សូមបញ្ជាក់ថា ប្រសិនបើអភិបាលមិនផ្តល់ឯកសារ ឬព័ត៌មានមិនគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងពេលអភិបាលចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់យើង អាចនឹងប្រឈមការបដិសេធលើសំណើរចុះបញ្ជី។ ក្នុងករណីនេះ រាល់ការចំណាយដែលបានធ្វើឡើងលើប្រព័ន្ធនេះនឹងមិនមានការធានាចំពោះការប្រគល់ប្រាក់ជូនវិញនោះទេ។

- ដំណើរការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានចែកចេញជា ៦ជំហានធំៗ៖

| **ជំហានទី១** | **ជំហានទី២** | **ជំហានទី៣** |
|---|---|---|
| ការបង្កើតគណនីលើ CamDigikey App | ការ Log In ចូលទំព័រ Portal | ដំណើរការចុះបញ្ជី |

| **ជំហានទី៤** | **ជំហានទី៥** | **ជំហានទី៦** |
|---|---|---|
| ការទទួលបានអាជ្ញាបណ្ណ /វិញ្ញាបនបត្រឌីជីថល | ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់កាលនីមួយៗ | ការបង្កើតគណនីលើ CamDigikey App |

**ជំហានទី១៖** ការបង្កើតគណនីលើ CamDigikey App

CamDigiKey គឺជាកម្មវិធីទូរស័ព្ទសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈ QR Code របស់រាជរដ្ឋាភិបាលកម្ពុជា ដែលភ្ជាប់អ្នកប្រើប្រាស់ទៅសេវាកម្មរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា។

ការបង្កើតគណនី CamDigiKey App មានដំណើរការ ដូចជា៖

- ដោនឡូត CamDigiKey App ពី App Store ឬ Play Store លើទូរស័ព្ទដៃរបស់អ្នក។
- ចូលទៅកាន់ CamDigiKey App រួចចុចប៊ូតុង ចុះឈ្មោះ។
- បញ្ចូលលេខទូរស័ព្ទដៃរបស់អ្នកទៅក្នុង App នោះលេខកូដស្វ័យប្រវត្តិនឹងត្រូវបានផ្ញើទៅកាន់លេខទូរស័ព្ទដៃរបស់អ្នក។

- បង្កើតលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់។
- បំពេញព័ត៌មានអត្តសញ្ញាណរបស់អ្នក។
- បំពេញថ្ងៃខែឆ្នាំកំណើត ភេទ និងទីកន្លែងកំណើត។
- បំពេញអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។
- បំពេញព័ត៌មានអត្តសញ្ញាណប័ណ្ណ(សម្រាប់សញ្ជាតិខ្មែរ) ឬលិខិតឆ្លងដែន (សម្រាប់សញ្ជាតិបរទេស)។
- វាយលេខកូដមួយផ្សេងទៀតដែលបានផ្ញើទៅកាន់សារអេឡិចត្រូនិចរបស់អ្នកទៅក្នុង App ដើម្បីបញ្ជាក់សារអេឡិចត្រូនិចរបស់អ្នក។
- បញ្ចូលរូបថត អត្តសញ្ញាប័ណ្ណ ឬលិខិតឆ្លងដែនរបស់លោកអ្នក។
- ចុច "ថតរូប រួចថតរូបរបស់លោកអ្នក។
- រង់ចាំយ៉ាងយូរ ២៤ម៉ោងសម្រាប់ការត្រួតពិនិត្យ។
- អ្នកបានបង្កើតគណនី CamDigiKey ដោយជោគជ័យ។

**ជំហានទី២៖** ការ Log In ចូលទំព័រ Portal

- ចូលទៅតំណ www.registerationservices.gov.kh លើកុំព្យូទ័ររបស់អ្នក រួចចុចលើប៊ូតុង ចុះបញ្ជីពាណិជ្ជកម្ម នៅជ្រុងខាស្តាំផ្នែកខាងលើនៃគេហទំព័រ។
- ចុចប៊ូតុង ទាញយក QR Code ។
- ស្កេន QR Code ដែលអ្នកឃើញជាមួយនឹង CamDigikey App នៅលើទូរសព្ទរបស់អ្នក
- បញ្ចូលលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់ដែលអ្នកបានបង្កើតក្នុង CamDigikey App ទៅក្នុង CamDigikey App នោះអ្នកនឹងចូលទៅកាន់ទំព័រ Portal ចុះបញ្ជីពាណិជ្ជកម្មក្នុងកុំព្យូទ័រដោយស្វ័យប្រវត្តិ

**ជំហានទី៣៖** ដំណើរការចុះបញ្ជី

- ចុចប៊ូតុង ចុះបញ្ជីពាណិជ្ជកម្ម
- ជ្រើសរើសទម្រង់សហគ្រាសដែលសមស្របទៅនឹងសហគ្រាសរបស់អ្នក រួចបំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ ចុះបញ្ជីពាណិជ្ជកម្ម រួចចុច បន្ទាប់។
- បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ ចុះបញ្ជីពន្ធដារ រួចចុច បន្ទាប់។
- បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស រួចចុច បន្ទាប់។

- ពិនិត្យព័ត៌មាន និងឯកសារឡើងវិញ រួចចុចប៊ូតុង ដាក់ស្នើ។

**ជំហានទី៤៖** ការទទួលបានអាជ្ញាបណ្ណ/វិញ្ញាបនបត្រឌីជីថល

- ជ្រើសរើសជម្រើសទូទាត់សងប្រាក់មួយ ដែលក្នុងនោះមាន ABA Pay និងការទូទាត់តាមរយៈកាតឥណទាន ឬកាតឥណពន្ធ។
- ក្នុងករណីទូទាត់ប្រាក់តាម ABA Pay,

  អ្នកនឹងឃើញ QR Code នៅលើអេក្រង់កុំព្យូទ័រ។

  ចូលទៅកាន់ ABA Mobile App រួច log in គណនីធនាគារ ABA របស់អ្នកលើ ទូរស័ព្ទដៃ។

  ចុចប៊ូតុង ស្កេន QR" នៅលើ ABA Mobile App។

  ស្កេន QR Code ដែលបង្ហាញនៅលើអេក្រង់កុំព្យូទ័រជាមួយទូរស័ព្ទដៃ របស់អ្នក។

  ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។
- ក្នុងករណីទូទាត់សងប្រាក់តាមកាតឥណទាន ឬកាតឥណពន្ធ ( Visa, Master Card ឬ Union Pay International )

  បំពេញព័ត៌មានគណនីរបស់អ្នក រួចចុចប៊ូតុង ដាក់ស្នើ។

  ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។

**ជំហានទី៥៖** ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់កាលនីមួយៗ

- ពេល Log in ចូលទំព័រ Portal ចុច ក្រុមហ៊ុនរបស់ខ្ញុំ។
- ចុចលើក្រុមហ៊ុនណាមួយដែលអ្នកចង់តាមដានស្ថានភាពសំណើ នោះអ្នកនឹងឃើញមានការបញ្ជាក់ស្ថានភាពសំណើលម្អិត។

**ជំហានទី៦៖**ការទូរទាត់ប្រាក់

- នៅពេលដែលអ្នកឃើញព័ត៌មានអំពីស្ថានភាពលម្អិតរបស់ក្រុមហ៊ុនអ្នក សូមចុច ទាញយកនៅផ្នែកវិញ្ញាបនបត្រ។

### ២.១.២. ការចុះបញ្ជីកែប្រែ

ដោយយោងតាមសេចក្តីជូនដំណឹងស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចុះថ្ងៃទី១៥ ខែមិថុនាឆ្នាំ២០២០បានបញ្ជាក់ថាដោយឡែកចំពោះការតម្កល់ប្រតិវេទន៍ ការចុះបញ្ជីកែប្រែរបស់ក្រសួងពាណិជ្ជ កម្មនៅរក្សាប្រើប្រាស់ក្នុងគេហទំព័រ www.businessregistration.moc.gov.kh ដដែល។

ដើម្បីចុះបញ្ជីកែប្រែក្រុមហ៊ុន

អភិបាលក្រុមហ៊ុនឬសហគ្រាសត្រូវចូលទៅក្នុងគណនីរបស់ក្រសួងពាណិជ្ជ កម្ម www.businessregistration.moc.gov.kh ដដែលរួចចុចពាក្យថា Log On(ចូល) ដើម្បីបំពេញឈ្មោះអ្នកប្រើប្រាស់ និងលេខសម្ងាត់ដើម្បីចូលទៅក្នុងប្រព័ន្ធរបស់ក្រសួងក្នុងគោលបំណងផ្លាស់ប្តូរកែប្រែក្រុមហ៊ុន ឬសហគ្រាស។ ការចុះបញ្ជី កែប្រែក្រុមហ៊ុន ឬសហគ្រាសមានដូចជា៖

ការប្តូរនាមករណ៍ក្រុមហ៊ុន

ចំពោះអភិបាលក្រុមហ៊ុនដែលមានគោលបំណងផ្លាស់ប្តូរ និងកែប្រែក្រុមហ៊ុន ឬសហគ្រាស ក្រោយពេលបាន Log On(ចូល) ចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មរួចហើយមកអភិបាលក្រុមហ៊ុនត្រូវជ្រើសរើសក្រុមហ៊ុន ឬសហគ្រាសដែលខ្លួនមានបំណងផ្លាស់ប្តូរ និងកែប្រែ។ បន្ទាប់មកចុចពាក្យថា ប្តូរនាមករណ៍ក្រុមហ៊ុន ប្រសិនបើអភិបាលក្រុមហ៊ុនបានបម្រុងទុកនាមករណ៍រួចរាល់ហើយ សូមចុចប្រអប់ពីមុខពាក្យ ថា ជ្រើសរើសនាមករណ៍បម្រុងទុក ប៉ុន្តែប្រសិនបើអភិបាលក្រុមហ៊ុនពុំទាន់បានបម្រុងទុកនាមករណ៍ទេ ត្រូវ បំពេញនាមករណ៍ថ្មី។ នាមករណ៍ភាសាអង់គ្លេសត្រូវច្បាស់ថា វាបានបញ្ចប់ដោយពាក្យដែលបញ្ជាក់ពីប្រភេទ ក្រុមហ៊ុន (ឧទាហរណ៍៖ ACELEDA PLC) បន្ទាប់មកពាក្យថា សុពលភាពនាមករណ៍ រួចជ្រើសរើសកាល បរិច្ឆេទនៃសេចក្តីសម្រេច ហើយចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ចំពោះព័ត៌មានបន្ថែមស្តីពីឯកសារភ្ជាប់ សូមអានប្រកាសលេខ១៤២ ព.ណ.ច.ប.ព.ប្រ.ក ស្តីពីបែបបទ និងនីតិ វិធីចុះបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។ បន្ទាប់មកចុចពាក្យ រក្សាទុក និងចាកចេញ ប្រសិនបើមានចំណុចណាមួយដែលអភិបាលក្រុមហ៊ុនត្រូវធ្វើការពិចារណាហើយប្រព័ន្ធនឹងធ្វើការរក្សាទុកព័ត៌មានកំពុងស្នើសុំនេះរយៈពេល១៥ថ្ងៃ។ ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែ។ តម្លៃសេវាក្នុងការចុះបញ្ជីកែប្រែនាមករណ៍ អភិបាលក្រុមហ៊ុនត្រូវបង់ប្រាក់ចំនួន ២៤០.០០០ (ពីររយសែសិបពាន់) រៀល និងរយៈពេលអតិបរមានៃការផ្តល់សេវាមានចាប់ពី៣-៧ថ្ងៃ។

ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

អភិបាលក្រុមហ៊ុនត្រូវចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួង រួចចូលទៅក្នុងទំព័រមុខងារបង្ហាញព័ត៌មានលម្អិតក្រុមហ៊ុនក្នុងស្រុករួចបន្តអនុវត្តនិតិវិធីដូចខាងក្រោម៖

- ចុចពាក្យថា កែប្រែលក្ខន្តិកៈក្រុមហ៊ុន បន្ទាប់មកចុចពាក្យថា លុបឯកសារ
- បន្ទាប់មកចុចពាក្យថា បញ្ចូល នៅត្រង់ពាក្យថា អនុស្សារណៈ/លក្ខន្តិកៈ
- ជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច រួចចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចក្រុមប្រឹក្សាភិបាល
- សូមចុចប្រអប់ពីមុខពាក្យថា៖ ខ្ញុំសូមប្រកាសថាព័ត៌មានដែលបានបំពេញក្នុងសំណើនេះ និងឯកសារភ្ជាប់ទាំងអស់ពិតជាត្រឹមត្រូវពិតប្រាកដ។ ក្រសួងពាណិជ្ជកម្មអាចនឹងធ្វើការលុបសហគ្រាសពីបញ្ជីពាណិជ្ជកម្ម ប្រសិនបើមានការផ្តល់ព័ត៌មានមិនត្រឹមត្រូវ ឬក្លែងបន្លំ
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យថា ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម។ តម្លៃសេវាក្នុងការចុះបញ្ជីកែប្រែនាមករណ៍ អភិបាលក្រុមហ៊ុនត្រូវបង់ប្រាក់ចំនួន ២៤០.០០០ (ពីររយសែសិបពាន់)រៀល និងរយៈពេលអតិបរមានៃការផ្តល់សេវាមានចាប់ពី៣-៧ថ្ងៃ។

  ការកែប្រែសកម្មភាពអាជីវកម្ម

អភិបាលក្រុមហ៊ុនទាំងឡាយណា ដែលមានគោលបំណងក្នុងការកែប្រែសកម្មភាពអាជីវកម្មនៃក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- បន្ទាប់ពីអភិបាលក្រុមហ៊ុន ឬសហគ្រាសបានចូលទៅក្នុងប្រព័ន្ធរបស់ក្រសួងពាណិជ្ជកម្មរួចហើយអភិបាលក្រុមហ៊ុនត្រូវចូលប្រព័ន្ធក្នុងទំព័រសកម្មភាពអាជីវកម្មរួចចុចពាក្យថា កែប្រែសកម្មភាពអាជីវកម្ម
- ចុចប្រអប់ពីមុខពាក្យថា បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ ប្រសិនបើកម្មវត្ថុអាជីវកម្មដូច ឬប្រហាក់ប្រហែលនឹងកម្មវត្ថុអាជីវកម្មលើបណ្ណប៉ាតង់ បន្ទាប់មកចុចពាក្យថា បញ្ចូល
- បន្ទាប់មកចុចពាក្យថា លុបឯកសារ នៅត្រង់ពាក្យថា បណ្ណប៉ាតង់ ហើយបញ្ចូលជំនួសវិញនូវបណ្ណប៉ាតង់ថ្មី
- សូមចុចពាក្យថា ដកចេញ ប្រសិនបើចង់លុបកម្មវត្ថុអាជីវកម្មមួយចេញ
- សូមចុចពាក្យ បន្ថែមសកម្មភាពអាជីវកម្មចម្បង ប្រសិនបើចង់បន្ថែមកម្មវត្ថុអាជីវកម្មមួយទៀត សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចម្ចាស់ហ៊ុន

- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ តម្លៃសេវានៃការចុះបញ្ជីកែប្រែសកម្មភាពអាជីវកម្មអភិបាលក្រុមហ៊ុនត្រូវបង់ប្រាក់ចំនួន ២៤០,០០០ (ពីរសែនបួនម៉ឺន)រៀល និង រយៈពេលអតិបរមានៃការផ្តល់សេវាមានចាប់ពី៣-៧ថ្ងៃ។

ការបន្ថយដើមទុន

ការបន្ថយដើមទុនត្រូវធ្វើឡើងតាមនីតិវិធីដូចខាងក្រោម៖

- សូមចុចពាក្យ បន្ថយដើមទុន
- បន្ទាប់មកសូមចុចពាក្យថាបន្ថយតម្លៃចារឹកលើប័ណ្ណ ប៉ុន្តែមិនអាចបន្ថយឱ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយ
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យថា បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចម្ចាស់ហ៊ុន និងកំណត់ហេតុអង្គប្រជុំ
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេ វាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ អភិបាលក្រុមហ៊ុនត្រូវទូទាត់កម្រៃសេវាលើការបន្ថយដើមទុន ចំនួន ៨០០.០០០(ប្រាំបីរយពាន់)រៀល រយៈពេលអតិបរមានៃការផ្តល់សេវាចាប់ពី៣-៧ថ្ងៃ នៃថ្ងៃធ្វើការ។

អាសយដ្ឋាន

ប្រសិនបើអភិបាលក្រុមហ៊ុនមានបំណងចង់ធ្វើការកែប្រែអាសយដ្ឋានរបស់ក្រុមហ៊ុន ឬសហគ្រាស ត្រូវចុចពាក្យដូចខាងក្រោម៖

- សូមចុចពាក្យថា កែប្រែព័ត៌មានលម្អិតអាសយដ្ឋានទីស្នាក់ការចុះបញ្ជី
- សូមចុចពាក្យថា Change(ផ្លាស់ប្តូរ) ប្រសិនបើអភិបាលក្រុមហ៊ុនមានបំណងកែប្រែអាសយដ្ឋានទី ស្នាក់ការចុះបញ្ជី ឬអាសយដ្ឋានទីស្នាក់ការចុះបញ្ជីតាមប្រៃសណីយ៍
- បន្ទាប់មកបំពេញ អាសយដ្ឋានទីស្នាក់ការចុះបញ្ជីថ្មី
- សូមចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា ឯកសារបញ្ជាក់អាសយដ្ឋាន (ឯកសារទាំងនោះមានដូចជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ កម្មសិទ្ធិដីធ្លី កិច្ចសន្យាជួលផ្ទះ-អាគារ ឬវិក័យបត្រទឹក-ភ្លើង)
- សូមជ្រើសរើសកាលបរិច្ឆេទចាប់ផ្តើម
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយចុចពាក្យ យល់ព្រម
- សូមបំពេញ អ៊ីមែល និងលេខទូរស័ព្ទទំនាក់ទំនង ប្រសិនបើមានបំណងកែប្រែ

- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យបញ្ចូលនៅត្រង់ពាក្យថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយសូមចុចពាក្យ ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ ការទូទាត់កម្រៃលើការកែប្រែអាសយដ្ឋានមានចំនួន ២៤០.០០០ (ពីររយសែសិបពាន់)រៀល រយៈពេលអតិបរមានៃការផ្តល់សេវាចាប់ពី ៣-៧ថ្ងៃនៃថ្ងៃធ្វើការ។

ការកែប្រែព័ត៌មានលម្អិតអភិបាល

ក្នុងករណីដែលក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុនមានគោលបំណងដើម្បីធ្វើការកែប្រែព័ត៌មានលម្អិតអភិបាលត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- សូមជ្រើសរើសកាលបរិច្ឆេទឈប់ដំណើរការរបស់អភិបាល
- ដើម្បីបញ្ឈប់អភិបាលណាម្នាក់សូមចុចពាក្យ បញ្ឈប់អភិបាល
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ យល់ព្រម
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ យល់ព្រម
- សូមចុចពាក្យ កែតម្រូវ ប្រសិនបើមានបំណងកែប្រែព័ត៌មានលម្អិតអភិបាលឬធ្វើបច្ចុប្បន្នភាពលិខិតបញ្ជាក់អត្តសញ្ញាណ
- ដើម្បីបន្ថែមអភិបាលណាម្នាក់សូមចុចពាក្យ បន្ថែមអភិបាល
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចម្ចាស់ហ៊ុន និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- សូមចុចប្រអប់ពីមុខពាក្យថា ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសថាពុំមានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងពុំមែនជាមន្ត្រីរាជការក្នុងក្រសួងស្ថាប័នរដ្ឋណាមួយនៃព្រះរាជាណាចក្រកម្ពុជាឡើយ។
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យថា ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ ការទូទាត់តម្លៃចំពោះការផ្លាស់ប្តូរព័ត៌មានលម្អិតរបស់អភិបាលមានចំនួន ២៤០.០០០ (ពីររយសែសិបពាន់)រៀល រយៈពេលអតិបរមានៃការផ្តល់សេវាចាប់ពី៣-៧ថ្ងៃនៃថ្ងៃធ្វើការ។

ភាគហ៊ុន និងម្ចាស់ភាគហ៊ុន

ការផ្លាស់ប្តូរ ឬការកែប្រែព័ត៌មានទាក់ទងជាមួយនឹងភាគហ៊ុន និងម្ចាស់ភាគហ៊ុនត្រូវបានបែងចែកជា៣ប្រភេទគឺ៖ ការបង្កើនដើមទុន ការកែប្រែព័ត៌មានលម្អិតម្ចាស់ហ៊ុន ការផ្ទេរភាគហ៊ុន។

ការបង្កើនដើមទុន

ដើម្បីធ្វើការបង្កើនដើមទុន អភិបាលក្រុមហ៊ុនត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

- សូមចុចពាក្យថា កែប្រែម្ចាស់ហ៊ុន
- សូមចុចពាក្យថា បង្កើនដើមទុន
- បន្ទាប់មកចុចពាក្យ កែតម្រូវម្ចាស់ហ៊ុន
- យើងអាចបន្ថែមចំនួនភាគហ៊ុនថ្មីដើម្បីបង្កើនដើមទុនដោយរក្សាតម្លៃចារឹកលើប័ណ្ណនៅដដែល ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ រក្សាទុកម្ចាស់ហ៊ុន
- សូមចុចពាក្យ បន្ថែមម្ចាស់ហ៊ុន ប្រសិនបើមានបំណងបន្ថែមម្ចាស់ហ៊ុន ដោយបង្កើនចំនួនភាគហ៊ុន
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចម្ចាស់ហ៊ុន និងកំណត់ហេតុអង្គប្រជុំ - ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម។ ការទូទាត់កម្រៃនៃការបង្កើនដើមទុនមានចំនួន៨០០.០០០ (ប្រាំបីរយពាន់) រៀល រយៈពេលអតិបរមានៃការផ្តល់សេវាចាប់ពី៣-៧ថ្ងៃនៃថ្ងៃធ្វើការ។

ការកែប្រែព័ត៌មានលម្អិតម្ចាស់ហ៊ុន

- សូមចុចពាក្យ កែប្រែម្ចាស់ហ៊ុន-
- សូមចុចពាក្យ កែប្រែព័ត៌មានលម្អិតម្ចាស់ហ៊ុន
- សូមចុចពាក្យ កែតម្រូវម្ចាស់ហ៊ុន ប្រសិនបើមានបំណងកែប្រែព័ត៌មានម្ចាស់ហ៊ុន ឬធ្វើបច្ចុប្បន្នភាពលិខិតបញ្ជាក់អត្តសញ្ញាណ
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។

ការផ្ទេរភាគហ៊ុន

- សូមចុចពាក្យ កែប្រែម្ចាស់ហ៊ុន
- សូមចុចពាក្យ ផ្ទេរភាគហ៊ុន

- សូមជ្រើសរើសកាលបរិច្ឆេទឈប់ដំណើរការ
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ យល់ព្រម
- សូមចុចពាក្យ កែតម្រូវម្ចាស់ហ៊ុន ប្រសិនបើមានបំណងកែប្រែចំនួនភាគហ៊ុនរបស់ម្ចាស់ហ៊ុនណាម្នាក់
- សូមបំពេញចំនួនភាគហ៊ុនថ្មី បន្ទាប់ពីការផ្ទេរភាគហ៊ុនរបស់ម្ចាស់ហ៊ុនណាម្នាក់
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ រក្សាទុកម្ចាស់ហ៊ុន
- សូមចុចពាក្យ បន្ថែមម្ចាស់ហ៊ុន ប្រសិនបើមានបំណងបន្ថែមសមាជិកភាគហ៊ុន
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យ បញ្ចូល នៅត្រង់ពាក្យថា សេចក្តីសម្រេចម្ចាស់ហ៊ុន ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ ដាក់ស្នើ ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។
- ការទូទាត់កម្រៃនៃការផ្ទេរភាគហ៊ុនមានចំនួន ៨០០០០០ (ប្រាំបីរយពាន់)រៀល មានរយៈពេលអតិបរមានៃការផ្តល់សេវាចាប់ពី៣-៧ថ្ងៃនៃថ្ងៃធ្វើការ។

## ២.២. អានុភាពនៃការចុះបញ្ជី

### ២.២.១. ចំពោះការចុះបញ្ជីបង្កើត

ក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ចាប់ពីកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម។ មានន័យថា ក្រុមហ៊ុនត្រូវបានក្លាយជានីតិបុគ្គលស្របច្បាប់ ហើយធ្វើអាជីវកម្មដោយស្របច្បាប់ និងទទួលបានការការពារដោយច្បាប់នៅពេលមានជម្លោះ ឬក៏បញ្ហាណាមួយដែលកើតឡើងជាយថាហេតុ។ ហើយក្រុមហ៊ុននឹងមាន
សម្ថភាព សិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលដែរ ហើយអាចប្រកបពាណិជ្ជកម្មនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនអាចធ្វើពាណិជ្ជកិច្ចក្រៅប្រទេសបាន លុះត្រាតែប្រទេសនោះផ្តល់ការអនុញ្ញាត។

### ២.២.២. ចំពោះការចុះបញ្ជីកែប្រែ

ការចុះបញ្ជីកែប្រនាំឱ្យមានអានុភាពទៅលើ៖

- ការផ្លាស់ប្តូរនាមករណ៍ សហគ្រាស ឬក្រុមហ៊ុន
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន
- ការបែងចែកសាជាថ្មីនូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ

- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុនដែលមានរួចហើយ
- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតម្លៃចារឹកលើបណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលអនុញ្ញាត
- ការកែប្រែថិរវេលា នៃអត្ថិភាពរបស់ក្រុមហ៊ុន
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី
- ការកែប្រែចំនួនកូរ៉ុម
- បន្ថែមបទបញ្ញត្តិណាមួយ ដែលអនុញ្ញាតឱ្យដាក់បញ្ចូលនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន
- ការផ្ទេរ ឬលក់ភាគហ៊ុនទាំងឡាយដែលអនុញ្ញាតដោយច្បាប់

**២.២.៣. ចំពោះការចុះបញ្ជីរំលាយ**

ការចុះបញ្ជីរំលាយក្រុមហ៊ុននាំឲ្យមានអានុភាព ដូចខាងក្រោម៖

- មានការជម្រះបញ្ជី និងចែកចំណែក
- ក្រុមហ៊ុនត្រូវបានក្រសួងពាណិជ្ជកម្មលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម
- ក្រុមហ៊ុនលែងមានអត្ថិភាពជានីតិបុគ្គល
- សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់។

# ជំពូកទី៣
# ប្រតិបត្តិការរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

# ជំពូកទី៣

# ប្រតិបត្តិការរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ប្រតិបត្តិការចម្បងរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺ ការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ។ ការបោះផ្សាយមូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាការវិនិយោគមូលបត្រ។ ការធ្វើបែបនេះអាចជួយឲ្យក្រុមហ៊ុនរកដើមទុនបន្ថែមបានច្រើន និងពុំចាំបាច់កម្ចីពីធនាគារដែលមានអត្រាសម្រាប់យកការប្រាក់ខ្ពស់យកមកធ្វើការវិនិយោគលើអាជីវកម្មរបស់ខ្លួន។

## ៣.១. សំណើរលក់មូលបត្រ និងការបោះផ្សាយមូលបត្រ

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវបានធ្វើឡើងដោយក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនឯកជនដែលជាក្រុមហ៊ុនមហាជន និងនីតិបុគ្គលប្រតិស្រុត ដោយមានគោលបំណងបោះមូលបត្រលក់ជាសាធារណៈ ដើម្បីត្រូវការជំនួយហិរញ្ញវត្ថុឬសាច់ប្រាក់ និងជាទុនបន្ថែមក្នុងគោលបំណងពង្រីកអាជីវកម្មរបស់ខ្លួន តាមរយៈការបោះផ្សាយមូលបត្រកម្មសិទ្ធិ ឬមូលបត្របំណុល។ គ្មានបុគ្គលណាមួយបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពី គ.ម.ក ដោយអនុលោមតាមច្បាប់និងលក្ខខណ្ឌផ្សេងៗដែលកំណត់ដោយ គ.ម.ក។ បុគ្គលនោះត្រូវបង់ថ្លៃសេវានៃការដាក់ពាក្យស្នើសុំដែលកំណត់ឡើងស្របតាមច្បាប់នេះ។[15]

### ៣.១.១. ការពិនិត្យលើពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ

អគ្គនាយកនៃ គ.ម.ក ត្រូវពិនិត្យរាល់ពាក្យស្នើសុំ និងជូនដំណឹងដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំនោះអំពីភាពសមស្រប ឬមិនសមស្របនៃសំណើនោះជាមួយនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលយ៉ាងយូរ ៣(បី) ខែគិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ។[16]

---

[15] មាត្រា១២ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ២០០៧

[16] មាត្រា១៣ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ២០០៧

ត្រូវចាត់សំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសំណើបោះផ្សាយលក់មូលបត្រអញ្ញត្រកម្ម សម្រាប់គោលបំណងនៃជំពូកទី៣ នៃច្បាប់ប្រសិនបើសំណើនោះជា៖

១. សំណើបោះផ្សាយលក់មូលបត្រ ដែលត្រូវបានធានាដោយរាជរដ្ឋាភិបាលកម្ពុជា។

២. សំណើបោះផ្សាយលក់មូលបត្រ ដែលត្រូវបានដាក់តម្លៃសម្រាប់ការជួញដូរក្នុងដំណើរការជួញដូរធម្មតា នៅក្នុងទីផ្សារមូលបត្រ។

៣. សំណើបោះផ្សាយលក់មូលបត្រផ្សេងទៀត ដែលកំណត់ដោយ គ.ម.ក។[17]

### ៣.១.២. លក្ខខណ្ឌនៃពាក្យស្នើរសុំបោះផ្សាយ និងលក់មូលបត្រ

ដើម្បីសម្រេចថា ពាក្យស្នើសុំមួយមានភាពសមស្រប ឬមិនសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា អគ្គនាយកនៃ គ.ម.ក ត្រូវតែពិចារណាលើ៖

១. គុណភាពនៃអភិបាលកិច្ច និងប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

២. តម្រូវការរបស់ទីផ្សារមូលបត្ររួមទាំងតម្រូវការដើម្បីអភិវឌ្ឍទីផ្សារមូលបត្រ។

៣. កត្តាជោគជ័យនៃសំណើបោះផ្សាយនិងលក់មូលបត្រជាសាធារណៈរួមទាំងអត្ថិភាពនៃកិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញដែលនឹងធានាថារាល់មូលបត្រទាំងអស់ដែលប្រកាសលក់ក្នុងក្របខណ្ឌនៃសំណើលក់ជាសាធារណៈនោះអាចបោះផ្សាយបាន ឬអាចលក់អស់។

៤. លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីដើម្បីលក់នៅទីផ្សារមូលបត្រ។

៥. លក្ខខណ្ឌផ្សេងៗតម្រូវក្នុងការផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានឲ្យស្របតាមជំពូកនេះ។

៦. បញ្ហាផ្សេងៗទៀតដែលអគ្គនាយកនៃ គ.ម.ក ពិនិត្យឃើញថាមានលក្ខណៈសមស្របក្នុងការការពារផលប្រយោជន៍សាធារណៈ។[18]

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់

[17] មាត្រា៦ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ២០០៩

[18] មាត្រា១៤ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ ២០០៧

មូលបត្រជាសាធារណៈ ត្រូវដាក់សំណើសុំការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. ដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

១. ទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុតអនុញ្ញាតឲ្យចុះបញ្ជីលក់មូលបត្រ។

២.ទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុត លើការដាក់តម្លៃមូលបត្រដែលធ្វើសំណើលក់។

៣. ក្រោយពីបានបំពេញតាមលក្ខខណ្ឌ ដែលមានចែងក្នុងចំណុចទី១ និងទី២ នៃមាត្រានេះ ក្រុមហ៊ុនបោះផ្សាយ ឬនីតិបុគ្គលប្រតិស្រុត ត្រូវបោះផ្សាយលក់មូលបត្រក្នុងរយៈពេលមិនលើសពី ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលឯកសារផ្តល់ព័ត៌មានបានចុះបញ្ជីនៅ គ.ម.ក.។ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនផុតរយៈពេល ០៦ (ប្រាំមួយ) ខែនេះ ក្រុមហ៊ុនបោះផ្សាយ ឬនីតិបុគ្គលប្រតិស្រុត អាចស្នើសុំពន្យារពេលការបោះផ្សាយលក់មូលបត្រពីអគ្គនាយកនៃ គ.ម.ក.។

៤. ក្នុងរយៈពេលធ្វើបរិវិសកម្ម ប្រសិនបើមានឯកសារផ្តល់ព័ត៌មានបន្ថែម ដែលតម្រូវឲ្យមានការអនុញ្ញាត និងចុះបញ្ជីពាក់ព័ន្ធនឹងសំណើលក់មូលបត្រ បុគ្គលដែលធ្វើសំណើលក់ជាសាធារណៈ ត្រូវ៖

ក. ផ្តល់ឯកសារផ្តល់ព័ត៌មានបន្ថែម ដែលអនុញ្ញាត និងចុះបញ្ជីរួច តាមទម្រង់ដែលកំណត់ដោយ គ.ម.ក. ជូនទៅអ្នកធ្វើបរិវិសកម្ម ចំពោះសំណើលក់មូលបត្រនិង អ្នកវិនិយោគសាធារណៈដទៃទៀតដែលទទួលបាននូវសំណើលក់មូលបត្រ ជាសាធារណៈនោះ បន្ទាប់ពីឯកសារផ្តល់ព័ត៌មានបន្ថែមនោះត្រូវបានចុះ
បញ្ជី។

ខ. ជូនដំណឹងដល់អ្នកធ្វើបរិវិសកម្ម ចំពោះសំណើលក់មូលបត្រនោះថាអ្នកធ្វើបរិវិសកម្មអាចមានសិទ្ធិដកស្វីការ ដែលបានធ្វើចំពោះសំណើលក់សាធារណៈនិងអាចទទួលប្រាក់ ដែលបានបង់នោះមកវិញបាន។

៥. លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយ គ.ម.ក. ។[19]

### ៣.១.៣. ការយល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ

ប្រសិនបើ គ.ម.ក យល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ ដែលដាក់ជូន បុគ្គលដេលធ្វើសំណើនោះអាចចាប់ផ្តើមធ្វើសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈ

[19] មាត្រា៧ អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ២០០៩

ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយមូលបត្រមហាជន។[20] លើកលែងតែមានការកំណត់ដោយឡែកពី គ.ម.ក. ការទូទាត់សងថ្លៃមូលបត្រដែលបានដាក់លក់ស្របតាមសំណើលក់មូលបត្រជាសាធារណៈ ដោយអនុលោមទៅតាមច្បាប់ និងអនុក្រឹត្យនេះត្រូវទូទាត់ជាសាច់ប្រាក់ ឬឧបករណ៍ទូទាត់ផ្សេងទៀតដូចជា មូលប្បទានបត្រ និងឧបករណ៍ ឥណទាន ដូចជារូបិយាណត្តិ បណ្ណសងតាមបញ្ជា និងបណ្ណឥណទាន។

### ៣.១.៤. ការដាក់លក់មូលបត្រជាសាធារណៈ

គ្មានបុគ្គលណាមួយធ្វើសំណើលក់មូលបត្រជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេលើក លែងតែសំណើលក់នេះ ធ្វើឡើងដោយគោរពតាមលក្ខខណ្ឌខាងក្រោម៖

១. មូលបត្រដែលធ្វើសំណើលក់នោះ ត្រូវបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដោយនីតិបុគ្គលប្រតិស្រុត ដែលត្រូវបានកំណត់ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

២. រាល់លក្ខខណ្ឌនៃការស្នើសុំលក់ និងឯកសារផ្តល់ព័ត៌មានដែលត្រូវបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌដទៃទៀតដែលត្រូវបានកំណត់ស្របតាមច្បាប់នេះ ត្រូវតែទទួលបានការអនុញ្ញាតជាមុនពី អគ្គនាយកនៃ គ.ម.ក. លើកលែងតែការដាក់លក់នោះ គឺជាការដាក់លក់មូលបត្រអញ្ញត្រកម្មដូចមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់នេះ។ ចំពោះឯកសារផ្តល់ព័ត៌មានត្រូវតែចុះបញ្ជីនៅ គ.ម.ក.។[21]

ឯកសារផ្តល់ព័ត៌មានដែលដាក់ស្នើសុំការអនុញ្ញាត និងចុះបញ្ជីនៅ គ.ម.ក. ត្រូវតែជា៖

១. ជាឯកសារលាយលក្ខណ៍អក្សរ។

២. មានកាលបរិច្ឆេទត្រឹមត្រូវ។

៣. កំណត់លក្ខខណ្ឌពាក់ព័ន្ធនឹងសំណើបោះផ្សាយលក់មូលបត្រ ជាសាធារណៈរួមទាំងលក្ខខណ្ឌផ្សេងទៀត ដោយពិពណ៌នាឲ្យបានខ្លី គ្រប់គ្រាន់ និងច្បាស់លាស់។ ប្រសិនបើលក្ខខណ្ឌទាំងនេះមិនបានបំពេញ ការបោះផ្សាយលក់មូលបត្រជាសាធារណៈមិនទាន់អាចប្រព្រឹត្តទៅបានទេ។

---

[20] មាត្រា១៥ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ ២០០៧

[21] មាត្រា១៦ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ ២០០៧

៤. មានព័ត៌មានគ្រប់គ្រាន់ ដើម្បីឲ្យសាធារណជននិងទីប្រឹក្សាវិនិយោគធ្វើការវាយតម្លៃដោយផ្អែកលើព័ត៌មានច្បាស់លាស់អំពីសិទ្ធិ និងការតព្វកិច្ចដែលភ្ជាប់និងមូលបត្រដែលបានធ្វើសំណើលក់នោះ ព្រមទាំងវាយតម្លៃទ្រព្យសកម្ម បំណុល ស្ថានភាពហិរញ្ញវត្ថុចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រដែលបានបោះផ្សាយឬនឹងបោះផ្សាយលក់មូលបត្រជាសាធារណៈ។

៥. មានគ្រប់ព័ត៌មាននិងឯកសារភ្ជាប់ផ្សេងទៀត ព្រមទាំងទម្រង់នៃឯកសារផ្តល់ព័ត៌មានដែលកំណត់ដោយ គ.ម.ក.។

៦. មានការយល់ព្រមពីអ្នកជំនាញ ប្រសិនបើសេចក្តីថ្លែង សម្រង់ ឬយោងលើសេចក្តីថ្លែងដែលត្រូវដាក់បញ្ចូលទៅក្នុងឯកសារផ្តល់ព័ត៌មានជាសេចក្តីថ្លែងរបស់អ្នកជំនាញនោះ។

៧. មានចុះហត្ថលេខាដោយសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូបរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រនៅលើឯកសារផ្តល់ព័ត៌មានដែលត្រូវដាក់ ដើម្បីសុំការអនុញ្ញាតនិងចុះបញ្ជីនៅ គ.ម.ក.។ សមាជិកក្រុមប្រឹក្សាភិបាលអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអ្នកតំណាងរបស់ខ្លួន ដើម្បីចុះហត្ថលេខាជំនួស។[22]

## ៣.២. ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ។

### ៣.២.១. ពាក្យស្នើសុំពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម មក ផ.ម.ក. ៖

១-ព័ត៌មានទូទៅ៖

ក-ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងអក្សរឡាតាំង។

ខ-អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

គ-កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ឃ-កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

---

[22] **មាត្រា៩** នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ ២០០៩

ង-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

ច-លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២-ព័ត៌មានអំពីបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ៖

អត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

៣-ព័ត៌មានអំពីភាគហ៊ុនិក អត្តសញ្ញាណភាគហ៊ុនិក។

៤-ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ខ- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ។

គ- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។

ឃ-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៥-ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច។

ខ- ព័ត៌មានអំពីហានិភ័យ។

៦- ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧-ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។[23]

### ៣.២.២. ការអនុញ្ញាតលើលទ្ធភាពអាចចុះបញ្ជី

ជ.ម.ក. ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រទៅបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ១ (មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។

ករណី ជ.ម.ក. បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ជ.ម.ក. ត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលស្នើសុំ

[23] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តនីតិវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក./ប្រ.ក., ១០ កញ្ញា ឆ្នាំ២០១៥, ប្រការ ៤

ចុះបញ្ជីលក់មូលបត្រអាចស្នើសុំការបំភ្លឺពី ផ.ម.ក.។ បុគ្គលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក គ.ម.ក. ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេច។[24]

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលទទួលបានការអនុញ្ញាតលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ផ្ញើមូលបត្រដែលមានស្រាប់នៅប្រតិបត្តិកររក្សាទុកមូលបត្រ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពី
គ.ម.ក. លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងមុនដំណើរការនៃការ កំណត់ថ្លៃលក់មូលបត្រ ។

## ៣.៣. យន្តការបោះផ្សាយមូលបត្រកម្មសិទ្ធិសាធារណៈ

ដើម្បីសម្របសម្រួលដល់ការយល់ដឹង ធានាឲ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការ

នៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ
គ.ម.កបានធ្វើការណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលរួមមាន១២ចំណុច[25]៖

### ៣.៣.១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយមូលបត្រជាសាធរណៈទៅគ.ម.ក

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក គ.ម.ក ដែលលិខិតមានខ្លឹមសារ ០៣ ចំណុចៈ

- គោលការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ( Purpose of IPO )
- គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ( Expected Timetable )
- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលរំពឹងទុករួម( Expected IPO Team ) មាន ក្រុមហ៊ុនធានាទិញលក់មូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬ ក្រុមមេធាវី ឬ ក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

### ៣.៣.២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

[24] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តិវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក./ប្រ.ក., ១០ កញ្ញា ឆ្នាំ២០១៥, ប្រការ ៥

[25] គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង, លេខ០០១ គ.ម.ក/គ.ណ.ន, ៨ កញ្ញា ២០១១

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានា ទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក។ ដើម្បីកំណត់ឲ្យដឹងថាតើមានក្រុមហ៊ុនប៉ុន្មាន ហើយក្រុមហ៊ុនណាខ្លះមានបំណងចង់ក្លាយជាម្ចាស់ភាគហ៊ុនក្រោយពេលទិញមូលបត្រ ពីព្រោះធ្វើយ៉ាងណាឲ្យមានការចូលរួមប្រកួតប្រជែងក្នុងការទិញមូលបត្រនៅក្រោយពេលការដាក់លក់ភាគហ៊ុនជាសាធារណៈ និងដើម្បីធានាដល់តម្លៃហ៊ុនកុំឲ្យមានតម្លៃទាប។

### ៣.៣.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុម- ហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬ ក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូល បត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

### ៣.៣.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យ ជំនាញមេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

### ៣.៣.៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធាន ចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារ មូលបត្រកម្ពុជា។ ការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្ពុជាទើបអាចបោះផ្សាយនិងលក់មូលបត្របាន។

**៣.៣.៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនិងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក**

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូល
បត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។

**៣.៣.៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង** ( Book Building )

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**៣.៣.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាពី ផ.ម.ក**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបតេបាន ដោយឈរលើមលដានវិធានរបតិបតិការដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ

មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**៣.៣.៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើរលក់ និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្ម

ឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតាបញ្ជាក់ការដាក់តម្លៃ មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន គ.ម.ក ដើម្បីទទួលបានការអនុញ្ញាត និងធ្វើចុះបញ្ជី។

**៣.៣.១០. ការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ ព័ត៌មានពី គ.ម.ក រួច ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និង ជំពូក ទី៤ នៃប្រកាសស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ។

**៣.៣.១១. ការរាយការណ៍ពីលទ្ធផលនៃបរិវិសកម្មមូលបត្រ**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះ ភ្លាមជូនគ.ម.ក។

**៣.៣.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវបំពេញបែបបទនៅ ផ.ម.ក ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ។

**៣.៣.១២.១. ការដាក់ពាក្យចុះបញ្ជីជាផ្លូវការ**

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារ ដូចខាងក្រោម៖

១-ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ គ.ម.ក.។

២-ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។

៣-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

៤-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

៥-របាយការណ៍បែងចែកមូលបត្រ។

៦- លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។[26]

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវនិងពេញលេញដូចមានចែងក្នុងប្រការ១០ នៃវិធានខាងលើនេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។[27]

### ៣.៣.១២.២. ការផ្តល់ការអនុញ្ញាតនៃការចុះបញ្ជី

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវនិងពេញលេញដូចមានចែងក្នុងប្រការ១០ នៃវិធានខាងលើនេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ ក្រោយពទទួលបានការអនុញ្ញាតពី ផ.ម.ក. ហើយ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ
អាចធ្វើការជួញដូរមូលបត្រជាផ្លូវការរបស់ខ្លួនបាននៅក្នុងទីផ្សារមូលបត្រកម្ពុជា។

## ៣.៤. ការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មានមូលហេតុជាច្រើនដូចជា៖

- ការមកដល់ពេលវេលានៃកិច្ចសន្យាក្រុមហ៊ុន
- ការសម្រេចនូវកម្មវត្ថុរបស់ក្រុមហ៊ុន
- ការរំលាយដោយសមាជិកជាអ្នកប្តឹង

[26] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក/ប្រ.ក., ១០ កញ្ញា ២០១៥, ប្រការ ១០

[27] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក/ប្រ.ក., ១០ កញ្ញា ២០១៥, ប្រការ ១១

- ម្ចាស់ប័ណ្ណបំណុលអាចប្ដឹងរំលាយក្រុមហ៊ុន ក្នុងករណីមិនមានលទ្ធភាពសង
- រំលាយដោយអំណាចតុលាការ ក្នុងករណីក្រុមហ៊ុនធ្វើខុសច្បាប់
- ចំនួនសមាជិកថយចុះជាងពីរនាក់
- ការខាតបង់ច្រើនជាង៣/៤(បីភាគបួន) នៃដើមទុនដែលមិនអាចស្ដារឡើងវិញបាន
- ការជម្រះបញ្ជីតាមផ្លូវតុលាការ

### ៣.៤.១. ការជម្រះបញ្ជីក្រុមហ៊ុន

ការជម្រះបញ្ជីក្រុមហ៊ុន គឺជាការដោះស្រាយកិច្ចការហិរញ្ញវត្ថុរបស់អាជីវកម្ម ឬ បុគ្គល ដោយជាទូទៅធ្វើការបំលែងទៅជាសាច់ប្រាក់នូវរាល់ទ្រព្យសកម្មទាំងឡាយ ដើម្បីចែកចាយឲ្យទៅឥណទានយក[28]។ ពាក្យ ការជម្រះបញ្ជី នេះ ត្រូវបានបែងចែកចេញពីពាក្យ ការរំលាយ ។ ដោយផ្អែកតាមការស្នើយោបល់របស់ក្រុមប្រឹក្សាភិបាល នៅពេលរំលាយក្រុមហ៊ុន មហាសន្និបាតវិសាមញ្ញនៃម្ចាស់ហ៊ុន ត្រូវកំណត់នូវវិធានការនៃការជម្រះបញ្ជីក្រុមហ៊ុន និង តែងតាំងអ្នកជម្រះ បញ្ជីម្នាក់ ឬ ច្រើននាក់ ដោយកំណត់សិទ្ធិអំណាចឲ្យបានច្បាស់លាស់ លើកលែងតែការជម្រះបញ្ជីនោះត្រូវសម្រេចដោយតុលាការ។ ការជម្រះបញ្ជីក្រុមហ៊ុន គឺជានីតិវិធីមួយដែលត្រូវបានអនុវត្ត ព្រមៗគ្នាជាមួយនឹងការរំលាយក្រុមហ៊ុនដែរ ដែលការជម្រះបញ្ជីនេះ អាចមានជាការជម្រះបញ្ជី ដោយស្ម័គ្រចិត្ត និង ការជម្រះបញ្ជីតាមផ្លូវតុលាការ។

#### ៣.៤.១.១. ការជម្រះបញ្ជីក្រុមហ៊ុនដោយស្ម័គ្រចិត្ត

ចំពោះអភិបាល ឬ ម្ចាស់ភាគហ៊ុនម្នាក់ ដែលមានសិទ្ធិបោះឆ្នោតនៅពេលមហាសន្និបាត ម្ចាស់ហ៊ុន អាចស្នើឲ្យជម្រះបញ្ជី និង រំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តបាន។ លិខិតជូនដំណឹងស្ដីពីការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងគោលបំណងជម្រះបញ្ជី ឬ រំលាយក្រុមហ៊ុនដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជី និង ការរំលាយក្រុមហ៊ុននោះ។

ឧទាហរណ៍ ៖ នៅក្នុងមាត្រាទី ៤៤ នៃលក្ខន្តិកៈរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី (ACLEDA Bank.PLC) បានកំណត់ថា ធនាគារ អាចត្រូវរំសាយ ហើយចំណូលពីការលក់ ( បន្ទាប់ពីបានដោះបំណុលរបស់ធនាគាររួចរាល់ហើយ) ត្រូវបែងចែកឲ្យភាគទុនិក តាមសមាមាត្រនៃចំនួនភាគហ៊ុនដែលភាគទុនិកម្នាក់ៗមាននៅក្នុងស្តុក នៅពេលធ្វើការរំសាយធនាគារនោះ ដែលក្នុង នោះ

[28] ក្រសួងពាណិជ្ជកម្ម, សៀវភៅណែនាំ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និង ការប្រកបអាជីវកម្មអនុលោមតាមច្បាប់, ១១៣

ជាបឋមការរំសាយ ត្រូវបានស្នើឡើងដោយសម្លេងឆ្នោតគាំទ្រ ៧៥ ភាគរយ ឬ ច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សា ដែលកំពុងបម្រើការងារ។

**៣.៤.១.២. ការជម្រះបញ្ជីក្រុមហ៊ុនតាមផ្លូវតុលាការ**

នៅគ្រប់ពេលក្នុងអំឡុងពេលនៃការជម្រះបញ្ជីរបស់ក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ឬ ជនដែលមានការពាក់ព័ន្ធផលប្រយោជន៍អាចស្នើទៅតុលាការដើម្បីឲ្យការជម្រះបញ្ជីស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ។ អ្នកដាក់ពាក្យសុំត្រូវផ្តល់ឲ្យក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងស្តីពីការអនុវត្ត ហើយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិបង្ហាញតុលាការដោយផ្ទាល់ ឬ តាមរយៈតំណាង។

ម៉្យាងទៀត តុលាការអាចធ្វើអន្តរាគមន៍នូវមូលហេតុមួយចំនួនដូចជា ៖

- ក្រុមហ៊ុន មិនមានសកម្មភាពក្នុងរយៈពេល ១ ឆ្នាំ ចាប់តាំងពីការបង្កើតមក
- ក្រុមហ៊ុន បានបញ្ឈប់សកម្មភាពរបស់ខ្លួនជាង ១ ឆ្នាំមកហើយ
- ក្រុមហ៊ុន មានសមាជិកតិចជាង ៣រូប

**៣.៤.១.២. លទ្ធផលនៃការជម្រះបញ្ជីក្រុមហ៊ុន**

ក្រុមហ៊ុន បន្ទាប់ពីការជម្រះបញ្ជីត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយ ហើយសេចក្តីសម្រេចស្តីពីការរំលាយនេះ ត្រូវផ្ញើទៅឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នៅពេលពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយ ក្រុមហ៊ុន។ ជាពិសេសនោះ ក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ឬ អាចនិយាយបានថាក្រុមហ៊ុនលែងមាននីតិបុគ្គលិកលក្ខណៈតទៅទៀតហើយ។

ក្រោយ ពីធ្វើការជម្រះបញ្ជីហើយ ក្រុមហ៊ុន ត្រូវ ៖

- បង់សោហ៊ុយចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងអភិបាលបណ្តោះអាសន្ននិងការ
- ជម្រះបញ្ជីតាមផ្លូវតុលាការឬតាមការស្ម័គ្រចិត្ត។
- បង់ជូនរដ្ឋនូវពន្ធឬអាករដែលបានជំពាក់។
- បើកជូនបុគ្គលិកក្រុមហ៊ុននូវប្រាក់បៀវត្សដែលបានជំពាក់។
- ប្រគល់ត្រលប់ទៅវិញ នូវប្រាក់បញ្ញើរជាសាច់ប្រាក់ ជាមាស ឬមូលបត្រ និងប្រាក់បំណុលផ្សេងទៀត ពីសមាជិក ឬពីតតិយជន។

ប៉ុន្តែទោះជាយ៉ាងណា បទបញ្ញត្តិពីការរំលាយ និងការជម្រះបញ្ជីទាំងអស់ខាងលើនេះមិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលដាក់ពាក្យសុំក្ស័យធនទៅតុលាការឡើយ។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ផ្អែកតាមការសិក្សាស្រាវជ្រាវលើប្រធានបទអំពី ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត យើងសង្កេតឃើញថា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាក្រុមហ៊ុនទ្រង់ទាយធំដែលបង្កើតឡើងដោយសមាជិកចាប់ពីរ រីប្រាំពីរនាក់ឡើងទៅ។ ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានដើមទុនចាប់បី ២០(ម្ភៃ)លានរៀលឡើងទៅ ហើយសមាជិកម្នាក់ៗត្រូវទទួលខុសត្រូវសងសំណងលើទ្រព្យសម្បត្តិដែលខ្លួនបានដាក់បញ្ចូលតែប៉ុណ្ណោះ។ ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវបំពេញនូវល័ក្ខខ័ណ្ឌពីរគឺ ល័ក្ខខ័ណ្ឌសុពលភាព និងល័ក្ខខ័ណ្ឌទម្រង់ដូចដែលបានរៀបរាប់ខាងលើ។ បន្ទាប់ពីបំពេញល័ក្ខខ័ណ្ឌគ្រប់អស់ហើយក្រុមហ៊ុនត្រូវរៀបចំរចនាសម្ព័ន្ធនៃការគ្រប់គ្រងនៅក្នុងក្រុមហ៊ុន។

ដើម្បីឲ្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតប្រព្រឹត្តិទៅបាននិងស្របទៅតាមច្បាប់ គឺត្រូវតែចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។ ការចុះបញ្ជីក្រុមហ៊ុនត្រូវធ្វើទៅតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមាន ៦ ជំហ៊ានដូចជា៖

១. ការបង្កើតគណនីលើ CamDigikey App

២. ការ Log In ចូលទំព័រ Portal

៣. ដំណើរការចុះបញ្ជី

៤. ការទូរទាត់

៥. ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់កាលនីមួយៗ

៦. ការទទួលបានអាជ្ញាបណ្ណ/វិញ្ញាបនបត្រឌីជីថល។

បន្ទាប់ពីបានចុះបញ្ជីក្រុមហ៊ុនរួចរាល់ហើយក្រុមហ៊ុននឹងធ្វើការដំណើរការនៅលើទីផ្សារ។ ប្រតិបត្តិការចម្បងរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺ ការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ។

ឆ្លងតាមការស្រាវជ្រាវយើងខ្ញុំសង្កេតឃើញថា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានកំពុងទទួលលទ្ធផលវិជ្ជមានជាច្រើន ដោយហេតុថារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតលិខិតបទដ្ឋាន គតិយុត្តិជាច្រើនដើម្បីគ្រប់គ្រងទីផ្សារមូលបត្រ ដូច្នេះហើយធ្វើឲ្យមានអ្នកវិនិយោគជាច្រើនបានមកវិនិយោគនៅប្រទេសកម្ពុជា។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០២២

ច្បាប់ស្តីពីវិធាពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និង ច្បាប់វិសោធនកម្ម

ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ ២០០៧

អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ២០០៩

ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ឆ្នាំ២០២៥

## ២. សៀវភៅដែលពាក់ព័ន្ធ និងឯកសារផ្សេងៗ

ក្រសួងពាណិជ្ជកម្ម. សៀវភៅណែនាំ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់

សៀវភៅមគ្គុទេសក៍ ដំណើរការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ២០២០

អ៊ីវ ប៉ូលី. នីតិក្រុមហ៊ុម . ២០០៥

គង់សាផន. នីតិពាណិជ្ជកម្ម. ២០១២

គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង

# ឧបសម្ព័ន្ធ

## **បញ្ជីឧបសម្ព័ន្ធ**

| **ល.រ** | **ឈ្មោះឯកសារ** |
|---|---|
| **ឧបសម្ព័ន្ធទី១** | ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០២២ |
| **ឧបសម្ព័ន្ធទី២** | លក្ខន្តិកៈរបស់ធនាគារអេស៊ីលីដា ភីអីលស៊ី |
| **ឧបសម្ព័ន្ធទី៣** | សេចក្ដីជូនដំណឹងស្ដីពីការវិសោធនកម្មលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| **ឧបសម្ព័ន្ធទី៤** | ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម |
| **ឧបសម្ព័ន្ធទី៥** | ពាក្យសុំចុះផ្សាយក្នុងសារព័ត៌មាន |
| **ឧបសម្ព័ន្ធទី៦** | វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម |
| **ឧបសម្ព័ន្ធទី៧** | ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រ |
| **ឧបសម្ព័ន្ធទី៨** | វិញ្ញាបនបត្រចុះបញ្ជីមូលបត្រ |

**ឧបសម្ព័ន្ធទី១**

# ព្រះរាជក្រម

## យើង

នស/រកម/០១២២/០០៧

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានរួមពិធជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

## ស្តីពី

## វិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ .-**

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៥ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោម៖

- ដោយធ្វើនិរាករណ៍ មាត្រា១៦៦ មាត្រា១៧៥ មាត្រា១៨២ មាត្រា១៨៣ មាត្រា១៨៤ មាត្រា១៨៥ មាត្រា១៨៦ មាត្រា១៨៧ មាត្រា១៨៨ មាត្រា១៨៩ មាត្រា១៩០ និងមាត្រា១៩៦

- ដោយកែប្រែ មាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៥៩ មាត្រា៦២ មាត្រា៨៧ មាត្រា១០១ មាត្រា១០៦ មាត្រា១១០ មាត្រា១១៤ មាត្រា១១៥ មាត្រា១៣៧ មាត្រា១៤៤ មាត្រា១៦១ មាត្រា១៧៤ មាត្រា១៩២ មាត្រា១៩៥ មាត្រា២២៥ មាត្រា២៣៤ មាត្រា២៥៥ មាត្រា២៦២ មាត្រា២៧០ និងមាត្រា២៧១ និងដោយកែប្រែជំពូកនិងផ្នែក ព្រមទាំងបន្ថែមមាត្រា៨ ស្ទួន មាត្រា៨៣ ស្ទួន ក្នុងជំពូកទី២ និងមាត្រា១៤៧ ស្ទួន ក្នុងជំពូកទី៣ ដូចតទៅ៖

**មាត្រា១ .- ថ្មី**

ច្បាប់នេះកំណត់ពីទម្រង់នៃសហគ្រាសពាណិជ្ជកម្មដែលជាសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនិងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនិងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

**មាត្រា២ .- ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១-បុគ្គល សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

២-ពាណិជ្ជករ សំដៅដល់បុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបររបស់ខ្លួនជាប្រចាំ។

៣-មន្ត្រីចុះបញ្ជី សំដៅដល់អ្នកទទួលចុះបញ្ជីដែលបានតែងតាំងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

៤-ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម សំដៅដល់ការិយាល័យដែលបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

៥-បុត្រសម្ព័ន្ធ សំដៅដល់ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនមួយផ្សេងទៀត ដែលជា "ក្រុមហ៊ុនមេ"។

៥.១-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានក្រុមហ៊ុនសហកម្មសិទ្ធិមេកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ។

៥.២-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនត្រូវបានក្រុមហ៊ុនមូលធនមេត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងបុត្រសម្ព័ន្ធនោះ។

៦-លេខាធិការរបស់ក្រុមហ៊ុន សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុនមូលធន ហើយមានសិទ្ធិក្នុងការទទួលនិងរក្សាទុកឯកសារដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រុមហ៊ុន។

**មាត្រា៣ .- ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមូលធន ត្រូវមានលេខាធិការរបស់ក្រុមហ៊ុនដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវផ្តល់ជូនមន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដនិងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា។

ក្រុមហ៊ុនមូលធន ត្រូវផ្តល់ជូនមន្ត្រីចុះបញ្ជីនូវឈ្មោះរបស់លេខាធិការរបស់ក្រុមហ៊ុន ហើយលេខាធិការរបស់ក្រុមហ៊ុននោះត្រូវតែជារូបវន្តបុគ្គលដែលមានការយល់ដឹងនិងសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារនេះ។ លេខាធិការរបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតផ្លូវការនិងឯកសារទាំងឡាយព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការ ក្នុងនាមក្រុមហ៊ុនមូលធននោះ។

សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវផ្តល់ជូនមន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ។ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ជូនមន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីនិងការផ្លាស់ប្តូរលេខាធិការរបស់ក្រុមហ៊ុនក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ។

សហគ្រាសឯកបុគ្គល និងក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .- ថ្មី**

ឯកសារនិងព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្តល់ទៅឱ្យក្រុមហ៊ុនមូលធនត្រូវប្រគល់ទៅឱ្យលេខាធិការរបស់ក្រុមហ៊ុននៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។

ឯកសារនិងព័ត៌មានត្រូវប្រគល់ទៅឱ្យម្ចាស់សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិក្នុងអំឡុងម៉ោងធ្វើការធម្មតា លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករទូទៅបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះត្រូវផ្ញើទៅឱ្យក្រុមហ៊ុនវិញតាមអាសយដ្ឋានចុងក្រោយរបស់សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្ម។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីតាមគ្រប់មធ្យោបាយ ត្រូវបានចាត់ទុកជាការបញ្ជូនទៅសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធននោះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៥ .– ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនត្រូវប្រើនាមករណ៍ជាភាសាខ្មែរ។ នាមករណ៍ជាភាសាខ្មែរត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំស្មើនឹងពីរដងធំជាងភាសាដទៃទៀត ប្រសិនបើមាន។ ការបកប្រែន័យរបស់នាមករណ៍សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់។ នាមករណ៍ជាភាសាខ្មែរនិងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរនៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បែបបទឯកសារឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន។

## ជំពូកទី២ ថ្មី

## សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិ

### ផ្នែកទី១ ថ្មី

### សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**ក (ថ្មី). ការបង្កើតសហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**

**មាត្រា៨ .– ស្ទួន**

សហគ្រាសឯកបុគ្គល គឺជាសហគ្រាសដែលបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ហើយទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល។

ម្ចាស់សហគ្រាសឯកបុគ្គល គឺជាពាណិជ្ជករ។

សហគ្រាសឯកបុគ្គល ដែលស្ថិតក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

នាមករណ៍របស់សហគ្រាសឯកបុគ្គលត្រូវដាក់នូវពាក្យថា "សហគ្រាសឯកបុគ្គល" ឬសរសេរជាអក្សរកាត់ដាក់ខាងចុងឬខាងក្រោម។

កាតព្វកិច្ចនិងការទទួលខុសត្រូវរបស់សហគ្រាសឯកបុគ្គល គឺជាការទទួលខុសត្រូវដោយផ្ទាល់និងដោយគ្មានកម្រិតលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសនោះ។ សហគ្រាសឯកបុគ្គលមិនតម្រូវឱ្យមានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសទេ។ សហគ្រាសឯកបុគ្គលមិនមានអត្តសញ្ញាណ...ណៈដាច់ដោយឡែកពីម្ចាស់សហគ្រាសឡើយ។

## ១ (ថ្មី). ការរំលាយ និងការជម្រះបញ្ជីសហគ្រាសឯកបុគ្គល និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### មាត្រា៥៣ .- ស្ទួន

ម្ចាស់សហគ្រាសឯកបុគ្គល អាចរំលាយសហគ្រាសរបស់ខ្លួនបាននៅពេលណាក៏បាន។

សហគ្រាសឯកបុគ្គល អាចត្រូវបានរំលាយដោយមូលហេតុដូចខាងក្រោម៖

- តាមការស្ម័គ្រចិត្ត
- មរណភាពរបស់ម្ចាស់សហគ្រាស
- សេចក្តីសម្រេចរបស់តុលាការ។

នីតិវិធីក្នុងការរំលាយសហគ្រាសឯកបុគ្គលតាមការស្ម័គ្រចិត្តឬមរណភាពរបស់ម្ចាស់សហគ្រាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយមានអនុលោមភាពតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា៥៩ .- ថ្មី

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅតាមទម្រង់បែបបទដែលបានកំណត់និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបោះពុម្ពឬផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀត ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

### មាត្រា៦២ .- ថ្មី

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗ របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរំលាយ រហូតដល់រយៈពេល៥(ប្រាំ)ឆ្នាំ ចាប់ពីពេលដែលជម្រះបញ្ជីរួច។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះ តម្រូវឱ្យទុកជាភស្តុតាង។

### មាត្រា៨៧ .- ថ្មី

[illegible]និមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវ[illegible]ច្បាប់ ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការបោះផ្សាយលក់មូលបត្រ[illegible]នុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា១០១ .— ថ្មី**

ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរលុះត្រាតែ៖

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្មនិងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី៥១(ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គលឬនីតិបុគ្គលសញ្ជាតិខ្មែរ ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម។

**មាត្រា១០៦ .— ថ្មី**

ក្រុមហ៊ុនឬបុគ្គលម្នាក់ដែលជានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោម ជាលេសដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជន ដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបានឡើយ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ឬបានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួនឬដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះ៖

ក-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម។

ខ-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ។

គ-ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ។

ឃ-បុគ្គលដែលជាអភិបាល បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំងឬមិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តនិងប្រតិបត្តិការកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន។

ង-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬលេខាធិការរបស់ក្រុមហ៊ុនណាម្នាក់មិនមានសុពលភាពឬមិនយកជាការបានឡើយ។

ច-ប្រាក់ខ្ចីនិងការធានា ឬការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ។

**មាត្រា១១០ .— ថ្មី**

ម្ចាស់ភាគហ៊ុននិងម្ចាស់បំណុលរបស់ក្រុមហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចពិនិត្យគ្រប់ឯកសារដូចដែលបានចែងនៅក្នុងអំឡុងពេលម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើ[illegible]បមិនគិតកម្រៃ។

[illegible]ក្រុមហ៊ុនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាច[illegible]ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្រប។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១១៤ ._ ថ្មី**

ក្រុមហ៊ុននិងលេខាធិការរបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្នឱ្យបានទៀងទាត់ និងការពារឱ្យបានត្រឹមត្រូវ។

**មាត្រា១១៥ ._ ថ្មី**

លិខិតស្នាមឬកិច្ចសន្យា ដែលបានធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬអ្នកគ្រប់គ្រងម្នាក់ ឬលេខាធិការរបស់ក្រុមហ៊ុនម្នាក់ មានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ។

**មាត្រា១៣៧ ._ ថ្មី**

អភិបាលដែលមានពាក់ព័ន្ធពីផលប្រយោជន៍ មិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងការធ្វើសេចក្ដីសម្រេចណាមួយក្នុងការអនុម័តកិច្ចសន្យាមួយទេ លើកលែងតែកិច្ចសន្យានោះជា៖

ក-ការសម្របសម្រួលតាមរយៈការធានាសម្រាប់ទឹកប្រាក់ ដើម្បីឱ្យទៅអ្នកខ្ចីឬកាតព្វកិច្ចទាំងឡាយដែលបានធានាអនុវត្តដោយអភិបាលនោះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុនឬដល់សាខាមួយរបស់ក្រុមហ៊ុន។

ខ-កិច្ចសន្យាដែលទាក់ទងជាចម្បងទៅនឹងទឹកប្រាក់បំណាច់របស់ខ្លួនដែលជាអភិបាល អ្នកគ្រប់គ្រង មន្ត្រី ឬលេខាធិការរបស់ក្រុមហ៊ុនឬសាខាណាមួយរបស់ក្រុមហ៊ុន។

គ-កិច្ចសន្យាមួយធ្វើឡើងជាការរ៉ាប់រងសងការខូចខាតឬជាការធានា។

ឃ-កិច្ចសន្យាមួយធ្វើឡើងជាមួយសាខាណាមួយ។

**មាត្រា១៤៤ ._ ថ្មី**

ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នានិងរួមបញ្ចូលនូវសិទ្ធិ៖

១-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន។

២-ក្នុងការទទួលនូវភាគលាភដែលបានប្រកាសដោយក្រុមហ៊ុន។

៣-ក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ក្រុមហ៊ុននៅពេលមានការរំលាយ។

**មាត្រា១៤៧ ._ ស្ទួន**

ម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនមូលធនដែលមិនមានបំណងបង្ហាញអត្តសញ្ញាណនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន អាចតែងតាំងអ្នកតំណាងឱ្យឈរឈ្មោះជំនួសបាន។ ការតែងតាំងអ្នកតំណាង ត្រូវធ្វើឡើងតាមរយៈកិច្ចសន្យារវាងម្ចាស់ភាគហ៊ុននិងអ្នកតំណាង ដែលជារូបវន្តបុគ្គលឬនីតិបុគ្គល ហៅថាកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន។

[illegible]ពីអត្តសញ្ញាណរបស់ម្ចាស់ភាគហ៊ុននិងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន ត្រូវតម្កល់ទុក[illegible]ពាណិជ្ជកម្ម។ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការតម្កល់ព័ត៌មាននិងកិច្ចសន្យាតំណាងម្ចា[illegible] ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១៦១ .‒ ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងផ្នែកទី២នេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១-អ្នកទិញដោយសុទ្ធចិត្ត** សំដៅដល់អ្នកទិញដែលបង់ថ្លៃឱ្យត្រឹមត្រូវ និងដោយមិនដឹងថាមានបណ្តឹងទាមទារណាមួយ ហើយជាអ្នកដែលធ្វើការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ជាអ្នកកាន់កាប់ ឬជាអ្នកបញ្ជាដែលទទួលការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ចុះបញ្ជីដែលបានបោះចេញឱ្យ។

**២-អ្នកជើងសា** សំដៅដល់បុគ្គលជាប់កាតព្វកិច្ចទាំងស្រុងឬមួយភាគនៃពេលវេលារបស់ខ្លួនក្នុងកិច្ចការជួញដូរមូលបត្រ និងជាអ្នកធ្វើសកម្មភាពជំនួសគេ ឬទិញមូលបត្រពីអតិថិជន ឬលក់មូលបត្រទៅឱ្យអតិថិជនក្នុងកិច្ចការជំនួញដែលជាប់ពាក់ព័ន្ធនោះ។

**៣-ការប្រគល់** សំដៅដល់ការផ្ទេរការកាន់កាប់ដោយឆន្ទៈ។

**៤-សុទ្ធ** សំដៅដល់ពិតប្រាកដមិនក្លែងក្លាយឬក្លែងបន្លំ។

**៥-ម្ចាស់មូលបត្រ** សំដៅដល់បុគ្គលដែលកាន់កាប់មូលបត្រភាគហ៊ុនក្នុងលក្ខន្តិកៈក្រុមហ៊ុន ដែលត្រូវបានចេញដោយក្រុមហ៊ុនមូលធន។

**៦-ចេញបន្ថែម** សំដៅដល់ការចេញមូលបត្រលើសពីចំនួនអតិបរមានៃមូលបត្រ ដែលអ្នកចេញមូលបត្រត្រូវផ្តល់សិទ្ធិតាមលក្ខន្តិកៈរបស់ខ្លួន ឬតាមកិច្ចសន្យាច្បាស់លាស់ក្នុងការចេញមូលបត្រ។

**៧-អ្នកជាវ** សំដៅដល់បុគ្គលដែលទាញរកចំណេញពីមូលបត្រដោយធ្វើការលក់ បញ្ចាំ ធ្វើហ៊ីប៉ូតែក ចេញប័ណ្ណ ចេញប័ណ្ណសាជាថ្មី ធ្វើអំណោយនូវមូលបត្រនោះ ឬក៏ទាញរកចំណេញតាមកិច្ចការជំនួញណាមួយផ្សេងទៀតដោយឆន្ទៈ។

**៨- មូលបត្រ** សំដៅដល់លិខិតស្នាមដែលចេញដោយក្រុមហ៊ុនហើយដែល៖

ក-ស្ថិតក្នុងទម្រង់ទ្រាយចុះបញ្ជី។

ខ-ជាគំរូប័ណ្ណមួយលក់ជាសាធារណៈនៅលើការដោះដូរ ឬលើទីផ្សារមូលបត្រ ឬបានទទួលស្គាល់នៅក្នុងវិស័យណាមួយដែលនៅក្នុងវិស័យនោះ មូលបត្រត្រូវបានបោះចេញឬត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើឱ្យការវិនិយោគ។

គ-ជាប្រភេទមួយឬស៊េរីមួយនៃមូលបត្រ ដែលចែកនៅក្នុងប្រភេទឬស៊េរីនៃលិខិតស្នាម។

ឃ-ជាភស្តុតាងបញ្ជាក់ភាគហ៊ុន ភស្តុតាងនៃការចូលរួមចំណែក ឬភស្តុតាងនៃអត្ថប្រយោជន៍ផ្សេងៗ ក្នុងកាតព្វកិច្ចរបស់ក្រុមហ៊ុន។

**៩-ការផ្ទេរ** សំដៅដល់ជាការផ្ទេរដែលរួមបញ្ចូលទាំងការបញ្ជូនឱ្យដោយប្រតិបត្តិតាមច្បាប់។

**១០-គ្មានសិទ្ធិក្នុងការចុះហត្ថលេខា** សំដៅដល់មនុស្សម្នាក់ប្រព្រឹត្តដោយគ្មានសិទ្ធិពិតប្រាកដ ហើយរួមទាំងការក្លែងបន្លំផង។

**មាត្រា១៧៤ .‒ ថ្មី**

នៅក្នុងបណ្តឹងពាក់ព័ន្ធលើមូលបត្រ៖

[illegible]ការចុះហត្ថលេខាលើមូលបត្រ ក្នុងករណីចាំបាច់គឺត្រូវបានទទួលស្គាល់ លើកលែងតែ[illegible]ជាក់លាក់។

[illegible]នៅលើមូលបត្រគឺត្រូវបានសន្មតថាត្រឹមត្រូវនិងមានការអនុញ្ញាត។ ប៉ុន្តែប្រសិន[illegible]លេខាត្រូវបានចោទជាបញ្ហាបន្ទុកនៃការរកភស្តុតាងគឺស្ថិតនៅលើភាគីប្តឹងតវ៉ា។

គ-ប្រសិនបើហត្ថលេខាត្រូវបានទទួលស្គាល់ថាត្រឹមត្រូវឬត្រូវបានធ្វើឡើងរួចហើយ ការបង្ហាញមូលបត្រអាចផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់គ្រប់គ្រងលើមូលបត្រនោះ លើកលែងតែភាគីចុងចម្លើយបង្ហាញភស្តុតាងផ្ទុយឬកង្វះខាតលើសុពលភាពនៃមូលបត្រនោះ។

ឃ-បើភាគីចុងចម្លើយលើកឡើងនូវភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនៃមូលបត្រ ភាគីដើមចោទត្រូវបង្ហាញភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនោះទៅវិញ។

**មាត្រា១៩២ .- ថ្មី**

ប្រសិនបើមូលបត្រដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយមិនត្រឹមត្រូវពីបុគ្គលណាមួយក្នុងមូលហេតុណាក៏ដោយរួមទាំងអសមត្ថភាពរបស់បុគ្គលនោះផង បុគ្គលនោះអាចធ្វើការទាមទារទៅអ្នកពាក់ព័ន្ធណាមួយ លើកលែងតែចំពោះអ្នកទិញដោយសុទ្ធចិត្តដើម្បី៖

១-ទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រនោះ។

២-កាន់កាប់ភាពជាម្ចាស់លើមូលបត្រថ្មី បញ្ជាក់ច្បាស់នូវសិទ្ធិដូចគ្នាទាំងអស់ឬមួយផ្នែក។

៣-ទាមទារពេញការខូចខាតទាំងឡាយ។

សិទ្ធិក្នុងការទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រ ត្រូវអនុវត្តយ៉ាងជាក់លាក់ដែលការផ្ទេរកម្មសិទ្ធិត្រូវបានទប់ស្កាត់ ហើយមូលបត្រនោះត្រូវបានដកហូតយកមកតម្កល់ទុកវិញដើម្បីរង់ចាំបណ្តឹងតវ៉ា។

**មាត្រា១៩៥ .- ថ្មី**

ពេលណាដែលមូលបត្រនៅក្នុងទម្រង់ចុះបញ្ជីត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិនោះក្នុងករណីដូចតទៅ៖

១-ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានអនុវត្ត។

២-ការផ្ទេរកម្មសិទ្ធិនោះគឺស្របតាមច្បាប់ឬផ្ទេរទៅឱ្យអ្នកជាពិតប្រាកដ។

នៅពេលអ្នកចេញមូលបត្រមានភារកិច្ចចុះបញ្ជី ការផ្ទេរកម្មសិទ្ធិមូលបត្រពេលនោះ អ្នកចេញមូលបត្រត្រូវទទួលខុសត្រូវចំពោះបុគ្គលដែលបានបង្ហាញមូលបត្រសម្រាប់ឱ្យចុះបញ្ជីនូវការខាតបង់ដែលកើតឡើងពីការពន្យារពេលមិនសមហេតុសមផលក្នុងការចុះបញ្ជី ឬពីការខកខាន ឬការប្រកែកក្នុងការចុះបញ្ជីលើការផ្ទេរនោះ។

**មាត្រា២២៥ .- ថ្មី**

ម្ចាស់ភាគហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបានដោយមិនគិតថ្លៃ។

**មាត្រា២៣៤ .- ថ្មី**

[illegible]ត្រូវធ្វើការត្រួតពិនិត្យលើចំណុចដែលខ្លួនយល់ថាចាំបាច់ ដើម្បីរាយការណ៍ជូនម្ចាស់[illegible]លើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ។

[illegible]របស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុនឬអភិបាលបច្ចុប្បន្ន អ្នកគ្រប់គ្រងក្រុមហ៊ុន [illegible] ឬលេខាធិការរបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មាន ការបកស្រាយបំភ្លឺ និងបញ្ជី

គណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ។

សវនកររបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាតម្ចាស់ភាគហ៊ុន និងចូលរួមដើម្បីដឹងឮនូវកម្មវត្ថុដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករ ដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន។

ប្រសិនបើអភិបាលឬម្ចាស់ភាគហ៊ុន ទោះបីជាម្ចាស់ភាគហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្នឬសវនករពីមុនក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃមុនមហាសន្និបាត សវនករបច្ចុប្បន្នឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ។

**មាត្រា២៥៥ ._ ថ្មី**

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវៈ

- ប្រមូលទ្រព្យសម្បត្តិ
- រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន
- បំពេញកាតព្វកិច្ចទាំងឡាយ
- ធ្វើសកម្មភាពផ្សេងទៀតដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី
- តែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។ អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយនិងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ទាំងកម្មសិទ្ធិជាសាច់ប្រាក់ឬជាវត្ថុទៅឱ្យម្ចាស់ភាគហ៊ុនដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនដែលបានរំលាយ រយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំចាប់ពីកាលបរិច្ឆេទជម្រះបញ្ជីរួច។

**មាត្រា២៦២ ._ ថ្មី**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬហេតុការណ៍ពិតដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់នេះ។

ក្នុងករណីចាំបាច់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចតម្រូវឱ្យក្រុមហ៊ុន ... នូវព័ត៌មានដែលបានចុះបញ្ជីឬដែលបានធ្វើប្រតិវេទន៍ប្រចាំឆ្នាំនៅគ្រប់កាលៈទេសៈ។

... គ្រប់គ្រងក្រុមហ៊ុនមានសិទ្ធិចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានឬឯកសារដែលបានធ្វើ ... ការរបស់ក្រុមហ៊ុន និងតម្រូវឱ្យក្រុមហ៊ុនផ្តល់ព័ត៌មានឬឯកសារបន្ថែម ដើម្បី ... ព័ត៌មាននិងឯកសារ។

**មាត្រាពីរ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ១៤រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២២

នសរកម.២២០១.០៥

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនដើម្បីថ្លែងទៅតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

ឧបសម្ព័ន្ធទី២

# លក្ខន្តិកៈរបស់ធនាគារ
# អេស៊ីលីដា ភីអិលស៊ី
# ( ACLEDA Bank.PLc )

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ACLEDA Bank Plc.

# លក្ខន្តិកៈ

# Articles of Association

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
ដើមទុនចុះបញ្ជី ១៣លានដុល្លារអាមេរិក

អាជ្ញាប័ណ្ណជាធនាគារពាណិជ្ជ
ថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៣

# លក្ខន្តិកៈធនាគារអេស៊ីលីដា ភីអិលស៊ី

ក្រសួងពាណិជ្ជកម្ម
ការិយាល័យចុះបញ្ជី ពាណិជ្ជ
...

## ជំពូកទី១ ប្រការទូទៅ

**មាត្រាទី ១.** នាម :

ធនាគារនេះ មាននាមជាភាសាខ្មែរថា ធនាគារអេស៊ីលីដា ភីអិលស៊ី និងជាភាសា អង់គ្លេសថា ACLEDA Bank Public Limited Company (ACLEDA Bank Plc ចាប់ពីនេះតទៅហៅថា ធនាគារ ។

**មាត្រាទី ២.** លក្ខណៈច្បាប់ :

ធនាគារ ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ក្រោមច្បា និងការអនុវត្តនៃព្រះរាជាណាចក្រកម្ពុជា ។ បំណុលរបស់ភាគទុនិកៈនិមួយៗត្រូវបាន កំណត់ ត្រឹមមូលធនភាគហ៊ុនរបស់ខ្លួនដែលបានចុះបញ្ជីរួចហើយ និង ពុំទាន់បានបង់ប្រាក់ ចូលធនាគា លើកលែងតែករណី ដូចមានចែងក្នុងមាត្រាទី៤៥ ខាងក្រោម ។

**មាត្រាទី ៣.** គោលដៅ :

ធនាគារ ត្រូវបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រោមបទប្បញ្ញត្តិរបស់ ធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការជាធនាគារពាណិជ្ជកម្ម តាមរយៈការិយាល័យកណ្តាល នៅភ្នំពេញ និងសាខានានានៅតាមបណ្តាខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តោត យកចិត្តទុកដាក់ជាពិសេសលើការផ្តល់សេវាកម្មឥណទាន និង សេវាកម្មផ្សេងទៀតរបស់ធនា ជូនស្រទាប់ទីផ្សារជាន់ទាប ព្រមទាំងចូលរួម ក្នុងសកម្មភាពដទៃទៀតដែល ក្រុមប្រឹក្សាភិ យល់ឃើញថាស្របនឹងគោលដៅ ។

**មាត្រាទី ៤. ការិយាល័យដែលចុះបញ្ជី :**

ការិយាល័យ ធនាគារ ចុះបញ្ជីនៅផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់ បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអាច បើកការិយាល័យបន្ថែមទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅក្នុងប្រទេសដទៃទៀត ហើយអាចផ្លាស់ប្តូរការិយាល័យដែលបានចុះបញ្ជី បន្ទាប់ពីបានចុះបញ្ជី ក្រសួងពាណិជ្ជកម្ម និងបានទទួលការយល់ព្រមពីធនាគារជាតិនៃកម្ពុជា អោយផ្លាស់ប្តូរផងដែរ ។

**មាត្រាទី ៥. ត្រានិងផ្លាកសញ្ញា :**

ក) ធនាគារ ត្រូវបង្កើតត្រាកាលណាតម្រូវអោយមាន ។

ខ) ផ្លាកសញ្ញានៃធនាគារ គឺរូបហង្សពណ៌មាសឈរនៅចំកណ្តាលរង្វង់មូលពណ៌ខៀវ។

## ជំពូកទី ២ ភាគហ៊ុន និងមូលធនភាគហ៊ុន

**មាត្រាទី ៦. ភាគហ៊ុន និងមូលធនភាគហ៊ុនដែលចុះបញ្ជី :**

មូលធនសរុបរបស់ធនាគារ ដែលចុះបញ្ជី មានចំនួន ១៣.០០០.០០០ដុល្លារអាមេរិក (ដប់បីលានដុល្លារអាមេរិក) ចែកជា ១៣.០០០.០០០ (ដប់បីលាន) ភាគហ៊ុន តំលៃភាគហ៊ុននិមួយៗ គឺស្មើនឹង ១.០០ដុល្លារ (មួយដុល្លារអាមេរិក) ។ ភាគហ៊ុននិមួយៗ មានសម្លេងឆ្នោតមួយ (១) សំលេង ហើយនឹងបានទទួលភាគលាភ និងរាល់ការបែងចែកផ្សេងៗទៀតរបស់ធនាគារស្មើភាពគ្នា ។ ការបែងចែងនៃភាគហ៊ុន មិនត្រូវបោះផ្សាយទេ ។

**មាត្រាទី ៧. ភាគទុនិក :**

៧.១ ACLEDA NGO ជាអង្គការក្រៅរដ្ឋាភិបាល ដែលមានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ព្រះរាជាណាចក្រកម្ពុជា ក្នុងអាសយដ្ឋាន នៅផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ចាប់ពីពេលនេះទៅហៅថា "ACLEDA NGO") ។

៧.២ *អេ អេស អេ អ៊ីនខ* ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង និ ចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានអាស័យដ្ឋាន ផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុ សង្កាត់ បឹងត្របែក ខំណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ចាប់ពីនេះ តទៅហៅថា "ASA, Inc") ។

៧.៣ DEG: Deutsche Investitions-und Entwicklungsgesellschaft mb ដែលជាក្រុមហ៊ុនទទួល ខុសត្រូវមានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃសាធារណរដ្ឋសហព័ អាល្លឺម៉ង់ ក្នុងអាស័យដ្ឋាន Belvederestr. 40, D-50933, Cologne, Germa (ចាប់ពីនេះតទៅហៅថា "DEG") ។

៧.៤ Nederlandse Financierings-Maatschappij voor Ontwikkelingsland N.V. ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង ក្រោមច្បាប់នៃប្រទេសហូ ដែលបានចុះបញ្ជីក្នុងអាស័យដ្ឋាន Anna Van Saksenlaan 71, 2593 HW, T Hague, the Netherlands (ចាប់ពីនេះតទៅហៅថា "FMO") ។

៧.៥ International Finance Corporation បង្កើតឡើងក្រោមមាត្រានៃកិច្ចព្រមព្រៀងដែ ចុះហត្ថលេខារវាងប្រទេសជាសមាជិក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ ដែលមា អាស័យដ្ឋាន ការិយាល័យកណ្តាលនៅ 2121 Pennsylvania Avenue, N.W Washington D.C. 20433, U.S.A (ចាប់ពីនេះតទៅហៅថា "IFC") .

៧.៦ Stichting Triodos Doen ជាមូលនិធិមួយដែលបានកសាងឡើងក្រោមច្បាប់នៃប្រទេសហូ ដែលមាន ការិយាល័យធំនៅ Utrechtseweg 60, P.O Box 55, 3700 AB Zei the Netherlands (ចាប់ពីនេះតទៅហៅថា "TRIODOS") និង

៧.៧ Triodos Custody B.V ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ដែលបានបង្កើតឡ ក្រោមច្បាប់នៃប្រទេសហូឡង់ ក្នុងនាមជាក្រុមហ៊ុន Triodos Fair Share Fu ជាមូលនិធិដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសហូឡង់ ដែលមាន ការិយាល័យធំ Utrechtseweg 60, P.O Box 55, 3700 AB Zeist, the Netherla (ចាប់ពីនេះតទៅហៅថា "TC") ។

**មាត្រាទី ៨- ការទិញភាគហ៊ុន :**

ភាគទុនិកៈទាំងអស់ នឹងទិញភាគហ៊ុន តាមចំនួនដូចខាងក្រោមនេះ :

| ភាគទុនិកៈ | ភាគរយនៃកម្មសិទ្ធិ | មូលធនភាគហ៊ុន (US$) | ចំនួនភាគហ៊ុន |
|---|---|---|---|
| ACLEDA NGO | 40.07% | $5,208,457 | 5,208,457 |
| ASA, Inc | 10.93% | $1,421,543 | 1,421,543 |
| DEG | 12.25% | $1,592,500 | 1,592,500 |
| FMO | 12.25% | $1,592,500 | 1,592,500 |
| IFC | 12.25% | $1,592,500 | 1,592,500 |
| TRIODOS | 10.33% | $1,342,500 | 1,342,500 |
| TC | 1.92% | $250,000 | 250,000 |
| <u>TOTAL</u> | 100.00% | $13,000,000 | 13,000,000 |

**មាត្រាទី ៩- មូលប័ត្រភាគហ៊ុន :**

ភាគទុនិកៈនីមួយៗ មានសិទ្ធិទទួលពីធនាគារនូវមូលប័ត្រភាគហ៊ុនមួយឬច្រើន ដែលបញ្ជាក់ភាគហ៊ុនរបស់ខ្លួននៅក្នុងធនាគារ ។ មូលប័ត្រភាគហ៊ុននេះ ត្រូវបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំ ឬក្រុមប្រឹក្សាភិបាលនៃធនាគារចំនួនពីររូប ដោយបញ្ជាក់នាម និងអាសយដ្ឋានរបស់ធនាគារ បោះត្រាធនាគារ មានចុះលេខរៀង និងចុះកាលបរិច្ឆេទចេញមូលប័ត្រភាគហ៊ុន មូលប័ត្រភាគហ៊ុននីមួយៗ ត្រូវសរសេរការហាមឃាត់រាល់ការផ្លាស់ប្តូរ ដែលមានចែងក្នុង មាត្រាទី១៣ទាំងស្រុង ។ ធនាគារនឹងថែរក្សាបញ្ជីឈ្មោះស្តុកដែល កត់ត្រាការបញ្ចេញ, ការបង្វិលត្រឡប់មកវិញ, ការលុបចោល ឬកិច្ចការផ្សេងៗទៀតអំពីមូលប័ត្រភាគហ៊ុន។

**មាត្រាទី ១០- ហត្ថលេខីដែលបានទទួលការអនុញ្ញាត :**

មានតែអ្នកដែលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាភិបាលទេ ដែលមានសិទ្ធិចុះហត្ថលេខាលើឯកសារធនាគារ ដើម្បីដាក់កាតព្វកិច្ចលើធនាគារ។ ហត្ថលេខាដែលគ្មានការអនុញ្ញាត ត្រូវចាត់ទុកជាមោឃៈ ។ ក្រុមប្រឹក្សាភិបាលអាចប្រគល់សិទ្ធិជូនអគ្គនាយកធនាគារ ដែលបានតែងតាំងក្រោមមាត្រាទី ៤២ ។

**មាត្រាទី ១១-** **ការបង្កើនមូលធនដែលបានចុះបញ្ជី :**

ធនាគារ អាចបង្កើនមូលធនដែលបានចុះបញ្ជីរួចហើយ ដោយបញ្ចេញភាគហ៊ុននៅក្នុងធនាគារ បន្ថែមទៀត ដោយមានការយល់ព្រមជាមុនដោយសំលេងឆ្នោតគាំទ្រយ៉ាងតិចចំនួន ៧៥ ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការងារ និងពីភាគទុនិកៈដែលកាន់កាប់ភាគហ៊ុន ៧៥ភាគរយ ឬច្រើនជាងនេះ នៃភាគហ៊ុនដែលនៅសល់ក្នុងធនាគារ ។

**មាត្រាទី ១២-** **ការទិញភាគហ៊ុនវិញ :**

តាមច្បាប់ដែលបានអនុញ្ញាត ធនាគារ អាចទិញភាគហ៊ុនរបស់ខ្លួនវិញ ដោយត្រូវមានការយល់ព្រមជាមុន ដោយមានសំលេងឆ្នោតគាំទ្រយ៉ាងតិចចំនួន ៧៥ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែល កំពុងបំពេញការងារ និងពីភាគទុនិកៈដែលកាន់កាប់ភាគហ៊ុន៧៥ភាគរយ ឬច្រើនជាងនេះនៃភាគហ៊ុន ដែលនៅសល់ក្នុងធនាគារ ។

**មាត្រាទី ១៣-** **ការហាមឃាត់លើការផ្ទេរភាគហ៊ុន :** ភាគហ៊ុននៃធនាគារ ត្រូវស្ថិតក្រោមការហាមឃាត់លើការផ្ទេរភាគហ៊ុន ដូចតទៅ :

១៣.១ ភាគទុនិកៈ *អង្គការអេស៊ីលីដា* មិនអាចបន្ថយភាគរយនៃភាគហ៊ុនរបស់ខ្លួនតិចជាង ២៨ ភាគរយ នៃមូលធនភាគហ៊ុនធនាគារដែលបានចុះបញ្ជីរួចហើយ ។

១៣.២ ប្រសិនភាគទុនិកៈ *អង្គការអេស៊ីលីដា* លក់ ឬ ប្រកាសលក់ភាគហ៊ុនណាមួយរបស់ខ្លួន ទៅអោយនរណាម្នាក់ "ក្នុងនេះហៅថាអ្នកទិញ" តាមការចុះទាត់ម្តង ឬច្រើនដង ភាគទុនិកៈផ្សេងៗទៀតទាំងអស់ ក៏មានសិទ្ធិលក់ភាគហ៊ុនរបស់ខ្លួនទៅអ្នកទិញនោះក្នុងតម្លៃ និងលក្ខខំណត្តដូចគ្នា ដែល *អង្គការអេស៊ីលីដា* លក់ ឬ ប្រកាសលក់ដែរ ។ កិច្ចព្រមព្រៀងទាំងឡាយណាដែលភាគទុនិក *អង្គការអេស៊ីលីដា* ធ្វើឡើង ដើម្បីលក់ភាគហ៊ុនរបស់ខ្លួនដែលផ្ទុយពីមាត្រា១៣.២នេះ គឺចាត់ទុកជាមោឃភាព ។ មាត្រាទី១៣.២នេះ មិនត្រូវអនុវត្តលើការផ្ទេរភាគហ៊ុនពី *អង្គការអេស៊ីលីដា* ទៅ ASA, Inc. ទេ ដរាបណា *អង្គការអេស៊ីលីដា* នៅតែកាន់កាប់ភាគហ៊ុន ២៨ ភាគរយ ឬច្រើនជាងនេះនៃមូលនិធិភាគហ៊ុនដែលបានចុះបញ្ជី របស់ធនាគារ ។

## ជំពូកទី ៣ សន្និបាតភាគទុនិកៈ

**មាត្រាទី ១៤.** **សន្និបាតភាគទុនិកៈប្រចាំឆ្នាំ និងសន្និបាតផ្សេងៗ :**

ភាគទុនិកៈ ត្រូវកោះសន្និបាតប្រចាំឆ្នាំយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ តែមិនឱ្យហួសពី១៥ខែ ក្រោយពីសន្និបាតលើកមុនឡើយ ។ ក្រុមប្រឹក្សាភិបាល ត្រូវកំណត់កាលបរិច្ឆេទ និង ពេលវេលា សន្និបាត ។ សន្និបាតភាគទុនិកៈវិសាមញ្ញ អាចប្រព្រឹត្តិទៅបានក្នុងករណី :

ក. មានការសំរេចពីក្រុមប្រឹក្សាភិបាល ឬ

ខ. មានការស្នើសុំជាលាយលក្ខណ៍អក្សរពីភាគទុនិកៈទាំងឡាយដែលមានភាគហ៊ុនសរុប មិនតិចជាង ភាគរយនៃភាគហ៊ុនដែលនៅសល់ក្នុងធនាគារ ។ ក្រុមប្រឹក្សាភិបាល "ឬ ភាគទុនិកៈ ណាដែល ជាអ្នកកោះសន្និបាត " នឹងកំណត់របៀបវារៈសន្និបាត ។ សមាជិកក្រុមប្រឹក្សា ២រូប ភាគទុនិកៈណាដែលកាន់កាប់ភាគហ៊ុនចាប់ពី ២០ភាគរយឡើងទៅនៃភាគហ៊ុន ដែលនៅសល់ ធនាគារ អាចស្នើបន្ថែមរបៀបវារៈទៅក្នុងសន្និបាតបាន ។

**មាត្រាទី ១៥.** **ការសំរេចរបស់ភាគទុនិកៈដោយគ្មានការធ្វើសន្និបាត :**

ការសំរេចណាមួយដែលតម្រូវឱ្យសន្និបាតរបស់ភាគទុនិកៈសំរេច អាចអនុវត្តបានដោយគ្មានការ សន្និបាត ក្នុងករណីមានការយល់ព្រមជាលាយលក្ខណ៍អក្សរអោយអនុវត្ត ដោយភាគទុនិកៈទាំង ឡាយដែលមានសិទ្ធិបោះឆ្នោតលើបញ្ហានេះ ។ ឯកសារចម្លងច្រើនច្បាប់នៃសេចក្តីសំរេចចុះហត្ថលេខា ទាំងទូរសារថតចម្លង ដែលសមាជិកមួយរូប ឬច្រើនរូបបានចុះហត្ថលេខា ត្រូវចាត់ទុកថា សេចក្តីជាលាយលក្ខណ៍អក្សរនេះ ត្រូវរក្សាទុកក្នុងសៀវភៅកំណត់ហេតុ ដោយចាត់ទុកជាកំណត់ ហេតុសន្និបាតរបស់ភាគទុនិកៈ ។

**មាត្រាទី ១៦.** **ទីកន្លែងសន្និបាតភាគទុនិកៈ :**

រាល់សន្និបាតភាគទុនិកៈ ត្រូវតែរៀបចំឡើងនៅការិយាល័យធនាគារដែលបានចុះបញ្ជី ឬនៅកន្លែង ផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬដោយភាគទុនិកៈដែលជាអ្នកកោះអង្គប្រជុំ នោះ ។

6

**មាត្រាទី ២១.** **ការដឹកនាំនៃសន្និបាតភាគទុនិកៈ :**

សន្និបាតនៃភាគទុនិកៈនីមួយៗ ត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬក្នុងករណីអវត្តមានប្រធានក្រុមប្រឹក្សាភិបាល ភាគទុនិកៈដែលមាន ឬដែលបានទទួលសិទ្ធិប្រទានត្រូវបោះឆ្នោតជ្រើសរើសតាំងប្រធានក្រុមប្រឹក្សាភិបាលស្តីទី ដើម្បីដឹកនាំសន្និបាតភាគទុនិកៈដោយមានសំលេងឆ្នោតគាំទ្រភាគច្រើន ។ រាល់សេចក្តីសំរេចរបស់ភាគទុនិកៈ ត្រូវតែកត់ត្រាជាលាយលក្ខណ៍អក្សរក្នុងកំណត់ហេតុនៃសន្និបាត ដែលសេចក្តីសំរេច ត្រូវបានធ្វើឡើងក្នុងសន្និបាតនោះ ហើយកំណត់ហេតុនោះត្រូវបានផ្តល់ការយល់ព្រមដោយភាគទុនិកទាំងអស់ ។ ការបោះឆ្នោតក្នុងសន្និបាតភាគទុនិកៈត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែករណីដែលមានការណែនាំពីប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រាទី ២២.** **ការបោះឆ្នោតដោយភាគទុនិក, ករណីពិសេស :**

ភាគហ៊ុនដែលនៅសល់នីមួយៗ មានសំលេងឆ្នោតមួយសំលេង ។ រាល់សេចក្តីសំរេចរបស់ភាគទុនិ ដែលធ្វើឡើងអនុលោមទៅតាមមាត្រាទាំងឡាយនៃលក្ខន្តិកៈនេះ ត្រូវតែធ្វើឡើងដោយការបោះឆ្នោ ដោយមានសំលេងគាំទ្រយ៉ាងតិច ហាសិបមួយភាគរយ (៥១ភាគរយ) នៃភាគហ៊ុនដែលនេ សល់ រៀងរាល់សន្និបាតដែលមានកូរ៉ុមគ្រប់ចំនួន លើកលែងតែករណីដូចខាងក្រោមនេះ ដែ តម្រូវអោយមានសំលេងឆ្នោតគាំទ្រ ៧៥ភាគរយ ឬច្រើនជាងនេះ នៃភាគហ៊ុនដែលនៅដដែលៈ

២២.១ ការកែប្រែមាត្រាទាំងឡាយនៃលក្ខន្តិកៈ

២២.២ ការផ្លាស់ប្តូរគោលដៅ ឬកិច្ចការជំនួញរបស់ធនាគារ

២២.៣ ការផ្លាស់ប្តូរអាជ្ញាប័ណ្ណរបស់ធនាគារ

២២.៤ ការផ្លាស់ប្តូរមូលធនជាភាគហ៊ុនរបស់ធនាគារដែលបានចុះបញ្ជី

២២.៥ ការចូលរួមគ្នា, ការដាក់បញ្ចូលគ្នា, ការរៀបចំឡើងវិញ ឬតាមនីតិវិធីណាក៏ដោយ ដែលតម្រូវ អោយផ្ទេរទ្រព្យសម្បត្តិធនាគារភាគខ្លះ ឬក៏ទាំងអស់ ទៅអោយអង្គភាពផ្សេងទៀត ។

២២.៦ ការអនុម័តលើគោលនយោបាយទូទៅរបស់ធនាគារ ទាក់ទិននឹងការធ្វើប្រតិបត្ត និងការទូ ភាគលាភ និងការផ្លាស់ប្តូរទាំងនេះ ។

២២.៧ ការរំលាយដោយស្ម័គ្រចិត្ត និងការជំរះបញ្ជីធនាគារ ក្រោមមាត្រាទី ៤៤

២២.៨ ការកែប្រែរបៀបវារៈសន្និបាតភាគទុនិក ក្រោមមាត្រាទី ១៨

២២.៩ ការទិញភាគហ៊ុនវិញ ដោយអនុលោមទៅតាមមាត្រាទី ១២ និង

២២.១០ ការអនុមតិលើការតែតាំង ឬការផ្លាស់ប្តូរតំនែងការគណនីរបស់ធនាគារ ។

8

**មាត្រាទី ២៣.** **ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល :**

ភាគទុនិកៈម្នាក់ៗ មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលដោយខ្លួនឯង ឬដោយសិទ្ធិប្រទានបានមួយសំលេងក្នុងមួយភាគហ៊ុនដែលភាគទុនិកៈនោះកាន់កាប់ហើយ ក៏អាចបោះឆ្នោតទាំងអស់ឱ្យសមាជិកក្រុមប្រឹក្សាណាម្នាក់ ឬច្រើននាក់ដែលឈរឈ្មោះបោះឆ្នោត ។

## ជំពូកទី ៤ ក្រុមប្រឹក្សាភិបាល

**មាត្រាទី ២៤.** **សិទ្ធិអំណាច និងភារកិច្ច ប្រធាន :**

ក. ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវកំណត់យុទ្ធសាស្ត្រនៃធនាគារ និងត្រួតពិនិត្យដំណើរការកិច្ចការជំនួញ ។ សមាជិកក្រុមប្រឹក្សាត្រូវធ្វើកិច្ចការណា ដែលផ្តល់ផលប្រយោជន៍ដល់ធនាគារ ។

ខ. អំណាចរបស់ក្រុមប្រឹក្សាភិបាល ត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់មានអំណាចចាត់ចែងមន្ត្រី ឬនិយោជិតរបស់ធនាគារ ចុះហត្ថលេខាលើកិច្ចសន្យាណាមួយ ឬចាត់ចែងប្រតិបត្តិការរបស់ធនាគារ លុះត្រាតែបានទទួលអំណាចពិសេស ដើម្បីចាត់ចែងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល។

គ. សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ អាចពិនិត្យមើលដោយគ្មានកំរិត នូវបញ្ជី ឬរបាយការណ៍របស់ធនាគារនៅក្នុងពេលម៉ោងធ្វើការធម្មតា ។

ឃ. ក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវជ្រើសតាំងក្នុងចំណោមសមាជិករបស់ខ្លួនមួយរូប ដើម្បីធ្វើជាប្រធានដោយសំលេងឆ្នោតគាំទ្រភាគច្រើន ។ ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ។ សំលេងឆ្នោតគាំទ្រភាគច្រើននៃសមាជិកក្រុមប្រឹក្សាភិបាលដែលកំពុងបំពេញការងារនៅការិយាល័យអាចផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាលបាន ប៉ុន្តែមិនអាចដកហូតតួនាទីសមាជិកក្រុមប្រឹក្សាបានឡើយ ។

**មាត្រាទី ២៥.** **សមាជិកក្រុមប្រឹក្សាភិបាល :**

ក្រុមប្រឹក្សាភិបាល មានសមាជិក ៥រូប ។

**មាត្រាទី ២៦.** **សមាសភាពក្រុមប្រឹក្សាភិបាលលើកដំបូង:**

ក្រុមប្រឹក្សាភិបាលដំបូង រួមមានសមាជិកដូចតទៅនេះ សមាជិកមួយរូបៗ ត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ :

១ លោក ជា សុខ
២ Mr. John Brinsden
៣ Mr. Peter Kooi
៤ Ms. Jutta Wagenseil
៥ Mr. Emile Hubert Joseph Groot
៦ Mr. Deepak C. Khanna
៧ Ms. Femke Bos
៨ លោក ឡុញ ថុល
៩ អ្នកស្រី សុខ ចន្ទ្ធានី

**មាត្រាទី ២៧.** **ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាល :**

ភាគទុនិកៈ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល សំរាប់អាណត្តិ ៣ ឆ្នាំ ដូចមានចែង ក្នុងមាត្រាទី២៣ ខាងលើ ។

**មាត្រាទី ២៨.** **អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល :**

អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងហោចណាស់ ៤ដងក្នុងមួយឆ្នាំចន្លោះពីអង្គប្រជុំមួយ ទៅអង្គប្រជុំមួយមិនលើសពី៤ខែឡើយ ។ យ៉ាងហោចណាស់ អង្គប្រជុំក្រុមប្រឹក្សាភិបាលចំនួន២ លើកក្នុងចំណោមអង្គប្រជុំក្រុមប្រឹក្សាភិបាលទាំង៤លើក ត្រូវតែមានមនុស្សចូលរួមប្រជុំពេញអង្គ អង្គប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល អាចធ្វើឡើងនៅពេលណាក៏បាន អោយតែមានសំណូមពរ សមាជិកក្រុមប្រឹក្សាភិបាលចំនួន ៣រូប ។

**មាត្រាទី ២៩.** **កិច្ចប្រជុំតាមអ៊ីមែល ឬ តាមទូរស័ព្ទ :**

លើកលែងតែអង្គប្រជុំក្រុមប្រឹក្សាភិបាលចំនួន២លើក ដូចដែលបានរៀបរាប់ក្នុងមាត្រាទី ២៨ ២... ទី២ អង្គប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាលអាចប្រជុំពិភាក្សា

តាមអ៊ីមែល ឬតាមទូរសព្ទ ។ ចំពោះការប្រជុំតាមទូរសព្ទ មានប្រសិទ្ធិភាព ក្នុងករណីដែលអ្នកចូលរួមប្រជុំទាំងអស់បញ្ជាក់ថាអាចស្តាប់ឮទៅវិញទៅមកទាំងអស់គ្នាបាន ។ ការប្រជុំដែលធ្វើឡើងតាម អ៊ីមែល មានប្រសិទ្ធិភាព ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់បានបញ្ជាក់អំពីគោលបំណងនៃអង្គប្រជុំនោះ ដោយផ្តល់ព្រឹត្តិបត្រនូវការទទួលស្គាល់ តាម អ៊ីមែល និងមានពេលវេលាពិនិត្យពិចារណាដែលបានផ្តល់ដោយសមាជិកក្រុមប្រឹក្សាភិបាលណាមួយ ហើយកំណត់ហេតុនៃរាល់អង្គប្រជុំ ត្រូវបញ្ជាក់ថា អង្គប្រជុំធ្វើឡើងដោយ អ៊ីមែល និង សង្ខេបខ្លឹមសារអ៊ីមែល ដែលពិចារណាផ្តល់ដោយក្រុមប្រឹក្សាភិបាល ។

**មាត្រាទី ៣០.** **សេចក្តីជូនដំណឹងពីអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល :**

សេចក្តីជូនដំណឹងអង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើជូនទៅសមាជិកក្រុមប្រឹក្សាទាំងអស់ចូលរួមប្រជុំយ៉ាងហោចណាស់៣០ថ្ងៃមុនកាលបរិច្ឆេទប្រជុំចាប់ផ្តើម

លិខិតជូនដំណឹង ត្រូវចុះកាលបរិច្ឆេទ, ពេលវេលា, និងទីកន្លែងប្រជុំ ព្រមទាំងរបៀបវារៈដែលត្រូវពិភាក្សា និងសំរេចផងដែរ ។

**មាត្រាទី ៣១.** **របៀបវារៈ :**

សមាជិកក្រុមប្រឹក្សា ដែលមានចំនួន៣រូប អាចស្នើបន្ថែម របៀបវារៈអង្គប្រជុំក្រុមប្រឹក្សាភិបាលណាមួយក៏បាន ដោយគ្រាន់តែជូនដំណឹងអំពីរបៀបវារៈនោះដល់ប្រធាន និងសមាជិកក្រុមប្រឹក្សាដទៃទៀត អោយបានយ៉ាងហោចណាស់ ១៥ថ្ងៃមុនពេលអង្គប្រជុំចាប់ផ្តើម។ ប្រសិនបើសមាជិកក្រុមប្រឹក្សាទាំងអស់ ដែលកំពុងបំពេញការងារ វត្តមានក្នុងអង្គប្រជុំ ឬដោយសិទ្ធិប្រទាន សមាជិកក្រុមប្រឹក្សាទាំងអស់នោះ អាចយល់ព្រមជាឯកច្ឆន្ទដើម្បីបន្ថែមរបៀបវារៈ ។

**មាត្រាទី ៣២.** **ទីកន្លែងប្រជុំ :**

គ្រប់អង្គប្រជុំដោយផ្ទាល់ ត្រូវរៀបចំឡើងនៅការិយាល័យកណ្តាលនៃធនាគារ ដែលបានចុះដូចបានចែងក្នុងមាត្រាទី៤ ឬនៅកន្លែងណាមួយផ្សេងទៀត ដែលក្រុមប្រឹក្សាភិបាលបានសំរេច



FB.

មាត្រាទី ៣៣. **កូរ៉ុម :**

កូរ៉ុមនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលជាចំនួនភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាភិបាល ដែលកំពុងបំពេ ការងារ លើកលែងតែកិច្ចប្រជុំតាមអ៊ីម៉ែល ដែលសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវតែបំពេញ កូរ៉ុម ។ សិទ្ធិប្រទានដែលចូលរួមប្រជុំ អាចរាប់បញ្ចូលជាវត្តមាននៃកូរ៉ុម ។

មាត្រាទី ៣៤. **ការបោះឆ្នោតដោយក្រុមប្រឹក្សាភិបាល, ករណីពិសេស :**

សមាជិកក្រុមប្រឹក្សាមួយរូបៗ មានសំលេងឆ្នោតមួយសំលេង ។ រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សា ភិបាល ដែលធ្វើឡើងដោយអនុលោមទៅតាមមាត្រាទាំងឡាយនៃលក្ខន្តិកៈនេះ ត្រូវមានសំលេ ឆ្នោតគាំទ្រយ៉ាងហោចណាស់ ៥១ភាគរយ នៃក្រុមប្រឹក្សាភិបាលចូលរួម រាល់អង្គប្រជុំដែលមាន កូរ៉ុមគ្រប់ចំនួន លើកលែងតែ ការសំរេចដែលទាក់ទងករណីដូចខាងក្រោមនេះ ដែលតម្រូ ការសំលេង ឆ្នោតគាំទ្រយ៉ាងហោចណាស់ ៧៥ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែល បំពុងបំពីការ :

៣៤.១ ការកែប្រែមាត្រាទាំងឡាយនៃលក្ខន្តិកៈ

៣៤.២ ការអនុម័តលើ ថវិកាប្រចាំឆ្នាំ ឬការផ្លាស់ប្តូរថវិកាប្រចាំឆ្នាំ ដែលអគ្គនាយកបានដាក់ជូន នោះរាប់បញ្ចូលទាំងថវិកា ដែលចំណាយលើមូលធន

៣៤.៣ ការចំណាយលើមូលធនលើសពីថវិកា ដែលត្រូវបានអនុម័តពីមុនរួចមកហើយ សំរាប់ សារពើពន្ធនោះ

៣៤.៤ ការតែងតាំង ឬ ដកតំណែងអគ្គនាយកធនាគារ ក្រោមមាត្រាទី ៤២

៣៤.៥ ការធ្វើប្រតិវេទ ឬការទូទាត់ភាគលាភ ឬការបែងចែកទ្រព្យសកម្មផ្សេងៗទៀតទៅអោយភាគ នៃធនាគារ ។

៣៤.៦ ការរំលាយដោយស្ម័គ្រចិត្ត ឬ ការជំរះបញ្ជីធនាគារ ក្រោមមាត្រា ៤៤

៣៤.៧ ការអនុម័តលើការទូទាត់ភាគលាភរបស់ធនាគារ ត្រូវធ្វើទៅតាមគោលនយោបាយទាក់ទិននឹងការ ប្រតិវេទ និងការទូទាត់ភាគលាភស់ធនាគារ ។

៣៤.៨ ការទិញភាគហ៊ុនវិញ ដោយអនុលោមទៅតាមមាត្រាទី ១២

**មាត្រាទី ៣៥.** **សេចក្តីសំរេច និង កំណត់ហេតុ :**

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវតែបង្ហាញអោយឃើញច្បាស់ ដោយការកត់ត្រាសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលជាលាយលក្ខណ៍អក្សរ ឬដោយកំណត់ហេតុនៃអង្គប្រជុំ ដែលសេចក្តីសំរេចបានធ្វើឡើង កំណត់ហេតុនោះ នឹងត្រូវបានអោយសច្ចានុម័តដោយអង្គប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល។ ការបោះឆ្នោតនៅរៀងរាល់អង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយការលើកដៃ ឬដោយវិធីផ្សេងៗទៀត ដែលអធិបតីក្រុមប្រឹក្សាជាអ្នកសំរេច ។

**មាត្រាទី ៣៦.** **ការសំរេចជាឯកច្ឆន្ទជាលាយលក្ខណ៍អក្សរ :**

សមាជិកក្រុមប្រឹក្សាភិបាល អាចធ្វើសកម្មភាពនៅចន្លោះកិច្ចប្រជុំក្រុមប្រឹក្សាភិបាលតាមរយៈសេចក្តីសំរេចជាឯកច្ឆន្ទជាលាយលក្ខណ៍អក្សរដែលមានចុះហត្ថលេខា ដោយសមាជិកក្រុមប្រឹក្សាទាំងអស់ដែលមានសិទ្ធិបោះឆ្នោតលើបញ្ហានោះ។ ឯកសារថតចំលងច្រើនច្បាប់នៃសេចក្តីសំរេចនោះរួមទាំងទូរសារថតចម្លងដែលសមាជិកក្រុមប្រឹក្សាមួយរូបឬច្រើនរូបបានចុះហត្ថលេខានឹងត្រូវចាត់ទុកថាជាផ្នែកនៃសេចក្តីសំរេចមួយជាលាយលក្ខណ៍អក្សរតាមគោលបំណងនៃមាត្រានេះ ។

**មាត្រាទី ៣៧.** **ការបោះឆ្នោតដោយសិទ្ធិប្រទាន :**

សមាជិកក្រុមប្រឹក្សាម្នាក់ ដែលមិនអាចចូលរួមក្នុងអង្គប្រជុំ ក្រុមប្រឹក្សាភិបាលបាន អាចតែងតាំងអ្នកទទួលសិទ្ធិប្រទានម្នាក់ ដើម្បីធ្វើការបោះឆ្នោត ក្នុងអង្គប្រជុំនោះជំនួសខ្លួនអោយតែ :

១- សិទ្ធិប្រទានដែលបានតែងតាំងនោះ គឺជាសមាជិកក្រុមប្រឹក្សាផងទៃទៀត និង

២- សិទ្ធិប្រទាននោះ ត្រូវបានតែងតាំងសំរាប់តែអង្គប្រជុំមួយនោះទេ ។ សិទ្ធិប្រទានត្រូវរាប់បញ្ចូលជាក្រុម។ សិទ្ធិប្រទាន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយប្រគល់ជូនប្រធានក្រុមប្រឹក្សាភិបាល អោយបានមុនពេលប្រជុំចាប់ផ្តើម ហើយត្រូវបញ្ជាក់ពីព្រំដែននៃសមត្ថកិច្ច ឬក៏សិទ្ធិអំណាច។ សិទ្ធិប្រទានលែងមានសិទ្ធិ ឬក៏ចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលតទៅទៀតហើយនៅពេលណាសមាជិកក្រុមប្រឹក្សា ដែលបានផ្តល់សិទ្ធិប្រទានមានវត្តមានជាក់ស្តែងក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ដោយខ្លួនឯងផ្ទាល់ ។

**មាត្រាទី ៣៥. សេចក្តីសំរេច និង កំណត់ហេតុ :**

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវតែបង្ហាញអោយឃើញច្បាស់ ដោយការកត់ត្រាសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលជាលាយល័ក្ខអក្សរ ឬដោយកំណត់ហេតុនៃអង្គប្រជុំ ដែលសេចក្តីសំរេចបានធ្វើឡើង កំណត់ហេតុនោះ នឹងត្រូវបានអោយសច្ចានុម័តដោយអង្គប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល។ ការបោះឆ្នោតនៅរៀងរាល់អង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយការលើកដៃ ឬដោយវិធីផ្សេងៗទៀត ដែលអធិបតីក្រុមប្រឹក្សាជាអ្នកសំរេច ។

**មាត្រាទី ៣៦. ការសំរេចជាឯកច្ឆន្ទជាលាយល័ក្ខអក្សរ :**

សមាជិកក្រុមប្រឹក្សាភិបាល អាចធ្វើសកម្មភាពនៅចន្លោះកិច្ចប្រជុំក្រុមប្រឹក្សាភិបាលតាមរយៈសេចក្តីសំរេចជាឯកច្ឆន្ទជាលាយល័ក្ខអក្សរដែលមានចុះហត្ថលេខា ដោយសមាជិកក្រុមប្រឹក្សាទាំងអស់ដែលមានសិទ្ធិបោះឆ្នោតលើបញ្ហានោះ។ ឯកសារថតចំលងច្រើនច្បាប់នៃសេចក្តីសំរេចនោះរួមទាំងទូរសារថតចម្លងដែលសមាជិកក្រុមប្រឹក្សាមួយរូបឬច្រើនរូបបានចុះហត្ថលេខានឹងត្រូវចាត់ទុកថាជាផ្នែកនៃសេចក្តីសំរេចមួយជាលាយល័ក្ខអក្សរតាមគោលបំណងនៃមាត្រានេះ ។

**មាត្រាទី ៣៧. ការបោះឆ្នោតដោយសិទ្ធិប្រទាន :**

សមាជិកក្រុមប្រឹក្សាម្នាក់ ដែលមិនអាចចូលរួមក្នុងអង្គប្រជុំ ក្រុមប្រឹក្សាភិបាលបាន អាចតែងតាំងអ្នកទទួលសិទ្ធិប្រទានម្នាក់ ដើម្បីធ្វើការបោះឆ្នោត ក្នុងអង្គប្រជុំនោះជំនួសខ្លួនអោយតែ :

១- សិទ្ធិប្រទានដែលបានតែងតាំងនោះ គឺជាសមាជិកក្រុមប្រឹក្សាផងទៀត និង

២- សិទ្ធិប្រទាននោះ ត្រូវបានតែងតាំងសំរាប់តែអង្គប្រជុំមួយនោះទេ ។ សិទ្ធិប្រទានត្រូវរាប់បញ្ចូលជាកូរ៉ុម។ សិទ្ធិប្រទាន ត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ ហើយប្រគល់ជូនប្រធានក្រុមប្រឹក្សាភិបាល អោយបានមុនពេលប្រជុំចាប់ផ្តើម ហើយត្រូវបញ្ជាក់ពីព្រំដែននៃសមត្ថកិច្ច ឬក៏សិទ្ធិអំណាច។ សិទ្ធិប្រទានលែងមានសិទ្ធិ ឬក៏ចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលតទៅទៀតហើយនៅពេលណាសមាជិកក្រុមប្រឹក្សា ដែលបានផ្តល់សិទ្ធិប្រទានមានវត្តមានជាក់ស្តែងក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ដោយខ្លួនឯងផ្ទាល់ ។

**មាត្រាទី ៣៨.** **សមាជិកក្រុមប្រឹក្សាដែលមានផលប្រយោជន៍ផ្ទាល់ខ្លួន :**

សមាជិកក្រុមប្រឹក្សាណាម្នាក់ដែលមានផលប្រយោជន៍ហិរញ្ញវត្ថុ ទោះផ្ទាល់ ឬដោយប្រយោល ដោយ (ឬបើមានសមាជិកក្រុមគ្រួសារផ្ទាល់មានផលប្រយោជន៍បែបនេះ) មុនពេលក្រុមប្រឹក្សាភិបាលធ្វើការសំរេច លើសំណើណាក៏ដោយសមាជិកក្រុមប្រឹក្សារូបនោះត្រូវតែជំរាបសមាជិកក្រុមប្រឹក្សាដទៃទៀតពីផលប្រយោជន៍នោះ មុនពេលអង្គប្រជុំក្រុមប្រឹក្សាភិបាលធ្វើការអនុម័ត ហើយសមាជិកក្រុមប្រឹក្សាទាំងអស់ មិនត្រូវចូលរួមពិភាក្សាលើសំណើនោះទេ លុះត្រាណាតែត្រូវ អោយចូលរួមពិភាក្សាដោយមានសំលេងឆ្នោតគាំទ្រភាគច្រើន ពីសមាជិកក្រុមប្រឹក្សាដទៃទៀតដែល ចូលរួមក្នុងអង្គប្រជុំនោះ ។ សមាជិកក្រុមប្រឹក្សានោះ មិនត្រូវបោះឆ្នោតលើករណីបែបនោះ ទេ ប៉ុន្តែវត្តមានរបស់សមាជិកក្រុមប្រឹក្សាទាំងអស់ នឹងត្រូវបានរាប់បញ្ចូលក្នុងកូរ៉ុមនៃអង្គប្រជុំ ។

**មាត្រាទី ៣៩.** **ការដកតំណែងសមាជិកក្រុមប្រឹក្សា :**

មានតែភាគទុនិកៈដែលបានជ្រើសរើស ឬតែងតាំងសមាជិកក្រុមប្រឹក្សាទេ ដែលអាចដកសមាជិកក្រុមប្រឹក្សាបាន ។ ការដកតំណែងនេះ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលាដោយគ្រាន់តែមាន ការជូនដំណឹងសមស្របដល់ប្រធានក្រុមប្រឹក្សាប៉ុណ្ណោះ ។

**មាត្រាទី ៤០.** **ការបំពេញកន្លែងទំនេរក្នុងក្រុមប្រឹក្សាភិបាល :**

បើអាសនៈណាមួយទំនេរក្នុងក្រុមប្រឹក្សាភិបាល មុនពេលដាច់អណត្តិធម្មតារបស់សមាជិកក្រុមប្រឹក្សា ដោយមូលហេតុមរណភាព សុំលាឈប់ ចូលនិវត្តន៍ ឬត្រូវបានដកចេញពីសមាជិកក្រុមប្រឹក្សា ភិបាលភាគទុនិកៈ ដែលជ្រើសតាំង ឬតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលថ្មី ដើម្បីបំពេញអាណត្តិ ដែលនៅសល់របស់អតីតសមាជិកក្រុមប្រឹក្សាភិបាលមុននោះ ។

**មាត្រាទី ៤១.** **គណៈកម្មាធិការនានានៃក្រុមប្រឹក្សាភិបាល :**

ក្រុមប្រឹក្សាភិបាល ត្រូវបង្កើតគណៈកម្មាធិការសវនកម្ម, គណៈកម្មាធិការឥណទាន, គណៈកម្មាធិការត្រួតពិនិត្យការអនុវត្តច្បាប់ និងគណៈកម្មាធិការត្រួតពិនិត្យទ្រព្យសម្បត្តិ និងបំណុល ហើយ អាចបង្កើត គណៈកម្មាធិការដទៃផ្សេងៗទៀត ដែលយល់ថាចាំបាច់ក្នុងការដឹកនាំកិច្ចការជំនួញ និងប្រតិបត្តិការរបស់ធនាគារ ។ គណៈកម្មាធិការទាំងនេះបង្កើតឡើង តាមឆន្ទៈរបស់ ក្រុមប្រឹក្សាភិបាល ហើយសមាជិកទាំងអស់នៃគណៈកម្មាធិការទាំងនេះ ត្រូវតែអនុវត្តទៅតាម ឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ៥ ថ្នាក់ដឹកនាំ

**មាត្រាទី ៤២.** **អគ្គនាយក :**

ក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងអគ្គនាយកមួយរូបសំរាប់ដឹកនាំកិច្ចការធនាគារ ហើយអាចដក តំណែងអគ្គនាយក ដោយអនុលោមទៅតាមមាត្រាទី៣៤.៤។ អគ្គនាយក ត្រូវទទួលខុសត្រូវ ក្នុងការអនុវត្ត និង ប្រកាន់យកយុទ្ធសាស្ត្រ និងការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវម ភារៈកិច្ចទទួលខុសត្រូវផ្សេងៗទៀត ដូចដែលក្រុមប្រឹក្សាភិបាលកំណត់អោយនៅពេលណាមួយ អគ្គនាយកត្រូវផ្តល់របាយការណ៍តាមពេលកំណត់ ជូនដល់ក្រុមប្រឹក្សាភិបាល រាប់ទាំងរបាយការណ៍ ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ។

**មាត្រាទី ៤៣.** **ថ្នាក់ដឹកនាំផ្សេងៗទៀត :**

អគ្គនាយក ត្រូវតែងតាំងនាយក នាយកដ្ឋាននានារបស់ធនាគារ និងថ្នាក់ដឹកនាំមន្ត្រីដទៃផ្សេ ទៀត ដែលអគ្គនាយកគិតថា វាជាតំរូវការចាំបាច់ សំរាប់ធនាគារ ។ អគ្គនាយក ត្រូវរៀប តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំទាំងនោះ។ អគ្គនាយក ឬក្រុមប្រឹក្សា ភិបាល អាចដកហូតថ្នាក់ដឹកនាំទាំងនោះបាន។

## ជំពូកទី ៦ ប្រការសំខាន់ៗដទៃទៀត

**មាត្រាទី ៤៤.** **ការរំសាយដោយស្ម័គ្រចិត្ត និងការជំរះបញ្ជី :**

ធនាគារ អាចត្រូវរំសាយ ហើយចំណូលពីការលក់ (បន្ទាប់ពីបានដោះបំណុលរបស់ធនាគាររួចរាល់ ហើយ) ត្រូវបែងចែកអោយភាគទុនិកៈតាមសមាមាត្រនៃចំនួនភាគហ៊ុន ដែលភាគទុនិកៈម្នាក់ៗ នៅក្នុងស្តុក នៅពេលធ្វើការរំសាយធនាគារនោះ។ ជាបឋមការរំសាយ ត្រូវបានស្នើឡើងដោយ សំលេងឆ្នោតគាំទ្រ៧៥ភាគរយ ឬច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការ ហើយបានទទួលសច្ចានុម័តយល់ព្រមពីភាគទុនិកៈដោយសំលេងឆ្នោតគាំទ្រ៧៥ភាគរយ ឬច្រើន នេះ នៃភាគហ៊ុនដែលនៅសល់ ។ ប្រសិនបើការរំសាយ មានសំលេងឆ្នោតគាំទ្រពីភាគទុនិក ៩៩ភាគរយនៃភាគហ៊ុនដែលនៅសល់ ដោយមិន គ្រប់តាមសំលេងឆ្នោតគាំទ្រ ៧៥ភាគរយ

តំរូវដោយឃ្លាខាងលើ ការសំរេចរំលាយ ឬមិនរំលាយធនាគារ ត្រូវតែបញ្ជូនទៅដោះស្រាយ តាមរយៈមជ្ឈត្តិនិច្ឆ័យ ដោយយោងទៅតាមច្បាប់មជ្ឈត្តិនិច្ឆ័យរបស់ សភាពាណិជ្ជកម្មអន្តរជាតិ (ICC) ដែលប្រតិបត្តិដោយមជ្ឈត្តករមួយ ឬច្រើនរូប ដែលបានតែងតាំងទៅតាមច្បាប់ ទីកន្លែងធ្វើមជ្ឈត្តិនិច្ឆ័យនោះ គឺនៅប្រទេសសិង្ហបុរី។ សមាសភាពតុលាការមជ្ឈត្តកម្ម មាន មជ្ឈត្តករបីរូប ដែលជ្រើសតាំងដោយសភាពាណិជ្ជកម្មអន្តរជាតិ។ ភាសាអង់គ្លេសគឺជាភាសា ដែលប្រើប្រាស់ជាផ្លូវការក្នុងដំណើរការមជ្ឈត្តិនិច្ឆ័យ។ ប្រសិនបើតុលាការមជ្ឈត្តកម្មយល់ព្រមអោយ រំលាយធនាគារនោះ ត្រូវដាក់ក្នុងការរំលាយដោយមិនស្ម័គ្រចិត្ត ហើយតែងតាំងនាយក មួយរូប ឬច្រើនរូប ឬអ្នកជំរះបញ្ជីដើម្បីត្រួតពិនិត្យការរំលាយ និងការជំរះបញ្ជីនោះ ។

មាត្រាទី ៤៥- **ភាគទុនិកមានឥទ្ធិពល :**

*អង្គការអេស៊ីលីដា* គឺជាភាគទុនិកដែលមានឥទ្ធិពលតែមួយគត់នៃធនាគារ ក្រោមច្បាប់របស់ ធនាគារ និងបញ្ញត្តិនានា ដែលមានស្រាប់នៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលចុះបញ្ជីធនាគារ ឬដែលត្រូវអនុម័ត និងមានប្រសិទ្ធភាពក្នុងពេលអនាគត ហើយគ្មានភាគទុនិកណាផ្សេង នៃធនាគារ ដែលអាច ចាត់ទុកថាជាភាគទុនិកដែលមានឥទ្ធិពល ឬ មានស្ថានភាពដែលអាច បង្ខំអោយ *អង្គការអេស៊ីលីដា* ទទួលខុសត្រូវបន្ថែមលើសពីមូលធនដែលបានចុះបញ្ជីហើយមិនទាន់បាន បង់ឡើយ ។ *អង្គការអេស៊ីលីដា* ត្រូវបានទទួលស្គាល់ថាជាភាគទុនិកដែលមានឥទ្ធិពលតាមច្បាប់ បទបញ្ញត្តិ និងការអនុវត្តជាក់ស្តែង នៅកម្ពុជា ហើយម្យ៉ាងវិញទៀត មិនអាចទទួលខុសត្រូវ លើសពីចំនួនមូលធនចុះបញ្ជី មិនទាន់បានបង់នោះឡើយ ។

មាត្រាទី ៤៦- **គោលនយោបាយដឹកនាំទូទៅ :**

ធនាគារត្រូវដឹកនាំ និងចាត់ចែងកិច្ចការជំនួញ និងអាជីវកម្មរបស់ខ្លួនទៅតាមគោលនយោបាយ ដឹកនាំទូទៅដើម្បីធ្វើប្រតិបត្តិការធនាគារ ដែលបានអនុម័តយល់ព្រមដោយមានសំលេងឆ្នោតគាំទ្រ ៧៥ភាគរយ ឬច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សាភិបាល ដែលកំពុងបំរើការងារ ។

**មាត្រាទី ៤៧.** **ការទូទាត់ភាគលាភ ក្រោមគោលនយោបាយទូទៅនៃភាគលាភ :**

ធនាគារ នឹងមិនទូទាត់ភាគលាភទៅអោយភាគទុនិកៈទាំងអស់របស់ខ្លួន លើកលែងតែអនុលោម ទៅតាមគោលនយោបាយទូទៅដែលពាក់ព័ន្ធទៅនឹងការធ្វើប្រតិវេទ និងការទូទាត់ភាគលាភ ហើយមានការអនុម័តពីភាគទុនិកដែលកំពុងកាន់កាប់ភាគហ៊ុន ដោយសំលេងឆ្នោតគាំទ្រមិនតិចជាង ៧៥ ភាគរយ នៃភាគទុនិកដែលនៅសេស ។

**មាត្រាទី ៤៨.** **សវនករខាងក្រៅ :**

ធនាគារ ត្រូវតែងតាំងសវនករខាងក្រៅមួយ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងមានសច្ចានុមតិយល់ព្រមដោយភាគទុនិក ។

**មាត្រាទី ៤៩.** **ឆ្នាំសារពើពន្ធ :**

ក្រុមប្រឹក្សាភិបាល ត្រូវតែកំណត់ឆ្នាំសារពើពន្ធនៃធនាគារទៅតាមសេចក្តីសំរេច ។

**មាត្រាទី ៥០.** **ការកំណត់ការទទួលខុសត្រូវ :**

គ្មានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ជាប់ជំពាក់ផ្ទាល់ខ្លួន ដោយសារការបំពេញការងារ ឬការកើតមានការខកខានមិនបានសំរេចជាមួយធនាគារឡើយ លើកលែងតែការបំពេញភារកិច្ច ឬការខកខានមិនបំពេញភារកិច្ច បណ្តាលអោយមានកំហុសដែលពាក់ព័ន្ធទៅនឹងការគេងបន្លំ ការរំលោភច្បាប់ ប្រព្រឹត្តខុសដោយចេតនា ឬកិច្ចការជំនួញដែលសមាជិកក្រុមប្រឹក្សារូបនោះបានទទួល ផលប្រយោជន៍ជាទ្រព្យសម្បត្តិមិនសមស្រប ឬសេវាកម្មដែលសមាជិកក្រុមប្រឹក្សារូបនោះ គ្មាន នឹងទទួលដោយស្របច្បាប់ ។

**មាត្រាទី ៥១.** **ការធានាសំណង :**

យោងតាមមាត្រាទី៥០ បានចែងថាក្រុមប្រឹក្សាភិបាល ដែលបានបំពេញការងារដោយស្មោះត្រង់ និងសច្ចភាពល្អ, ធនាគារ នឹងធានាទទួលខុសត្រូវជួសសមាជិកក្រុមប្រឹក្សាភិបាលរូបនោះ នូវរាល់ការចំណាយ (រួមទាំងថ្លៃមេធាវី) ការវិនិច្ឆ័យ (លើបណ្តឹង)ណាមួយ និងការពិន័យ ជាប្រាក់ដែលកើតឡើង និងចំនួនទឹកប្រាក់ដែលបង់ ក្នុងការដោះស្រាយដែលក្រុមប្រឹក្សាភិបាល រូបនោះជាប់ពាក់ព័ន្ធជាមួយនឹង ឬក្នុងដំណើរការ រួមបញ្ចូលទាំង អំពើគំរាមកំហែង ទោះជារឿងរដ្ឋប្បវេណី, ព្រហ្មទណ្ឌ, រដ្ឋបាល ឬការស៊ើបអង្កេត តាមហេតុផលជាក់ស្តែង ដែលក្រុមប្រឹក្សារូបនោះ កំពុងបំពេញ ភារកិច្ចជាសមាជិកក្រុមប្រឹក្សាភិបាល ។

**មាត្រាទី ៥២.** **វិសោធនកម្ម ៖**

**៥២.១** **អ្នកមានសិទ្ធិលើកសំណើធ្វើវិសោធនកម្ម ៖**

ការធ្វើវិសោធនកម្មទៅលើមាត្រាទាំងឡាយនៃលក្ខន្តិកៈ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល និងភាគទុនិកៈ ដើម្បីធ្វើការសំរេច ប្រសិនបើសំណើនោះត្រូវបានធ្វើឡើងដោយ សមាជិកក្រុមប្រឹក្សាភិបាលដែលកំពុងបំពេញការងារយ៉ាងតិចចំនួន ១/៣ ឬពីភាគទុនិកៈដោយសំលេងឆ្នោតគាំទ្រចំនួន ៣៣-១/៣៖ ឬច្រើន ជាងនេះ នៃភាគហ៊ុនដែលនៅសល់ ។

**៥២.២** **សំលេងឆ្នោតចាំបាច់ ៖**

រាល់ការធ្វើវិសោធនកម្មរបស់មាត្រាទាំងឡាយនៃលក្ខន្តិកៈ តម្រូវអោយមាន ៖

ក- សំលេងឆ្នោតគាំទ្រយ៉ាងតិច ៧៥ភាគរយនៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលកំពុងបំពេញការងារ ដោយមានភ្ជាប់ជាមួយនូវ

ខ- សំលេងឆ្នោតគាំទ្ររបស់ភាគទុនិកយ៉ាងតិច ៧៥ភាគរយ ឬច្រើនជាងនេះនៃភាគហ៊ុនដែលនៅសល់ ។

# <u>ភាគទុនិក</u>

សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដែលហៅកាត់ថា *អង្គការអេស៊ីលីដា* ជាអង្គការក្រៅរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

លោក អ៊ិន ចាន់នី

ក្រុមហ៊ុន អេ អេស អេ អ៊ីន្ស ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង និងចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

លោក រ័ត្ន យូម៉េង

Deutsche Investitions- und Entwicklungsgesellschaft mbH, ក្រុមហ៊ុនទទួលខុសត្រូវ មានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

តំណាងដោយ ______________________

Ms. Jutta Wagenseil

Nederlandse Financierings-Maatschappij voor Ontwikkelingslanden N.V, ក្រុមហ៊ុនទទួលខុសត្រូវ មានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃប្រទេសហូល្លង់

តំណាងដោយ ______________________

Ms. Els Boerhof

International Finance Corporation, ជាអង្គការអន្តរជាតិ បានបង្កើតឡើងក្រោមមាត្រានៃកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងប្រទេសជាសមាជិក រួមទាំងព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

EDWARD NICHOLAS

Mr. ~~Deepak Khanna~~

Stichting Triodos Doen, ជាមូលនិធិមួយ បានកសាងឡើងក្រោមច្បាប់នៃប្រទេសហូល្លង់

តំណាងដោយ ______________________

Ms. Femke Bos

Triodos Custody B.V, ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានកសាងឡើងក្រោមច្បាប់នៃប្រទេសហូល្លង់ ក្នុងនាមជាក្រុមហ៊ុន Triodos Fair Share Fund ដែលជាមូលនិធិបានកសាងឡើងក្រោមច្បាប់នៃប្រទេសហូឡង់

តំណាងដោយ ______________________

Ms. Femke Bos

ក្រសួងពាណិជ្ជកម្ម
ការិយាល័យចុះបញ្ជី ពាណិជ្ជកម្ម

# ក្រុមប្រឹក្សាភិបាល

១. លោក ជា សុខ (តតិយជន) ____________

២- Mr. John Brinsden (តតិយជន) ____________

៣- Mr. Peter Kooi (តតិយជន) ____________

៤- Ms. Jutta Wagenseil (តតិយជន) ____________

៥- Mr. Emile Hubert Joseph Gruot (តតិយជន) ____________ by proxy

៦. Mr. Deepak C. Khenna (តតិយជន) by proxy ____________

៧. Ms. Femke Bos (តតិយជន) ____________

៨. លោក ឡុញ ថុល (តតិយជន) ____________

៩. អ្នកស្រី សុខ ចណ្ណនី (តតិយជន) ____________

បានឃើញនិងទទួលទុកជាឯកសារ
រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ..........ឆ្នាំ.....
ធនាគារជាតិ នៃ កម្ពុជា
ទេសាភិបាល

ឧបសម្ព័ន្ធទី៣

ការិយាល័យកណ្តាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង
## ស្តីពី
